ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ ភារកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឋានៈជា "សមាគមជនរងគ្រោះ"...

◆ អ្នកថតរូបអះអាងថា៖ ជនបរទេសស្លាប់នៅក្នុងគុករបស់ប៉ុលពត

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៤ ខែតុលា ឆ្នាំ២០០៧

ស្វែងរកការពិត

លេខ៩៤ ខែតុលា ឆ្នាំ២០០៧

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ កាតព្វកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ..........................១

**ផ្នែកឯកសារ**

◆ នៅតែគ្មានចម្លើយ..........................................................................២

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម ..............................................................................៧

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ..............................................១១

**ផ្នែកច្បាប់**

◆ សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះវិសាមញ្ញ ......................១៩

◆ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ...........................................២០

◆ ការចូលរួមនៃជនរងគ្រោះ.......................................................២៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ .....................................៣៦

◆ អ្នកថតរូបអះអាងថា៖ ជនបរទេសស្លាប់នៅក្នុងគុករបស់ប៉ុលពត ......៤៣

◆ អតីតអ្នកថតរូបនៅទួលស្លែងមិនបានអះអាងថា បានដឹងពុ............៤៤

◆ សុន្ទរកថារបស់ឯកអគ្គរដ្ឋទូត ចូសេហ្វ មូសូមេលី ........................៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ការពិតដែលដក់ក្នុងអារម្មណ៍នៃជីវិតកុមារភាពខ្ញុំ...........................៥២

◆ គោរពជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា .......................៥៩





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាលេខនេះ** ៖ អាន ហេនដែល, ដេន ពង្សរ៉ាស៊ី, ឌី ខាំបូលី, អេតែល ហ៊ីហ្គូនេត, ព្រុំ ដល្លា, ចូសេហ្វ មូសូមេលី, ហ៊ូ សាមិ, នួរ ហ៊ិន, **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ តាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ** ៖ យុត តារាសោភា **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ជំនួយការនិពន្ធនាយក** ៖ លី សុផល **ក្រាហ្វិកកុំព្យូទ័រ** ៖ ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ** ៖ វ័ន្ន តារាពិដោរ **Email: dccam@online.com.kh, Homepage: www.dccam.org**

*សំបុត្រ :*

# កាតព្វកិច្ចរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងឋានៈជា "សមាគមជនរងគ្រោះ" និងជួយរៀបចំពាក្យបណ្តឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាបន្ថែមគម្រោងថ្មីមួយទៀតទៅក្នុងសកម្មភាពផ្សព្វផ្សាយរបស់ខ្លួនដែលមានស្រាប់ដែលតាមរយៈនេះគឺផ្សព្វផ្សាយដល់ជនរងគ្រោះឲ្យដឹងអំពីសិទ្ធិចូលរួមក្នុងដំណើរការក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរយៈ (១) ការដាក់ពាក្យបណ្តឹងទៅតុលាការ ឬ (២) ការចុះក្នុងបញ្ជីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌជាក់លាក់ណាមួយ ។ ប្រសិនបើជនរងគ្រោះជ្រើសរើសថា នឹងចូលរួម មជ្ឈមណ្ឌលឯកសារកម្ពុជានឹងជួយដល់ជនរងគ្រោះទាំងនោះដើម្បីបំពេញពាក្យសុំ និងបញ្ជូនពាក្យសុំដែលមានព័ត៌មានចាំបាច់របស់ជនរងគ្រោះឲ្យទៅអង្គភាពជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ការពង្រីកនូវតួនាទីដែលគ្រោងទុករបស់ខ្លួននៅក្នុងដំណើរការបែបនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនចាំបាច់តាំងខ្លួនជា «សមាគមជនរងគ្រោះ» ដូចដែលកំណត់ដោយវិធានផ្ទៃក្នុងនិងសេចក្តីណែនាំ ០២/២០០៧ ស្តីពីការចូលរួមនៃជនរងគ្រោះ ។ ដោយហេតុផលនេះមជ្ឈមណ្ឌលឯកសារកម្ពុជាពុំចាំបាច់ចុះបញ្ជីម្តងទៀតនៅឯក្រសួងមហាផ្ទៃ ឬក៏នៅអង្គភាពជនរងគ្រោះឡើយ ។

ដូចដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងនិងសេចក្តីណែនាំ ០២/២០០៧ មុខងាររួមរបស់សមាគមជនរងគ្រោះគឺ ជួយដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ អាស្រ័យហេតុនេះ អង្គការទាំងឡាយដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានបំណងចង់ជួយដល់ជនរងគ្រោះក្នុងការដាក់ពាក្យបណ្តឹង ពុំចាំបាច់តម្រូវឲ្យចុះក្នុងបញ្ជីជាសមាគមជនរងគ្រោះឡើយ ។

សមាគមជនរងគ្រោះត្រូវបានយល់ឃើញថា ជាយានរបស់ក្រុមជនរងគ្រោះដែលរៀបចំឡើងក្នុងគោលបំណងចង់ចូលរួមក្នុងនាមជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រុមជនរងគ្រោះទទួលបាននូវជម្រើសម្យ៉ាងគឺមានមេធាវីរួមមួយដែលជ្រើសរើសចេញពីបញ្ជីមេធាវីរៀបចំដោយអង្គភាពជនរងគ្រោះ ឬម្យ៉ាងទៀតគឺរៀបចំដាក់បណ្តឹងរដ្ឋប្បវេណីដោយគ្រាន់តែចូលជាសមាជិកនៃ «សមាគមជនរងគ្រោះ» ណាមួយ ។ ដូច្នេះសមាគមជនរងគ្រោះត្រូវបានកំណត់ថាជាអង្គការមួយដែលរួមគ្នាបង្កើតឡើងដោយ «សមាជិក» ជាជនរងគ្រោះម្នាក់ៗ ។

ការទទួលខុសត្រូវរបស់សមាគមជនរងគ្រោះចំពោះសមាជិកខ្លួននឹងគ្របដណ្តប់លើជំនួយផ្នែករដ្ឋបាលនិងផ្នែកច្បាប់ពេញមួយអំឡុងពេលនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សមាជិកទាំងអស់នឹងត្រូវទទួលបានការធ្វើតំណាងឲ្យដោយមេធាវីរបស់សមាគមផ្ទាល់ ឬដោយមេធាវីដែលជ្រើសរើសដោយសមាគមចេញមកអំពីបញ្ជីឈ្មោះមេធាវីដែលផ្តល់ដោយអង្គភាពជនរងគ្រោះ ។ ឧទាហរណ៍ វិធានផ្ទៃក្នុងចែងថា «ដើមបណ្តឹងរដ្ឋប្បវេណីដែលជាសមាជិករបស់សមាគមជនរងគ្រោះមួយត្រូវតែតំណាងដោយមេធាវីរបស់សមាគមនោះ ហើយការកោះឲ្យចូលខ្លួននិងការជូនដំណឹងដល់សមាគមត្រូវធ្វើឡើងតាមរយៈសមាគម» ។

តាមរយៈការបំពេញទម្រង់ការចូលរួមដោយជនរងគ្រោះ ជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យអាចស្នើសុំចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរបៀបបីយ៉ាងៈ តាមរយៈការស្ម័គ្រចិត្តធ្វើជាសាក្សី, ការដាក់ពាក្យបណ្តឹង និងការដាក់ពាក្យចូលរួមជា «ជនរងគ្រោះ» នៅក្នុងបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

លោក-អ្នកគួរតែដឹងថាភាគច្រើននៃជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យទាំងអស់នឹងមិនត្រូវបានជ្រើសយកធ្វើជាសាក្សីទេ ។ ជាងនេះទៅទៀត ភាគច្រើននៃពាក្យបណ្តឹង និងបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនឹងទំនងជាត្រូវច្រានចោល ។ នេះមិនមែនមានន័យថា ព័ត៌មានដែលលោកអ្នកបានផ្តល់ឲ្យ ឬការរងគ្រោះដែលលោកអ្នកទទួលរងមិនសំខាន់នោះទេ ហើយក៏មិនមានន័យថាអង្គជំនុំជម្រះវិសាមញ្ញមិនជឿជាក់លោក-អ្នក ឬមិនផ្តល់តម្លៃចំពោះរឿងរ៉ាវរបស់លោក-អ្នកនោះទេ ។

**(តទៅទំព័រ៤២)**

# នៅតែគ្មានចម្លើយ

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង មេដឹកនាំនៃរបបនេះបានដឹកនាំតាមគោលនយោបាយថ្មីមួយ ក្នុងគោលបំណងប្រែក្លាយប្រទេសជាតិឲ្យឈានទៅរកភាពរីកចម្រើន និងរុងរឿងតាមទិសដៅ «បដិវត្តន៍មហាលោតផ្លោះ មហាអស្ចារ្យ» ។ ផ្ទុយទៅវិញការដឹកនាំតាមគោលនយោបាយនេះបានធ្វើឲ្យប្រទេសជាតិធ្លាក់ទៅក្នុងភាពរេចរឹលបន្តិចម្តងៗ ស្ទើរតែមិនអាចស្តារបាន ។ ខ្មែរក្រហមបានអនុវត្តជំហានដំបូងគឺសម្លាប់អ្នកចេះដឹង មន្ត្រីរាជការនិងទាហាននៅក្នុងរបបសាធារណរដ្ឋខ្មែរ និងសម្លាប់ជាបន្តបន្ទាប់ចាប់ពីប្រជាជនសាមញ្ញ កម្មាភិបាលក្រោមបង្គាប់និងអ្នកដែលនៅជុំវិញខ្លួនតាមវិធីច្រើនយ៉ាង ដូចជាផ្តល់របបអាហារមិនគ្រប់គ្រាន់ គ្មានថ្នាំព្យាបាលនៅពេលមានជំងឺ ចាប់បញ្ជូនទៅមន្ទីរឃុំឃាំងធ្វើទារុណកម្មដោយចោទប្រកាន់ថាក្បត់បក្ស ឬពីបទលួចទ្រព្យសម្បត្តិសហករណ៍ ។ ដូច្នេះដើម្បីរក្សាជីវិតប្រជាជនខ្លះបានព្យាយាមលាក់ប្រវត្តិរូបរបស់ខ្លួនខិតខំធ្វើការដើម្បីឲ្យអង្គការទុកចិត្ត ប្រជាជនមួយចំនួនទៀតលួចបេះបោចដំណាំដើម្បីបំពេញសេចក្តីស្រេកឃ្លានទោះបីជាដឹងថា ទង្វើទាំងអស់នេះជាការប្រឆាំងនឹងអង្គការក៏ដោយ ។ ផ្ទុយស្រឡះពីអ្នកទាំងនោះ ទូច ដែលធ្លាប់បានទទួលរបបអាហារគ្រប់គ្រាន់ដោយសារបានបម្រើអង្គការ ហើយក្រោយមកត្រូវបញ្ជូនទៅមន្ទីរអប់រំ២០៤ ដោយមិនដឹងមូលហេតុ ទូច បែរជាចង់ឲ្យខ្មែរក្រហមសម្លាប់គាត់ប្រសើរជាងការរស់នៅក្នុងមន្ទីរនោះទៅវិញ ។


ទូប

**តើបដិវត្តន៍របស់ ទូច មានអ្វីខ្លះ ទើបទទួលការតបស្នងបែបនេះ?**

ទូច កើតនៅក្នុងត្រកូលកសិករ មធ្យម និងជាកូនទី៥ក្នុងចំណោមបងប្អូន៧នាក់ ។ ទូច បានធំដឹងក្តីក្នុងពេលប្រទេសជាតិកើតសង្គ្រាម ហើយបានទទួលការសិក្សានៅត្រឹមកម្រិតដំបូងនៅសាលាបឋមសិក្សាវត្តឈើនាងផ្អែម ។ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារនៅឆ្នាំ១៩៧០ ទូច បានឈប់រៀននៅផ្ទះជួយកិច្ចការឪពុកម្តាយ ។ ចាប់តាំងពីមានព្រឹត្តិការណ៍នោះមកប្រជាជននៅក្នុងភូមិក្រាំងស្បែកតែងតែព្រួយបារម្ភណ៍ពីសុវត្ថិភាពរបស់ខ្លួនជានិច្ច ពីព្រោះថាភូមិនេះក្លាយជាតំបន់ប្រទាញប្រទង់គ្នារវាងកងទ័ពលន់នល់និងកងទ័ពខ្មែរក្រហម ។ នៅពេលថ្ងៃទាហានលន់នល់បានចូលមកគ្រប់គ្រង ហើយពេលយប់កងទ័ពខ្មែរក្រហមគ្រប់គ្រងម្តង ។ ពេលចូលមកម្តងៗកងទ័ពទាំងសងខាងតែងតែស្នើសុំស្បៀងពីប្រជាជន ដូចជាអង្ករនិងបន្លែជាដើម ហើយគ្មាននរណាម្នាក់នៅក្នុងភូមិហ៊ានជំទាស់នឹងការស្នើសុំនេះទេ ។ ដោយសារតែភាពភ័យខ្លាច នៅឆ្នាំ១៩៧២ ប្រជាជនបានភៀសខ្លួនទៅរស់នៅស្រុកត្រាំកក់មួយរយៈ ។ បន្ទាប់ពីស្ថានភាពបានស្ងប់ស្ងាត់បន្តិចប្រជាជនក៏វិលត្រឡប់មករស់នៅក្នុងភូមិរបស់ខ្លួនវិញ ។ ក៏ប៉ុន្តែស្ថានការណ៍បានប្រែប្រួលម្តងទៀត ។ នៅឆ្នាំ១៩៧៣ ខ្មែរក្រហមបានដណ្តើមកាន់កាប់តំបន់នោះទាំងស្រុង ហើយចាប់ផ្តើមជ្រើសរើសយុវជននិងយុវនារីឲ្យចូលបម្រើបដិវត្តន៍ ។

**សំបុត្រចាត់តាំងឲ្យចូលធ្វើបដិវត្តន៍**

ទូច បានចាប់ផ្តើមជីវិតបដិវត្តន៍នៅអាយុ១៧ឆ្នាំតាមសំបុត្រកោះហៅរបស់គណៈឃុំ ។ ហេតុការណ៍នេះបានកើតក្នុងឆ្នាំ១៩៧៤ ថ្ងៃមួយវេលាម៉ោង៨ព្រឹក មាននិរសារស្រីម្នាក់បានយកសំបុត្រមួយច្បាប់មកប្រគល់ឲ្យឪពុកម្តាយរបស់ ទូច ដើម្បីស្នើសុំ ទូច ឲ្យចូលបដិវត្តន៍ ។ នៅក្នុងសំបុត្រនោះមានឈ្មោះ ទូច និងអ្នកភូមិម្នាក់ទៀតឈ្មោះ អ៊ី (សព្វថ្ងៃបាត់ខ្លួន) ឲ្យទៅជួបជុំគ្នានៅវត្តអង្គញ់ខាងកើតភូមិ ។ ឪពុកម្តាយរបស់ ទូច មិនព្រមឲ្យ ទូច ចាកចេញពីគាត់ទាំងពីរឡើយ ពីព្រោះថាបងប្អូនប្រុសរបស់ ទូច បីនាក់បានចេញទៅធ្វើបដិវត្តន៍អស់ហើយ នៅសល់តែ ទូច ម្នាក់គ្រាន់ជួយមើលប្អូនៗជំនួសគាត់ទាំងពីរ ។ ទូច ក៏មិនចង់ទៅដែរ តែមិនអាចប្រកែកនឹងការចាត់តាំងនេះបានព្រោះនេះជាកាតព្វកិច្ច

បម្រើជាតិ ។ មួយម៉ោងក្រោយពីនិរសារចាកចេញ ទូច ក៏បានចាកចេញពីផ្ទះដែរ ។ យុវជន-យុវនារីសរុបទាំងអស់១០០នាក់ ដែលមកជួបជុំគ្នានៅវត្តអន្លង់ត្រូវបានបញ្ចូលជាកងវរយ ហើយបញ្ជូនទៅធ្វើការមន្ទីរ១៥០-កនៅស្រុកត្រាំកក់ ។ កងនេះត្រូវបានបែងចែកជាកងតូចទៀតដូចជា កងកាប់ឆ្ការ កងប្រមូល និងកងចិញ្ចាំជាដើម ។ ទូច ស្ថិតនៅក្នុងកងកាប់ឆ្ការមានសមាជិក ១០នាក់ ទទួលការចាត់តាំងទៅកាប់ឆ្ការព្រៃនៅភ្នំដីររមៀលដើម្បីដាំដំណាំ ។ ការងារនេះត្រូវធ្វើតាំងពីម៉ោង៧ព្រឹកដល់ម៉ោង១១ និងពីម៉ោង១ដល់ម៉ោង៥ល្ងាច ហើយត្រូវហូបបបរនៅទីនោះព្រោះកងយុវជន(ជាកងវែក) វែកបបរមកដល់កន្លែងធ្វើការតែម្តង ។ ទូច សម្គាល់ឃើញថា ពេលពួកគាត់កំពុងធ្វើការមានឈ្លបប្រដាប់ដោយអាវុធឈរយាមគាត់ធ្វើការជានិច្ចដោយសារខ្លាចមានអ្នកលួចរត់ទៅផ្ទះ ។ មួយខែក្រោយមក អង្គការមានផែនការបញ្ជូនយុវនារីទាំងអស់ឲ្យទៅធ្វើស្រែអំបិលវិញ ។ ទូច មិនត្រូវបានអនុញ្ញាតទៅធ្វើការនៅទីនោះទេ ព្រោះគាត់មានជំងឺដោយសារដើមឈើរលំសង្កត់ពីលើ ។ ទោះបីដឹងថាខ្លួនមិនអាចទៅបានក៏ដោយ ក៏ ទូច នៅតែទទូចសុំប្រធានទៅទីនោះដែរ ព្រោះគាត់មិនចង់នៅទីនេះហូបបបរទាំងព្រឹកទាំងល្ងាចដូច្នេះទេ ។

## ការងារនៅស្រែអំបិល

រថយន្តចំនួនបួនគ្រឿងបាននាំយុវនារីទាំងអស់ចេញពីមន្ទីរ ១៥០-ក ឆ្ពោះទៅកាន់ស្រែអំបិលនៅភូមិអង្កោល (បច្ចុប្បន្នសង្កាត់ភ្នំលាវទី២) ស្ថិតនៅក្នុងស្រុកកំពង់ត្រាច ខេត្តកំពត ។ ស្រែអំបិលនេះជាស្រែអំបិលភូមិភាគ ពីព្រោះថា ទិន្នផលអំបិលដែលប្រមូលបានមិនត្រូវបានចែកចាយទៅតំបន់ផ្សេងទេ ។ ទូច និងកម្មករចំនួន១០០នាក់ស្នាក់នៅក្នុងផ្ទះមួយដែលមានលក្ខណៈដូចជាឃ្លាំងស្តុកអំបិល ដែលស្ថិតនៅមិនឆ្ងាយពីកន្លែងធ្វើការ ។ កម្មករនៅទីនេះមានបួនកងធំៗ មួយកងមានសមាជិកប្រហែល១០០ នាក់ ជានារីនៅលីវនិងកងបុរសមានចំនួន២កង មានតួនាទីខាងបច្ចេកទេសកាន់ម៉ាស៊ីនបូមទឹក ។ ស្រែអំបិលនិងកម្មករទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមមិត្ត ជឿន ។ នៅក្នុងកងនីមួយៗមានបែងចែកជាកងឬក្រុមតូចៗទៀតដូចជា កងបង្ហាប់ដី កងវែកអំបិល និងកងអូសទឹកជាដើម ។ ទូច ស្ថិតនៅក្នុងកងបង្ហាប់ដី ដោយក្រុមរបស់គាត់មានតួនាទីបង្ហាប់ដីឲ្យហាប់មុនពេលបញ្ចូលទឹកបណ្តុះអំបិល ។ ការងារនេះពិបាកនិងត្រូវចំណាយពេលយូរក្នុងការបង្ហាប់ដីឲ្យរឹងល្អ ទោះជាយ៉ាងណាក៏មិនការស្តីបន្ទោសពីថ្នាក់លើដែរ ព្រោះអង្គការចង់បានអំបិលល្អនិងទទួលបានទិន្នផលច្រើន ។ ក្រៅពីការងារនេះ ទូច ត្រូវជួយធ្វើការស៊ើរតែដល់ភ្លឺជាមួយក្រុមធ្វើអំបិលថែមទៀត ដោយកើបអំបិលពីស្រែឲ្យអស់ដើម្បីកុំឲ្យត្រូវទឹកភ្លៀង ។ ទូច បានរៀបរាប់ថា «តែកាលណាមានផែនការឲ្យធ្វើគឺដូចគ្នា បើធ្វើមិនហើយថ្ងៃ យប់ឡើងត្រូវវែកអំបិលនោះទល់ភ្លឺ ។ គ្មានអ្នកណាម្នាក់ហ៊ានត្អូញត្អែរថាការងារយ៉ាប់ទេ» ។ ពេលធ្វើការចប់ កម្មករទាំងអស់អាចសម្រាកបានមួយព្រឹក ប្រសិនបើគ្មានការងារត្រូវធ្វើបន្តទេ ។ កម្មករអាចទៅដូតទឹកឈូនៅកំពតដោយរថយន្តដែលដឹកទៅម្តងមួយកងតូចចំនួន៣០ នាក់ទៅទីនោះ ចំណែកទឹកនៅស្រែអំបិលប្រើប្រាស់សម្រាប់តែដឹកនិងធ្វើម្ហូបប៉ុណ្ណោះ ។

នៅពេលប្រមូលទិន្នផលអំបិលដាក់ក្នុងឃ្លាំង ទូច តែងឃើញមានរថយន្តចូលមកដឹកចេញស្ទើររាល់ថ្ងៃ ប៉ុន្តែ ទូច មិនដឹងជាយកទៅកន្លែងណានោះទេ ។ «ខ្ញុំឃើញតែដញ្ជូនដាក់ឡានដាក់រទេះភ្លើងមកភ្នំពេញ រថយន្តនោះដាក់ផ្លាកថារថយន្តដឹកជញ្ជូន» ។

ទូច មិនសូវហ៊ាននិយាយលេង ឬចង់ដឹងពីការរស់នៅរបស់អ្នកផ្សេងដែលនៅក្នុងក្រុមជាមួយគ្នាឡើយ ព្រោះគាត់ធ្លាប់ឃើញគំរូអ្នកដែលចង់ដឹងរឿងរបស់អ្នកដទៃ តែងតែត្រូវអង្គការហៅទៅអប់រំតែមិនដែលត្រឡប់មកវិញឡើយ ។ លើសពីនេះទៀត ទូច ក៏បានឃើញកងឈ្លបបណ្តើរមនុស្សមួយក្រុមប្រហែលជា ១០-១៥ នាក់ចេញទៅ ហើយមួយរយៈក្រោយមកសម្លៀកបំពាក់របស់អ្នកទាំងនេះត្រូវបានយកមកចែកឲ្យពួកគាត់ប្រើវិញ ។ ពិតមែនតែការងារលំបាក ប៉ុន្តែកម្មករទាំងអស់បានរបបបាយជារៀងរាល់ថ្ងៃ លើកលែងតែថ្ងៃខ្វះខាតសេដ្ឋកិច្ចដឹកអង្ករទៅឲ្យមិនទាន់ទើបហូបបបរ ។ ក្នុងមួយសប្តាហ៍កម្មករទាំងអស់បានបន្ថែមហូបម្តង បន្ថែមពីលើនេះមានចែករបស់របរប្រើប្រាស់ដូចជាសម្លៀកបំពាក់និងក្រមាផងដែរ ។ ការងារស្រែអំបិលគឺអាចធ្វើបានតែខែប្រាំងប៉ុណ្ណោះ នៅរដូវវស្សាកម្មករទាំងអស់ត្រូវទៅធ្វើស្រែនៅកំពតដើម្បីប្រមូលស្រូវទុកផ្គត់ផ្គង់កម្មករនៅរដូវប្រាំងវិញ ។

ចាប់តាំងពីទៅធ្វើនៅទីនោះ ទូច បានជួបនិយាយជាមួយ អៀង សារី ជារដ្ឋមន្ត្រីក្រសួងការបរទេសម្តង ។ ទូច រំឭកថា មុនពេល អៀង សារី មកដល់ នារី ជឿន បានប្រាប់កម្មករនៅស្រែអំបិលឲ្យត្រៀមលក្ខណៈធ្វើការ ព្រោះអង្គការថ្នាក់លើនឹងមកទស្សនកិច្ចស្រែអំបិល ។ មិនយូរប៉ុន្មាន មានរថយន្តពីរគ្រឿងដែលមានយុទ្ធជនប្រដាប់អាវុធបើកអមដំណើររថយន្តរបស់ អៀង សារី ចូលមកដល់ការដ្ឋានស្រែអំបិល ។ ទូច រំឭកថា អៀង សារី បានដើរមកកន្លែងធ្វើការហើយសួរថា «ធ្វើស្រែអំបិលហ្នឹងរយៈពេលប៉ុន្មានថ្ងៃ និងបញ្ចូលទឹកប៉ុន្មានថ្ងៃទើបកើបអំបិល» ហើយគាត់បានត្រឹមតែនិយាយឆ្លើយឆ្លងទៅវិញថា «រយៈពេល ៣-៤ថ្ងៃអំបិលនឹងដុះ ដោយក្នុងអំឡុងពេលនេះអំបិលនៅខ្ចីក្រួសអំបិលអាចយកមកច្របាច់បែក បើទុករយៈពេលមួយសប្តាហ៍ទើបវាល្អ» ប៉ុន្តែមិនហ៊ានងើបមើលមុខ អៀង សារី ទេ ។

នៅក្នុងឆ្នាំ១៩៧៥ ក្រោយពីកងទ័ពខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង ទូច ត្រូវបានផ្លាស់ឲ្យទៅធ្វើស្រែអំបិលនៅកំពង់កណ្តាលដែលជាស្រែអំបិលរបស់រដ្ឋវិញ ។ ស្រែអំបិលនេះក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ជឿន ដែរ ។

ស្រែអំបិលរដ្ឋជាកន្លែងចែកចាយអំបិលធំជាងគេរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីប្រមូលផល រួចអំបិលទាំងអស់ត្រូវដឹកចែកចាយទៅតាមខេត្តនានានៅទូទាំងប្រទេស ។ ពេលទៅដល់ទីនោះ អង្គការបានចាត់តាំងឲ្យ ទូច ធ្វើជាប្រធានកងគ្រប់គ្រងសមាជិក៤០នាក់ ដែលមានប្រធានកងរយឈ្មោះ ខុន ជាអ្នកទទួលខុសត្រូវពីលើទៀត ។ កម្មករទាំងអស់ដែលនៅស្រែអំបិលភូមិភាគឬស្រែអំបិលរដ្ឋ គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតមកលេងផ្ទះទេ ។ ទូច ធ្លាប់បានសុំ ជឿន មកលេងផ្ទះម្តង ប៉ុន្តែសំណើរបស់គាត់ត្រូវបានបដិសេធដោយ ជឿន បានលើកហេតុផលថា «បើយើងមកម្នាក់សុំបាន អ្នកមកក្រោយក៏សុំបានដែរ» ។

## ការងារនៅរោងចក្របាវ

នៅឆ្នាំ១៩៧៧ អង្គការបានចម្រាញ់យកមនុស្សក្នុងមួយកងចំនួន៣ទៅ៤នាក់ដែលក្នុងចំណោមនោះមាន ទូច ម្នាក់ដែរ ដើម្បីបញ្ជូនឲ្យទៅធ្វើការនៅក្នុងរោងចក្របាវនៅខេត្តបាត់ដំបង ។ ទូច ត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានផ្នែកវេញអំបោះដំនួសអ្នកចាស់និងគ្រប់គ្រងសមាជិក៩០នាក់ ហើយ បូ ជាប្រធានរោងចក្រគ្រប់គ្រងទូទៅ ។ ក្នុងរយៈពេលពីរសប្តាហ៍ដំបូង ទូច ត្រូវបានកម្មករចាស់ៗបង្រៀនអំពីរបៀបប្រើប្រាស់ម៉ាស៊ីននិងកិច្ចការផ្សេងទៀតមុនផ្ទេរកិច្ចការនេះមកឲ្យគាត់ ។ ចំណែកកម្មករចាស់ៗក្រោយពីបង្ហាត់បង្រៀនចប់ ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅតាមសហករណ៍វិញ ។ ទូច ត្រូវធ្វើការតាំងពីព្រលឹមរហូតដល់ម៉ោង១០យប់ទើបអាចសម្រាកបាន ។ ពិតមែនតែធ្វើការច្រើនម៉ោង ប៉ុន្តែ ទូច មិនសូវលំបាកឬទទួលការកៀបសង្កត់ខ្លាំងពេកទេ ។ ទូច ទទួលរបបអាហារបាយមួយពេលនិងបបរមួយពេល ។ ក្រៅពីនេះ ទូច ក៏ត្រូវចូលរួមប្រជុំជាមួយប្រធានរោងចក្រដើម្បីរាយការណ៍អំពីការងារប្រចាំថ្ងៃ ថាតើវេញអំបោះបានប៉ុន្មានដុំក្នុងមួយថ្ងៃ និងខូចសម្ភារមួយចំនួនដែលនាំឲ្យមានការយឺតយ៉ាវដូចជាម៉ាស៊ីនដំណើរការមិនសូវល្អនិងអំបោះដុយជាដើម ។ ទូច គិតថានេះប្រហែលជាគាត់ធ្វើការងារល្អទើបបានកាន់តំណែងនេះ ។ អ្នកធ្វើការទីនេះភាគច្រើនគឺជានារីមានអាយុស្របាលនឹង ទូច ចំណែកប្រុសមានចំនួនតិច និងមានតួនាទីជាជាងម៉ាស៊ីន ។

## មន្ទីរ២០៤

មិនថាយុវជនឬយុវនារីដែលធ្លាប់តស៊ូរយៈពេលតិចឬច្រើនឆ្នាំដើម្បីបដិវត្តន៍ សុទ្ធតែប្រឹងប្រែងធ្វើការងារដោយមិនដែលហ៊ានត្អូញត្អែរថាការងារនោះលំបាកទេ ពោលគឺធ្វើយ៉ាងណាសម្រេចឲ្យបានតាមផែនការដែលអង្គការកំណត់ដើម្បីឲ្យអង្គការមានទំនុកចិត្ត និងរក្សាបាននូវសុវត្ថិភាពផ្ទាល់ខ្លួន ។ ទូច មិនដែលធ្លាប់គិតសោះថាខ្លួនបានប្រព្រឹត្តខុសឆ្គងចំពោះអង្គការឡើយ ព្រោះថាគាត់បានសម្រេចកិច្ចការគ្រប់បែបយ៉ាងជូនអង្គការ ។ ផ្ទុយពីការគិត ទូច បែរជាត្រូវអង្គការបញ្ជូនទៅមន្ទីរ២០៤ ជាកន្លែងសម្រាប់ដាក់អ្នកទោសដែលមានទីតាំងនៅក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ។ ទូច រំឭកថា ប្រហែលជាក្នុងឆ្នាំ១៩៧៨ នៅវេលាម៉ោងប្រហែល៤ទៀបភ្លឺ មានរថយន្តពីរគ្រឿងបានបើកចូលរោងចក្រ ហើយគាត់ចម្ងល់ចិត្តដែរថា តើហេតុអ្វីបានជារថយន្តបើកចូលមកទាំងយប់? លុះវេលាម៉ោង៧ព្រឹក និរសារស្រីរបស់ អ៊ិន ដែលជាប្រធានគ្រប់គ្រងផ្នែកនារីបានមកប្រាប់ឲ្យគាត់រៀបចំអីវ៉ាន់ព្រោះត្រូវបញ្ជូនទៅខាងភូមិភាគនិរតី ។ ក្រៅពី ទូច នៅមាន

នារីពីរនាក់ទៀតមកពីស្រែអំបិលជាមួយគ្នា ម្នាក់ឈ្មោះ រឿន ជាអ្នកស្រុកព្រៃកប្បាស និងម្នាក់ទៀតឈ្មោះ សឿន ជាអ្នកស្រុកកំពង់ស្ពឺ ។ ទូច ដឹងថាអ្នកដែលត្រូវបញ្ជូនទៅមន្ទីរ២០៤ សុទ្ធតែមានទោស ប៉ុន្តែ ទូច រកកំហុសខ្លួនឯងមិនឃើញទាល់តែសោះ ។ ទូច នៅចាំបានថា រថយន្តដែលដឹកអ្នកទោសនេះ មានឃ្មុបបិទជិត នៅក្នុងរថយន្តមានអ្នកទោសបុរស៤នាក់ចងស្លាបសេក ក្រៅពីនេះជាស្ត្រីប៉ុន្តែមិនមានចងស្លាបសេកទេ ។ អ្នកទោសម្នាក់ៗមានទឹកមុខក្រៀមក្រំនិងស្រងូតស្រងាត់ ចម្លែកតែ ទូច គ្មានតក់ស្លុតបន្តិចណាឡើយ ។ *«ប្រសិនបើខ្មែរក្រហមយកទៅសម្លាប់ អរជាងយកទៅដាក់គុក»* ។ *«ខ្ញុំឆ្អែតនឹងការតស៊ូដើម្បីបដិវត្តន៍ហើយ ព្រោះបានបែកពីឪពុកម្តាយនិងបងប្អូនតាំងពីអាយុ១៧ឆ្នាំ ខ្ញុំខំលះបង់ដើម្បីដើរតាមមាគ៌ារបស់អង្គការទីបំផុតបែរជាមានទោសទៅវិញ»* ។

ពេលរថយន្តបើកមកដល់ខេត្តកំពង់ឆ្នាំង សន្តិសុខការពារបានឲ្យឡានឈប់នៅព្រលានយន្តហោះកំពង់ឆ្នាំងបន្តិចដើម្បីឲ្យអ្នកទោសទាំងអស់រកកន្លែងបន្ទោរបង់ រួចរថយន្តបានបន្តដំណើរដល់មន្ទីរ២០៤ទាំងយប់ ។ មន្ទីរនេះគ្រប់គ្រងដោយឈ្មោះ ចឹក ។ អ្នកទោសទាំងអស់ត្រូវចុះពីលើរថយន្តទៅកន្លែងសម្រាកបណ្តោះអាសន្ន។ ព្រឹកឡើងអង្គការបានចែកកណ្តៀវឲ្យអ្នកទោសម្នាក់មួយទៅច្រូតស្រូវនៅក្នុងព្រៃជ្រៅ បោកបែនស្រូវនិងបុកចេញជាអង្ករសម្រាប់ផ្គត់ផ្គង់កងទ័ព ។ ទូច សម្គាល់ឃើញថាទោះបីជាធ្វើការនៅកន្លែងណាក៏ដោយសន្តិសុខមន្ទីរនៅតែដើរឃ្លាំមើលជានិច្ច ។ អ្នកទោសចាស់ៗដែលជាប់នៅក្នុងមន្ទីរនេះបាននិយាយប្រាប់គាត់ថា មន្ទីរនេះមានតាំងពីឆ្នាំ១៩៧០ ជាកន្លែងដាក់អ្នកទោស ហើយដើមដូងនិងដើមឈើផ្សេងទៀតដែលដុះនៅជុំវិញបរិវេណមន្ទីរលូតលាស់ល្អណាស់ដោយសារជីមនុស្ស ។ ថ្ងៃមួយ ទូច បានឃើញខ្មែរក្រហមបីបួននាក់ (ម្នាក់ដើរមុខ ម្នាក់ដើរកណ្តាល និងម្នាក់ទៀតដើរក្រោយ) បណ្តើរមនុស្សមួយខ្សែមានស្រី ប្រុស ចាស់និងកូនក្មេងដើរកាត់មុខមន្ទីរដើម្បីយកទៅសម្លាប់ ។

## ចម្ងល់គ្មានចម្លើយច្បាស់លាស់

ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេលជិត៣០ឆ្នាំហើយក៏ដោយ ប៉ុន្តែចម្ងល់ក្នុងចិត្តរបស់ ទូច នៅតែមិនអាចរកចម្លើយបាន។ ទូច បានរៀបរាប់ថា តាំងពីថ្ងៃចូលធ្វើបដិវត្តន៍ គាត់ខិតខំធ្វើអ្វីមិនឲ្យមានកំហុស ធ្វើតាមតែការដឹកនាំរបស់អង្គការ ហើយក៏មិនដែលតវ៉ាឬប្រកែកថាការងារនោះពិបាកទេ ។ នៅក្នុងក្រុមគ្រួសារឬសាច់ញាតិរបស់គាត់ក៏គ្មាននរណាជាមន្ត្រីរដ្ឋការឬជាទាហានពីជំនាន់មុនដែរ ។ ក្រោយពេលត្រឡប់មករស់នៅស្រុកកំណើតវិញ អ្នកនៅក្នុងភូមិបានប្រាប់ថា គណៈឃុំនិងគណៈស្រុកដែលបាននាំគាត់ចូលធ្វើបដិវត្តន៍ត្រូវខ្មែរក្រហមចាប់ខ្លួនបាត់អស់ហើយ ។ ទូច សន្និដ្ឋានថា គាត់ប្រហែលត្រូវចាប់ខ្លួនតាមខ្សែរយៈអ្នកទាំងអស់នេះហើយ ទោះយ៉ាងណានេះគ្រាន់តែជាផ្នែកមួយតូចដែលអាចដោះស្រាយចម្ងល់របស់គាត់ប៉ុណ្ណោះ ។

## ក្រោយបដិវត្តន៍ឆ្នាំ១៩៧៩

ក្រោយពីរបបនេះដួលរលំនៅឆ្នាំ១៩៧៩ ទូច និងអ្នកទោសទាំងអស់បន្តរស់នៅក្នុងមន្ទីរ២០៤អស់ជាច្រើនខែ ទម្រាំតែកងទ័ពវៀតណាមរំដោះបានទីតាំងនេះ ។ មេដឹកនាំមន្ទីររត់គេចខ្លួនបាត់ពេលកងទ័ពវៀតណាមចូលមក ចំណែកអ្នកទោសទាំងអស់បាននាំគ្នារត់មករកផ្ទះរៀងៗខ្លួន ។ ទូច ចង់វិលត្រឡប់មកផ្ទះវិញដូចអ្នកដទៃដែរ ប៉ុន្តែដោយសារតែបានឮពាក្យឃោសនាពីមាត់មួយទៅមាត់មួយថា អ្នកធ្លាប់ធ្វើខ្មែរក្រហម ប្រសិនបើកងទ័ពវៀតណាមចាប់បាននឹងត្រូវធ្វើបាប ។ ម្យ៉ាងទៀតដោយគាត់មានតែខ្លួនមួយ គាត់ក៏សម្រេចចិត្តរត់ឡើងភ្នំទាំងគ្មានកម្លាំងនៅក្នុងខ្លួន ព្រោះអាហារដែលអាចរកហូបបាននៅតាមផ្លូវមានតែត្លុកនិងដំឡូងប៉ុណ្ណោះ ។

នៅខែធ្នូ ឆ្នាំ១៩៧៩ ទូច ធ្វើដំណើរមកដល់ជំរំរបស់តា សឺន សាន ដែលមានទីតាំងនៅជាយដែនខ្មែរ-ថៃ ជំរំនេះមានជនភៀសខ្លួនប្រមាណជា៤ម៉ឺននាក់ក្រោមការជួយឧបត្ថម្ភពីបារាំងនិងថៃ។ បារាំងជាអ្នកជួយទំនុកបម្រុងអង្ករនិងម្ហូប ចំណែកថៃឧបត្ថម្ភថ្នាំពេទ្យ ។ ជំរំនេះមានទាំងអ្នកតស៊ូនិងប្រជាពលរដ្ឋសាមញ្ញ អ្នកទាំងអស់គ្នានេះគ្មាននរណាម្នាក់បានទទួលសិទ្ធិជ្រកកោននៅប្រទេសទីបីទេ ដោយសារថាជាជំរំអ្នកតស៊ូ ។ ការរស់នៅទីនេះដំបូង ទូច ជួបការលំបាកខ្លះដែរ ព្រោះត្រូវទៅកាប់ឬស្សីនិងឈើមកសង់ខ្ទមរស់នៅដោយខ្លួនឯង ។ ចំណែករបបអាហារវិញ បារាំងចែកឲ្យមានកំណត់ ពោលគឺមិនទាន់ឲ្យហូបមួយថ្ងៃបីពេលភ្លាមទេ ព្រោះខ្លាចឃ្លានពេក ហូបច្រើនបណ្តាលឲ្យហាល់ស្លាប់ ។

ដូចនេះ បារាំងចែកអង្ករមួយថ្ងៃមួយកំប៉ុងឲ្យដាំហូបទៅតាមផ្ទះ ។ មួយរយៈក្រោយមកទើបបារាំងចាប់ផ្តើមចែករបបឲ្យហូបជាធម្មតាវិញ មានអង្ករ ត្រីខ ខ្ទាញ់ និងបន្លែជាដើម ។ របបនេះបើកបានតែស្ត្រីប៉ុណ្ណោះ ចំណែកបុរសអាចទទួលរបបអង្ករបានលុះត្រាណាតែចូលធ្វើទាហាន ។ ប្រជាជនទាំងអស់គ្មានសិទ្ធិដើរហើរទៅកន្លែងណាឆ្ងាយពីជំរំទេ ។ ទូច មានភារកិច្ចជួយស្តាបនាផ្លូវថ្នល់ដឹកជញ្ជូនអង្ករមកចែកប្រជាជននិងកាប់ឈើធ្វើឃ្លាំង ។ នៅឆ្នាំ ១៩៨០ ទូច សម្រេចចិត្តរៀបការជាមួយបុរសម្នាក់ឈ្មោះ ខាន់ មាស ដើម្បីបានជួយមើលថែគ្នាទៅវិញទៅមក ។ អាពាហ៍ពិពាហ៍របស់អ្នកទាំងពីរមិនមានលក្ខណៈអឹកអធឹកទេ គឺគ្រាន់តែអញ្ជើញចាស់ទុំនៅក្នុងជំរំមកចូលរួមដើម្បីដឹងឮនិងកុំឲ្យខុសប្រពៃណីខ្មែរប៉ុណ្ណោះ ។ សំណាងអាក្រក់ នៅឆ្នាំ១៩៨៣ ប្តីរបស់ ទូច បានដើរជាន់មីនដែលខ្មែរក្រហមបានបង្កប់នៅក្នុងជំរំបណ្តាលឲ្យពិការជើងម្ខាង ដូច្នោះបន្ទុកគ្រួសារបានធ្លាក់មកលើ ទូច ទាំងស្រុង ។ នៅឆ្នាំ ១៩៨៧ ដោយជីវភាពខ្វះខាត ទូច ក៏បានស្ម័គ្រចិត្តចូលធ្វើការនៅពេទ្យជំរំផ្នែកគាំពារទារក ដោយទុកកូនៗឲ្យប្តីមើលថែជំនួស ។ ទូច អាចបំពេញការងារនេះបានក្រោមការបង្ហាត់បង្រៀនពីគ្រូពេទ្យជនជាតិបារាំងម្នាក់និងអ្នកបកប្រែភាសាម្នាក់ ។ ក្រោយមក ទូច បានផ្លាស់ទៅធ្វើការនៅអង្គការមួយទៀតដែលការងារនេះមិនមានប្រាក់ខែទេ តែទទួលការឧបត្ថម្ភជាអង្ករវិញ ។

នៅឆ្នាំ១៩៩២ ប្រជាជនដែលរស់នៅក្នុងជំរំទាំងអស់ត្រូវបានតម្រូវឲ្យធ្វើមាតុភូមិនិវត្តន៍ ។ ប្រជាជនមួយចំនួនដែលមានជីវភាពធូរធារមិនព្រមវិលត្រឡប់មកស្រុកកំណើតទេ ។ ជនភៀសខ្លួនត្រូវបានអាជ្ញាធរជំរំអនុញ្ញាតឲ្យវិលត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនប៉ុណ្ណោះ ហើយការធ្វើមាតុភូមិនិវត្តន៍តម្រូវឲ្យបំពេញសំណុំបែបបទផ្ញើទៅអាជ្ញាធរដើម្បីណាត់ថ្ងៃសម្ភាស ។ បទសម្ភាសន៍លើកទីមួយ ទូច បានដាក់ពាក្យសុំទៅរស់នៅខេត្តសៀមរាបដែលជាស្រុកកំណើតខាងប្តី ប៉ុន្តែការស្នើសុំនេះត្រូវអាជ្ញាធរបដិសេធ ដោយសារថា សៀមរាបជាខេត្តមួយមិនទាន់មានសុវត្ថិភាពពេញលេញនៅឡើយ ។ សម្ភាសន៍លើកទីពីរ អាជ្ញាធរអនុញ្ញាតដោយសារគាត់បានស្នើសុំត្រឡប់ទៅស្រុកកំណើតនៅស្រុកទ្រាំង ខេត្តតាកែវ ។ មុនពេលចាកចេញ អាជ្ញាធរជំរំបានចែកស្បៀងឲ្យដូចជារបបអង្ករ ត្រីខ និងខ្ទាញ់ខ្លះ ទុកសម្រាប់ហូបតាមផ្លូវរយៈពេលមួយខែ ។

ទូច សប្បាយចិត្តយ៉ាងខ្លាំងពេលមកដល់ភូមិកំណើតដែលស្ថិតនៅឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ជាទីកន្លែងតែមួយគត់ដែលផ្តល់នូវភាពសុខសាន្តសម្រាប់គាត់ ។ ទូច បានរៀបរាប់ថាការបដិវត្តន៍របស់គាត់បានត្រឹមតែការវិនាសព្រាត់ប្រាសគ្រួសារប៉ុណ្ណោះ ឪពុកម្តាយបានលាចាលោកដោយគាត់មិនបានជួបមុខជាលើកចុងក្រោយ ។ ចំណែកប្អូនដែលបានចូលបដិវត្តន៍បាត់ខ្លួនទៀត ហើយបងប្អូននៅក្នុងភូមិក៏គិតថា គាត់ស្លាប់បាត់ជីវិតនៅសម័យនោះដែរ ហើយថែមទាំងបានធ្វើបុណ្យឲ្យគាត់ទៀតផង ។ ទូច បានចាប់ផ្តើមកសាងជីវិតថ្មីនៅភូមិកំណើតរបស់ខ្លួនជាមួយនឹងធនធានតិចតួចបំផុតដែលសេសសល់កាលពីនៅជំរំ ។

ទូច សព្វថ្ងៃប្រកបមុខធ្វើស្រែនិងពេលទំនេរធ្វើពងលក់ ។ ទូច រស់នៅយ៉ាងសុខដុមជាមួយប្តីនិងកូនបីនាក់ ប៉ុន្តែអ្វីដែលគាត់នៅតែបារម្ភគឺសុខភាពប្តីរបស់គាត់ដែលមានជំងឺតគាណូសបន្សល់ទុកពីរបបខ្មែរក្រហម ។ ពេលជំងឺនេះធ្វើទុក្ខម្តងៗតែងតែធ្វើឲ្យរៀចមាត់និងទាញដៃជើង ។ ទូច សង្ឃឹមថា ប្តីរបស់គាត់នឹងបានធូរស្បើយពីជំងឺនេះបន្ទាប់ពីបានទៅចាក់ថ្នាំបង្ការគ្រប់ចំនួន ។ ទូច បានឲ្យដឹងទៀតថា ជីវភាពរបស់គាត់ក៏បានធូរធារនិងមានសេរីភាពជាងកាលដែលគាត់រស់នៅជំរំដោយសារកូនរបស់គាត់មានការងារធ្វើ ហើយបានផ្ញើលុយឲ្យគាត់ជារៀងរាល់ខែ គួបផ្សំនឹងប្រាក់បៀវត្សរ៍ទាហានរបស់ប្តីគាត់១០ម៉ឺនរៀលទៀតៗ ទូច បន្តថាអាចឲ្យគាត់ចង់ចេញទៅធ្វើស្រែពេលណាក៏បានមិនបាច់មានអ្នកត្រួតត្រាដូចសម័យខ្មែរក្រហមឡើយ ។

ទូច មានការយល់ដឹងច្រើនអំពីបញ្ហាសង្គម គាត់គិតថាការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមមានប្រយោជន៍ណាស់សម្រាប់ឲ្យជនល្មើសរាងចាលនិងកុំឲ្យរបបនេះកើតឡើងជាលើកទីពីរទៀត ហើយពិសេសដើម្បីស្វែងរកសុវត្ថិភាពជូនប្រជាជនផង ។ ទូច ជឿថា មានតែតុលាការពិសេសនេះទេ ដែលអាចរកយុត្តិធម៌ពិតប្រាកដជូនប្រជាជននិងជនរងគ្រោះដែលស្លាប់បាត់បង់ជីវិត ។

**គាត លក្ខិណា**

# គុកខ្មែរក្រហម

## ខេត្តសៀមរាប

### ស្រុកអង្គរជុំ

### ១) មន្ទីរសន្តិសុខទួលបុសព្រាល

មន្ទីរសន្តិសុខព្រៃបុសព្រាលខ្មែរក្រហមបង្កើតឡើងនៅឆ្នាំ១៩៧០ សម្រាប់ឃុំឃាំងអ្នកទោសជាទាហានរបបសាធារណរដ្ឋខ្មែរ ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅក្នុងព្រៃឫស្សីត្រពាំងល្បើក ស្ថិតនៅក្នុងឃុំនគរភាស ។ កាលពីជំនាន់ខ្មែរក្រហមមន្ទីរសន្តិសុខនេះស្ថិតនៅក្នុងទឹកដីស្រុកពួក ដែលមាន ពោត ចាន់ ជាប្រធានមន្ទីរសន្តិសុខនិងជាគណៈស្រុកពួកគ្រប់គ្រងពីឆ្នាំ១៩៧០ដល់១៩៧៥ ប៉ុន្តែបច្ចុប្បន្នស្ថិតនៅភូមិក្បាលចាម ឃុំចារឈូក ស្រុកអង្គរជុំ ខេត្តសៀមរាប ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៥ គណៈស្រុកថ្មីឈ្មោះ លក បេង បានមកកាន់តំណែងជំនួស ហើយបានផ្លាស់ប្តូរមន្ទីរសន្តិសុខពីព្រៃបុសព្រាលទៅកាន់ទីតាំងថ្មីនៅក្នុងបរិវេណអនុវិទ្យាល័យពួក បច្ចុប្បន្នត្រូវបានប្តូរឈ្មោះទៅជាមន្ទីរសន្តិសុខប្រចាំស្រុកពួកវិញ ។

នៅឆ្នាំ១៩៧៧ បន្ទាប់ពី លក បេង និងបក្ខពួកត្រូវអង្គការនាំយកទៅសម្លាប់ចោល ឈ្មោះ ស៊ុន និង វ៉ាន់ បានមកកាន់កាប់មន្ទីរសន្តិសុខនេះបន្តទៀតរហូតដល់ឆ្នាំ១៩៧៩ ។

### ស្រុកបន្ទាយស្រី

### ២) មន្ទីរសន្តិសុខវត្តត្បែង

វត្តត្បែងជាវត្តចំណាស់មួយស្ថិតនៅក្នុងភូមិវត្តឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប ។ វត្តត្បែងជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោសគ្រប់ប្រភេទកាលពីជំនាន់ខ្មែរក្រហម ។

ចាប់ពីឆ្នាំ១៩៧០មកដល់ឆ្នាំ១៩៧៥ វត្តត្បែងបានឃុំឃាំងឈ្លើយសឹកដែលចាប់យកមកពីសមរភូមិនានា ។ សាលាឆាន់ ព្រះវិហារ និងកុដិមួយចំនួនត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង ជារោងបាយនិងកន្លែងផលិតថ្នាំ ។

នៅឆ្នាំ១៩៧៥ មន្ទីរសន្តិសុខវត្តត្បែងនៅតែដំណើរការដដែល ព្រមទាំងបានបង្កើនការងារជាច្រើនបន្ថែមទៀត ដូចជាសិប្បកម្មដំដែក តម្បាញ ការដ្ឋាននិងកន្លែងកាត់ដេរ ។ ព្រះតេជគុណ អ៊ូម សឿន ព្រះជន្ម៧២ព្រះវស្សា ជាចៅអធិការវត្តត្បែងបានបញ្ជាក់ថា កងសន្តិសុខប្រចាំមន្ទីរចាប់ផ្តើមសម្លាប់អ្នកទោសតាំងពីចុងឆ្នាំ១៩៧៥ ព្រមទាំងបញ្ជូនអ្នកទោសថ្មីៗចូលមកថែមទៀត ។ ឡាយ កយ អាយុ៦៩ឆ្នាំ ជាប្រជាជនរស់នៅភូមិត្បែងកើត ឃុំត្បែងបានប្រាប់ថា បន្ទាប់ពីគាត់ត្រូវអង្គការដកតួនាទីជាប្រធានសហករណ៍ភ្នាម ការសម្លាប់និងការធ្វើទារុណកម្មបានកើនឡើងជាលំដាប់ ។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបណ្តើរប្រជាជនជម្លៀសជាច្រើននាក់មកកាន់មន្ទីរសន្តិសុខនេះ បន្ទាប់ពីធ្វើប្រវត្តិរូបរួច ។ ប្រជាជនទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យធ្វើដំណើរឆ្លងកាត់បរិវេណវត្តត្បែងឡើយ ។ កងសន្តិសុខក៏មិនអនុញ្ញាតឲ្យអ្នកទោសកម្រិតធ្ងន់ចេញក្រៅមន្ទីរឃុំឃាំងដែរ ។

ចាប់ពីឆ្នាំ១៩៧៧ ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តត្បែងបានកើនឡើងទ្វេដង ។ ប្រជាជនជម្លៀសទាំងអស់ត្រូវអង្គការកំណត់ឲ្យធ្វើប្រវត្តិរូបក្នុងគោលបំណងស៊ើបរកប្រជាជន



មន្ទីរសន្តិសុខវត្តត្បែង

ណាដែលមានជាប់សែស្រឡាយ ជាតិសាសន៍ផ្សេងៗ ឬនិន្នាការនយោបាយពីសង្គមចាស់ ដើម្បីបញ្ជូនទៅកាន់មន្ទីរសន្តិសុខវត្តត្បែង ។ ព្រះតេជគុណ អ៊ុម សឿន មានសង្ឃដីកាថា អ្នកទោសប្រហែល៤០នាក់ ត្រូវបានសម្លាប់នៅក្នុងបរិវេណវត្តត្បែងបន្ទាប់ពីបានឃុំឃាំងមួយរយៈមក ។ ការសម្លាប់នេះភាគច្រើនបានប្រព្រឹត្តទៅនៅពេលទៀបភ្លឺ ។ ឡាយ កយ និយាយថា និល អតីតមនុស្សជំនិតរបស់គណៈស្រុកបន្ទាយស្រីឈ្មោះ ម៉ុន គឺជាជនដៃដល់ម្នាក់ដែលបានសម្លាប់អ្នកទោសអស់យ៉ាងច្រើន ។

## ស្រុកជីក្រែង

### ៣) មន្ទីរសន្តិសុខវត្តគីរីនន



មន្ទីរសន្តិសុខវត្តគីរីនន

វត្តគីរីនន ដែលមានទីតាំងនៅក្នុងភូមិម្កាក់ ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខកាលពីជំនាន់ខ្មែរក្រហម ។ ព្រះវិហារបានក្លាយទៅជាមន្ទីរឃុំឃាំង និងកន្លែងដទៃទៀតក្លាយជាឃ្លាំងស្តុកស្បៀងអាហារនិងសម្ភារៈ ។ នៅចន្លោះឆ្នាំ១៩៧៧ដល់ឆ្នាំ១៩៧៨ វ៉ាន់ ដែលជាប្រធានសន្តិសុខបានបញ្ជាឲ្យកងសន្តិសុខរបស់ខ្លួននាំអ្នកទោសយកទៅសម្លាប់ចោល ។ អ្នកទោសខ្លះត្រូវបានសម្លាប់នៅទីលានបោកបែនស្រូវនិងជង្រុកស្រូវដែលស្ថិតនៅក្នុងបរិវេណវត្តគីរីននេះដែរ និងមួយចំនួនត្រូវនាំយកទៅសម្លាប់នៅត្រពាំងក្រូស ភូមិត្រពាំងវែងនិងក្នុងព្រៃត្រាច ។ ចិន វិន បានអះអាងថា ក្នុងចំណោមអ្នកទោសចំនួនប្រហែលពី២០០ទៅ៣០០នាក់នៅមន្ទីរសន្តិសុខវត្តគីរីនន ភាគច្រើនបំផុតជាប្រជាជនដែលធ្វើការបះបោរប្រឆាំងនឹងការធ្វើការងារហួសកម្លាំង ។

## ស្រុកក្រឡាញ់

### ៤) មន្ទីរសន្តិសុខក្រឡាញ់

រោងវែងៗពីរខ្នង ផ្ទះមួយខ្នងសម្រាប់គណៈស្រុកក្រឡាញ់ស្នាក់នៅ និងផ្ទះពីរខ្នងទៀតដែលនៅក្បែរនោះ ត្រូវខ្មែរក្រហមជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខប្រចាំស្រុកក្រឡាញ់ ។ អ្នកទោសដែលជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខនេះមានបែងចែងអ្នកទោសកម្រិតធ្ងន់និងអ្នកទោសកម្រិតស្រាល ។ រោងវែងៗពីរខ្នងជាកន្លែងឃុំឃាំងអ្នកទោសកម្រិតធ្ងន់ រីឯផ្ទះពីរ-បីខ្នងទៀត គឺសម្រាប់ដាក់អ្នកទោសកម្រិតស្រាល ។ អ្នកទោសកម្រិតធ្ងន់មានការយាមកាមតឹងរឹងជាងអ្នកទោសកម្រិតស្រាល ។ ប៉ុន្តែអ្នកទោសស្រាលត្រូវបានដាក់ខ្នោះជើងជាមួយនឹងរនងដែកវែងៗឲ្យនៅតែលើផ្ទះ ។ វ៉ន សុភី អាយុ៣៩ឆ្នាំ រស់នៅក្នុងឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ជាអតីតអ្នកទោសកម្រិតស្រាលបានប្រាប់ថា ទោសកំហុសពុំមានអ្វីធំដុំទេ គឺគ្រាន់តែមានកំហុសបន្តិចបន្តួចក្នុងការធ្វើពលកម្ម ឬការលួចនេះលួចនោះប៉ុណ្ណោះ ។ សុភី ត្រូវកងឈ្លបនាំខ្លួនមកកាន់មន្ទីរសន្តិសុខស្រុកក្រឡាញ់ ដោយសារគាត់ច្រឡំពាក់ខោក្រវាត់ប្រធានកងរបស់គាត់នៅពេលឡើងពីងូតទឹកស្ទឹងវិញ ។ បន្ទាប់ពីជាប់ឃុំឃាំងមួយរយៈពេលខ្លី គាត់ត្រូវអង្គការបញ្ជូនឲ្យទៅធ្វើការនៅក្នុងការដ្ឋានលើកទំនប់និងរែកដីវិញ ។ ប៉ុន្តែនៅអំឡុងពេលនោះ សុភី ប្រទះឃើញសកម្មភាពធ្វើទារុណកម្មនិងសម្លាប់អ្នកទោសកម្រិតធ្ងន់ផ្ទាល់ភ្នែកនិងបានឮសូរសំឡេងអ្នកទោសស្រែកស្ទើរតែរាល់ថ្ងៃ ។

ចិ វ៉ាន់ថន អាយុ៤៣ឆ្នាំ បច្ចុប្បន្នរស់នៅភូមិកំពង់ថ្កូវ ឃុំកំពង់ថ្កូវ ជាអ្នកទោសកម្រិតធ្ងន់នៅមន្ទីរសន្តិសុខនេះបានរួចខ្លួនពីការសម្លាប់ដោយសារថ្ងៃរំដោះទី៧ មករាឆ្នាំ១៩៧៩ ។ វ៉ាន់ថន ត្រូវកងឈ្លបចាប់ខ្លួនដោយចោទថា បានលួចផ្តល់ស្បៀងអាហារឲ្យខ្មាំង ហើយមិនព្រមរៀបការតាមការស្នើសុំរបស់អង្គការ ។

នៅក្រោយឆ្នាំ១៩៧៩ មន្ទីរសន្តិសុខប្រចាំស្រុកក្រឡាញ់ត្រូវរដ្ឋអំណាចរំលាយចោល ហើយផ្ទះពីរ-បីខ្នងដែលជាអតីតមន្ទីរឃុំឃាំងអ្នកទោសកម្រិតស្រាល ត្រូវម្ចាស់ដើមត្រឡប់មកគ្រប់គ្រងឡើងវិញ ។ ថោង មឿយ ដែលជាម្ចាស់ផ្ទះម្នាក់ក្នុង

ចំណោមនោះបាននិយាយប្រាប់ថានៅលើផ្ទះមានបន្សល់ទុកស្លាក ស្នាមនិងខ្នោះដើងមួយឡាំង ។ នៅពេលក្រោយមកខ្នោះទាំងនោះ ត្រូវប្រជាជនយកគ្រវាត់ចោលអស់ ។ ក្រៅពីនោះ នៅមានដីមួយ ពំនូកដែលនៅសេសសល់ពីការដុតសាកសពមនុស្សនិងអង្កាម ។ ពំនូកដីនេះ ត្រូវប្រជាជនយកប្រើប្រាស់ដាក់ស្រែក្រុមសាមគ្គី ក្រោយថ្ងៃរំដោះ ឆ្នាំ១៩៧៩ ។

មឿយ បានយករនងដែលនៅសេសសល់នៅលើផ្ទះរបស់ គាត់យកមកប្រើប្រាស់ខ្វាស់ទ្វាររហូតដល់សព្វថ្ងៃ ។ មឿយ បញ្ជាក់ថា គាត់មិនទាន់ហ៊ានឡើងទៅស្នាក់នៅលើផ្ទះរបស់គាត់ ភ្លាមៗទេ ព្រោះមានសាកសពស្អុយរលួយនៅខាងលើនោះ ហើយ នៅតាមចន្លោះក្តារក្រាលសម្បូរសត្វសង្កើចនិងសត្វល្អិតផ្សេងៗ ។

## ស្រុកពួក

### ៥) មន្ទីរសន្តិសុខកោះថ្មី

កោះថ្មី ស្ថិតនៅភូមិគោកថ្មីខាងជើង ឃុំពួក ស្រុកពួក ខេត្ត សៀមរាប ។ ផ្ទះរបស់ សាត ពី ដែលនៅជាន់ក្រោមសាងសង់ពី បេតុងនិងឈើ នៅជាន់លើបានក្លាយជាមន្ទីរសន្តិសុខរបស់ខ្មែរ ក្រហម ។ មានអ្នកទោសជាច្រើនជាប់ឃុំឃាំងនៅក្នុងនោះ ។ ក្រោយឆ្នាំ១៩៧៩ អ្នកទោសមួយចំនួនត្រូវកងឈ្លបសម្លាប់ ហើយមួយចំនួនទៀតបានរួចរស់ជីវិត ។ សាត ពី អាយុ៥៨ឆ្នាំ ភេទស្រី និង ឈឿន ហ៊ុម អាយុ៥៥ឆ្នាំ ភេទប្រុស ដែលរស់នៅ ភូមិគោកថ្មី ឃុំពួក ស្រុកពួក បាននិយាយថា ខ្មែរក្រហមបានសម្លាប់ អ្នកទោសនៅទីតាំងមួយចម្ងាយប្រហែល៥០ម៉ែត្រពីមន្ទីរសន្តិសុខ ។ សាកសពស្ទើរតែទាំងអស់ត្រូវកងសន្តិសុខកាប់ចិញ្ច្រាំលាយជាមួយ នឹងដើមរុក្ខជាតិ ហើយដុតធ្វើជាជីសម្រាប់ដាក់ស្រែនិងដំណាំ ផ្សេងទៀត ។

## ស្រុកប្រាសាទបាគង

### ៦) មន្ទីរសន្តិសុខវត្តខ្សាច់

វត្តសុវណ្ណបុប្ផារាម ហៅវត្តខ្សាច់ មានទីតាំងនៅក្នុងភូមិ រកាកំបុត ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ខេត្តសៀមរាប ។ វត្តនេះគឺជាមន្ទីរសន្តិសុខបណ្តោះអាសន្នមួយដែលមានឃុំឃាំង អ្នកទោសជាច្រើន ។ ព្រះតេជគុណព្រះនាម គីវ ឆាយ ព្រះជន្ម ៥៦ព្រះវស្សា គង់នៅវត្តខ្សាច់ បានមានសង្ឃដីកាថា អ្នកទោស ត្រូវកងសន្តិសុខនាំយកមកដាក់ឃុំឃាំងនៅក្នុងសាលារៀនមួយ ខ្នងស្ថិតនៅក្នុងបរិវេណវត្តខ្សាច់ ប៉ុន្តែក្រោយមកអ្នកទោសបាននាំ គ្នាវាយទម្លុះជញ្ជាំងនិងបន្ទួចរត់ចេញ ប៉ុន្តែមានអ្នកទោស១២នាក់ ត្រូវកងឈ្លបចាប់ខ្លួនបាន ហើយនាំយកទៅសម្លាប់ចោលនៅក្នុង អណ្តូងទឹកមួយស្ថិតនៅក្នុងបរិវេណវត្តខ្សាច់ដែរ ។

ព្រះតេជគុណ គីវ ឆាយ បានមានសង្ឃដីកាបន្តថា នៅ ក្រោយឆ្នាំ១៩៧៩ ពេលមកបួសជាសង្ឃមុនគេនៅវត្តខ្សាច់នេះ ព្រះតេជគុណបានឃើញប្រជាជនជីកស្តារអណ្តូងរួច ទាញយក សាកសពទាំង១២នាក់នោះមកធ្វើបុណ្យតាមប្រពៃណី ព្រមទាំង តម្កល់អដ្ឋិធាតុយ៉ាងត្រឹមត្រូវក្នុងចេតិយមួយសម្រាប់ឲ្យក្រុម គ្រួសារមកគោរពវិញ្ញាណក្ខន្ធ ។

### ៧) មន្ទីរសន្តិសុខវត្តលលៃ

មន្ទីរសន្តិសុខវត្តលលៃ ស្ថិតនៅភូមិលលៃ ឃុំបាគង ស្រុក ប្រាសាទបាគង ខេត្តសៀមរាប ត្រូវអង្គការបដិវត្តន៍បង្កើតឡើង សម្រាប់ឃុំឃាំងអ្នកទោសបណ្តោះអាសន្នមួយរយៈមុននឹងបញ្ជូន ទៅសម្លាប់ចោលនៅទីតាំងសម្លាប់ទួលតាកែ គោកតាមុំ និងខាង លិចវត្តលលៃ ។

## ស្រុកសៀមរាប

### ៨) មន្ទីរសន្តិសុខវត្តអដ្ឋិការាម

វត្តអដ្ឋិការាម ហៅវត្តថ្មី ស្ថិតនៅក្នុងភូមិត្រពាំងសេះ ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ។ នៅឆ្នាំ១៩៩៥ ប្រជាជនបានចាប់ផ្តើមជួលជុលវត្តអដ្ឋិការាមជាថ្មីឡើងវិញ ។ ប៉ុន្តែរណ្តៅសាកសពធំៗចំនួន២កន្លែង ព្រមទាំងអណ្តូងជាច្រើន នៅជិតកុដិដែលព្រះសង្ឃគង់នៅរាល់ថ្ងៃ នៅតែមិនទាន់បានគាស់ នៅឡើយ ។

### ៩) វិទ្យាល័យសៀមរាប

ឯកសារណសិទ្ធរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានបញ្ជាក់ច្បាស់ថា វិទ្យាល័យសៀមរាបគឺជាអតីតមន្ទីរសន្តិសុខ របស់ខ្មែរក្រហម ។ ក្នុងចំណោមអគារទាំងប៉ុន្មានរបស់វិទ្យាល័យ នេះមានមួយចំនួនត្រូវបានបំផ្លាញ ។ នួន ថុក និង ស៊ុំ ឫទ្ធី បានធ្វើ សម្ភាសន៍ជាមួយក្រុមស្រាវជ្រាវឈ្មោះ សែស ឈន និង សាង នីម ដែលជាកម្មាភិបាលក្រសួងមហាផ្ទៃនៃរបបសាធារណរដ្ឋ

ប្រជាមានិតកម្ពុជា ស្តីពីមន្ទីរសន្តិសុខនៅវិទ្យាល័យសៀមរាប និងទីតាំងសម្លាប់ជាច្រើនទៀតនៅជុំវិញបរិវេណមន្ទីរសន្តិសុខនេះ ។ វិទ្យាល័យសៀមរាប មានទីតាំងស្ថិតនៅចម្ងាយប្រហែល៥០០ ម៉ែត្រពីទីរួមខេត្តសៀមរាបប៉ែកខាងទិសឦសាន ។

ហឿន ដឿម បាននិយាយថា វិទ្យាល័យសៀមរាប ត្រូវខ្មែរក្រហមប្រើប្រាស់ជាមន្ទីរសន្តិសុខ ហើយមានអ្នកទោសដែលជាអ្នកជាប់ពាក់ពន្ធ័នឹងរបបលន់នល់ ប្រហែល២៨៨នាក់បានជាប់នៅទីនោះ ហើយក្រោយមកត្រូវកងសន្តិសុខសម្លាប់ចោលទាំងអស់ ។

### ១០) មន្ទីរសន្តិសុខវត្តធម្មយុត្តិ

វត្តធម្មយុត្តិ ស្ថិតនៅក្នុងភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។ ចៅអធិការវត្តធម្មយុត្តិព្រះនាម ពុក ពុន បានមានសង្ឃដីកាថា កុដិនានាត្រូវកងសន្តិសុខប្រើធ្វើជាកន្លែងសួរចម្លើយ ហើយព្រះវិហារធ្វើជាកន្លែងឃុំឃាំង ។

## ស្រុកសូទ្រនិគម

### ១១) មន្ទីរសន្តិសុខវត្តតាយ៉ែក

វត្តតាយ៉ែក ស្ថិតនៅក្នុងភូមិតាយ៉ែក ឃុំតាយ៉ែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ កាលពីជំនាន់ខ្មែរក្រហម វត្តតាយ៉ែកគឺជាមន្ទីរសន្តិសុខដែលមានឃុំឃាំងជនរងគ្រោះជាប្រជាជន១៧មេសា និងប្រជាជនមូលដ្ឋានដែលប្រព្រឹត្តខុសឆ្គងចំពោះអង្គការនិងអ្នកដែលមានជាប់ពាក់ព័ន្ធនិន្នាការនយោបាយពីសង្គមចាស់យ៉ាងច្រើន ។ ខ្មែរក្រហមបានយកព្រះវិហារធ្វើកន្លែងឃុំឃាំងនិងសួរចម្លើយ ។ ជញ្ជាំងខាងក្នុងព្រះវិហារនៅមានស្នាមឈាមនៅឡើយ ។



មន្ទីរសន្តិសុខវត្តតាយ៉ែក

## ស្រុកវ៉ារិន

### ១២) មន្ទីរសន្តិសុខគោកគាយា

បច្ចុប្បន្នព្រៃគោកគាយា ជាព្រៃស្វាត់ជ្រងំមួយស្ថិតនៅក្នុងភូមិស្វាយស ឃុំស្វាយស ស្រុកវ៉ារិន ខេត្តសៀមរាប ហើយនៅអែបនឹងព្រៃធំនេះមានទីបញ្ជាការទាហានមួយប្រចាំស្រុកវ៉ារិន ។ កាលពីជំនាន់ខ្មែរក្រហម ព្រៃគោកគាយាត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខ មន្ទីរពេទ្យ ការដ្ឋាន រោងសិប្បកម្ម កន្លែងផ្តល់ស្បៀងនិងរោងម៉ាស៊ីនកិនស្រូវ ។ នៅក្រោយឆ្នាំ១៩៧៩ ទីតាំងទាំងនោះត្រូវប្រជាជនដែលរស់នៅក្បែរៗនោះរុះរើគ្មានសល់ ។

### ១៣) មន្ទីរសន្តិសុខវត្តស្វាយស

វត្តស្វាយស ឬវត្តចន្ទរង្សីស្វាយស ជាវត្តមួយដែលខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខ និងជាមន្ទីរពេទ្យ បន្ទាប់ពីបណ្តេញព្រះសង្ឃគ្រប់អង្គនិងពុទ្ធបរិសទ័ចំណុះជើងវត្តទាំងអស់ឲ្យចេញទៅរស់នៅកន្លែងឆ្ងាយៗពីបរិវេណវត្ត ។ កុដិទាំងឡាយដែលស្ថិតនៅក្នុងទីធ្លាវត្តស្វាយស ត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរព្យាបាលអ្នកជំងឺ ។ ចំណែកព្រះវិហារធ្វើជាឃ្លាំងស្តុកថ្នាំដែលផលិតឡើងដោយមនុស្សចំណាស់ៗក្នុងភូមិ ។ សាលារៀនមួយខ្នងទៀតក៏ត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាកន្លែងឃុំឃាំងប្រជាជនជម្លៀសជាបណ្តោះអាសន្ន ដែលត្រូវអង្គការចោទប្រកាន់ថាមានជាប់និន្នាការនយោបាយពីសង្គមមុននិងប្រជាជនមូលដ្ឋានមួយចំនួនដែលខ្ជិលច្រអូសនឹងការងារ មុននឹងបញ្ជូនទៅកាន់មន្ទីរសន្តិសុខនៅគោកគាយា ។ រយៈពេលឃុំឃាំងត្រឹមតែ៣ថ្ងៃឬ៤ថ្ងៃប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៦ អ្នកទោសភាគច្រើនត្រូវកងសន្តិសុខបញ្ជូនចេញពីមន្ទីរសន្តិសុខវត្តស្វាយសទៅកាន់មន្ទីរសន្តិសុខគោកគាយា ហើយក្នុងចំណោមនោះភាគច្រើនត្រូវបានកងសន្តិសុខនាំយកទៅសម្លាប់នៅក្នុងព្រៃក្បែរៗនោះ ។

**ផេង ពង្សរ៉ាស៊ី**

# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## ជំពូកទី៧
## ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### ១) *ការបង្កើតសហករណ៍*

ក្នុងអំឡុងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០-១៩៧៥ ប្រជាជនភាគច្រើនដែលរស់នៅតាមតំបន់រំដោះរបស់ខ្មែរក្រហមត្រូវបានរៀបចំឲ្យទៅជា «ក្រុមប្រវាស់ដៃ» ដែលមានសមាជិកពី១០ទៅ៣០គ្រួសារក្នុងមួយក្រុម ។ ទោះជាយ៉ាងនេះក្តី ចាប់ពីឆ្នាំ១៩៧៣ និងជាពិសេសបន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៥ ក្រុមប្រវាស់ដៃត្រូវបានរៀបចំឲ្យទៅជា «សហករណ៍កម្រិតទាប» ដែលមានសមាជិកបី-បួនរយនាក់ ឬក៏ភូមិមួយទាំងមូល ។ រហូតដល់ឆ្នាំ១៩៧៧ សហករណ៍កម្រិតទាបត្រូវបានរៀបចំឡើងវិញឲ្យទៅជា «សហករណ៍កម្រិតខ្ពស់» ដែលរួមមានមួយពាន់គ្រួសារក្នុងសហករណ៍នីមួយៗ ឬក៏ឃុំមួយទាំងមូល ។

មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតសហករណ៍ទាំងនេះឡើងដែលជាផ្នែកមួយនៃដំណើររបស់ខ្លួនឆ្ពោះទៅរកការលុបបំបាត់ចោលកម្មសិទ្ធិឯកជននិងរបបមូលធននិយម និងដើម្បីពង្រីកវណ្ណៈកម្មករនិងកសិករ ។ ចំពោះខ្មែរក្រហម សហករណ៍មានន័យថាប្រជាជនរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា ហូបជាមួយគ្នា និងចែករំលែកការកម្សាន្តជាសមូហភាព ។ គោលការណ៍នេះធ្វើឲ្យមានការដាក់កំហិតយ៉ាងតឹងរ៉ឹងទៅលើការរស់នៅជាបុគ្គល ។ គ្រួសារខ្មែរធ្លាប់រស់នៅ ហូបចុកជួបជុំគ្នារាប់ពាន់ឆ្នាំមកហើយ ដូច្នេះការបង្ខំប្រជាជនឲ្យហូបរួមគ្នានៅក្នុងសហករណ៍ ជាពិសេសនៅពេលដែលមានការខ្វះខាតអាហារយ៉ាងខ្លាំងបែបនេះ គឺជាទង្វើមួយឃោរឃៅខ្លាំងណាស់ ។ ជាងនេះទៅទៀត ប្រជាជនត្រូវប្រគល់ទ្រព្យសម្បត្តិរបស់ខ្លួន ដែលជាមធ្យោបាយផលិតកម្មសំខាន់ៗដាក់ជាសម្បត្តិរួមរបស់សហករណ៍ទាំងអស់ដែលមានដូចជាឧបករណ៍ប្រើប្រាស់ គោក្របី នង្គ័ល រនាស់ គ្រាប់ពូជ និងដីស្រែជាដើម ។

សហករណ៍ត្រូវបានរៀបចំឡើងដើម្បីធ្វើយ៉ាងណាអាចឲ្យខ្លួនឧបត្ថម្ភខ្លួនដោយខ្លួនឯងបាន ។ មេដឹកនាំខ្មែរក្រហមបានពណ៌នាសហករណ៍ថាជា «កម្លាំងធំធេងខ្លាំងក្លា» ក្នុងការកសាងប្រទេសនិងជា «កំផែងថែបយ៉ាងរឹងមាំបំផុត» សម្រាប់ការពារកម្ពុជាប្រជាធិបតេយ្យទប់ទល់នឹងសត្រូវ ។

### ២) *វណ្ណៈសង្គមថ្មីពីរ*

ទោះជាខ្មែរក្រហមបានអះអាងថា ខ្លួនកំពុងតែកសាងប្រទេសមួយប្រកបដោយសមភាពនិងលុបបំបាត់ចោលវណ្ណៈសង្គមយ៉ាងណាក៏ដោយ ប៉ុន្តែធាតុពិតខ្មែរក្រហមបានបង្កើតឡើងនូវវណ្ណៈថ្មីពីរនៅក្នុងប្រទេសគឺ «ប្រជាជនមូលដ្ឋាន» និង «ប្រជាជនថ្មី» ។

***ប្រជាជនមូលដ្ឋាន*** ឬប្រជាជនចាស់គឺអ្នកទាំងឡាយណាដែលរស់នៅតាមតំបន់ជនបទ គ្រប់គ្រងដោយបក្សកុម្មុយនីស្តកម្ពុជា



នារីសិល្បៈខ្មែរក្រហម

មុនថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្មែរក្រហមបានបែងចែកអ្នកទាំងនេះជាប្រជាជនពេញសិទ្ធិឬប្រជាជនត្រៀម ។ ប្រជាជនពេញសិទ្ធិគឺអ្នកទាំងឡាយណាដែលមិនមានបងប្អូនធ្លាប់ធ្វើការក្នុងរបបសាធារណរដ្ឋខ្មែរ ហើយជាសមាជិកគ្រួសារកសិករក្រ ឬកសិករកណ្តាលថ្នាក់ក្រោម(កសិករនិងកម្មករ) ។ ប្រជាជនប្រភេទនេះត្រូវបានអនុញ្ញាតឲ្យទៅបោះឆ្នោត ឬឈរឈ្មោះឲ្យគេបោះឆ្នោត ទោះបីជាការបោះឆ្នោតមានតែម្តងគត់នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៦ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យក៏ដោយ ។ (ការបោះឆ្នោតនេះមិនអនុលោមតាមបទដ្ឋានអន្តរជាតិ ហើយឈ្មោះសមាជិកសភាតំណាងប្រជាជនក៏មិនត្រូវបានប្រកាសឲ្យប្រជាជនដឹងដែរ) ។ ប្រជាជនមូលដ្ឋានអាចក្លាយជាប្រធានសហករណ៍និងប្រធានកងផ្សេងៗ ។ ប្រជាជនត្រៀមគឺអ្នកទាំងឡាយដែលមានបងប្អូនធ្លាប់ធ្វើការជាមួយរបបសាធារណរដ្ឋខ្មែរ ។ ប្រជាជនទាំងនេះនឹងត្រូវបានគ្រាប្រណី ដរាបណាប្រជាជនទាំងអស់នោះខិតខំធ្វើការងារដោយខ្ជាប់ខ្ជួន ។

**ប្រជាជនថ្មី** ឬប្រជាជន១៧មេសាគឺអ្នកដែលត្រូវជម្លៀសចេញពីទីក្រុង ឬទីប្រជុំជននានានៅខែមេសា ឆ្នាំ១៩៧៥ ។ ទោះជាយ៉ាងនេះក្តី មួយចំនួនធំនៃអ្នកទាំងនេះគឺជាអ្នកមកពីជនបទ ហើយបានរត់ទៅទីក្រុងដើម្បីគេចពីសង្គ្រាម ។ ប្រជាជនថ្មីត្រូវបានចាត់ទុកថាជាមនុស្សដែលមិនអាចជឿទុកចិត្តបាន ហើយទទួលការស្អប់ខ្ពើមនិងការសង្ស័យពីសំណាក់អង្គការ ។ ប្រជាជនទាំងនេះត្រូវបានអង្គការចាត់ទុកថាជា“ជនបញ្ញើក្អែក” ហើយគ្មានសិទ្ធិអ្វីទាំងអស់ដូចដែលពាក្យស្លោកខ្មែរក្រហមមួយបានអះអាងថា “ពួក១៧មេសាជាជនបញ្ញើក្អែក ។ ពួកវាជាអ្នកចាញ់សង្គ្រាមនិងជាឈ្លើយសឹក” ។ ពាក្យស្លោកមួយទៀតដែលអ្នករស់រានមានជីវិតភាគច្រើនចងចាំនោះគឺ “ទុកក៏មិនចំណេញ ដកចេញក៏មិនខាត” ។ ប្រជាជនថ្មីទទួលរងការធ្វើទុកបុកម្នេញខ្លាំងជាងប្រជាជនចាស់ ។ ប៉ុន្តែទំហំនៃអំពើឃោរឃៅមានកម្រិតខុសៗគ្នាពីតំបន់មួយទៅតំបន់មួយទៀត ។ ឧទាហរណ៍ ប្រជាជននៅខេត្តស្វាយរៀងនិងព្រៃវែងក្នុងភូមិភាគបូព៌ា បានទទួលការគាំពារពីបដិវត្តន៍ប្រសើរជាងអ្នកដែលត្រូវបានជម្លៀសទៅខេត្តពោធិសាត់និងបាត់ដំបងនៃភូមិភាគពាយ័ព្យ ។

ចាប ស៊ីថា អាយុ៦៥ឆ្នាំ រស់នៅទីក្រុងភ្នំពេញបានរៀបរាប់ពីជីវិតរបស់គាត់ដែលកាលណោះជាអ្នក១៧ មេសាថាៈ នៅពេលជម្លៀសឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំដែលមានសមាជិកទាំងអស់១៨នាក់ត្រូវបានជម្លៀសទៅរស់នៅស្រុកកោះធំ ខេត្តកណ្តាល ។ នៅទីនោះ អង្គការចាត់តាំងឲ្យដាំបន្លែបង្ការ និងធ្វើស្រែ ។ ថ្ងៃមួយវេលាម៉ោងប្រាំបួនយប់ ប្តីរបស់ខ្ញុំត្រូវអង្គការស្នើឲ្យទៅរៀនសូត្រមួយរយៈ ។ ខ្ញុំរង់ចាំប្តីខ្ញុំ ប៉ុន្តែមិនឃើញគាត់ត្រឡប់មកវិញសោះ ។ ស្ត្រីម្នាក់នៅក្នុងភូមិបានប្រាប់កូនរបស់ខ្ញុំម្នាក់ថា “មិនចាំបាច់មើលផ្លូវឪពុកឯងទេ ហើយប្រយ័ត្នប្រយែងមាត់ផង កុំនិយាយអ្វីផ្តេសផ្តាសឲ្យសោះ ប្រយ័ត្នគេយកទៅមួយពូជ ព្រោះឪពុកឯងមានប្រវត្តិធំណាស់” ។ ខ្ញុំដឹងថាអង្គការបានយកប្តីខ្ញុំទៅសម្លាប់ចោល ព្រោះគាត់ជាអតីតចៅហ្វាយខេត្តកណ្តាល ។ ពីរខែក្រោយមក អង្គការបានប្រាប់ខ្ញុំឲ្យផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ។ តាមពិតខ្មែរក្រហមនាំពួកយើងទៅខេត្តបាត់ដំបង ។ អង្គការបានចែកកូនខ្ទមមួយឲ្យក្រុមគ្រួសារខ្ញុំរស់នៅ ។ គ្រួសារខ្ញុំត្រូវបានបំបែកឲ្យទៅរស់នៅក្នុងកងផ្សេងៗគ្នា ។ មានតែកូនស្រី


ក្រុមសិល្បៈខ្មែរក្រហមនៅប្រាសាទបន្ទាយស្រី

*ពោរបស់ខ្ញុំអាយុប្រាំមួយឆ្នាំប៉ុណ្ណោះ រស់នៅជាមួយខ្ញុំ ។ ជីវិតនៅបាត់ដំបងគឺជារឿងរ៉ាវមួយដែលមិនអាចបំភ្លេចបានទេសម្រាប់ខ្ញុំ ។ ក្នុងរយៈពេលតែដប់ថ្ងៃប៉ុណ្ណោះកូនប្រុស ខ្ញុំបួននាក់និងកូនស្រីម្នាក់បានស្លាប់បន្តបន្ទាប់គ្នា ។ ខ្លះស្លាប់ដោយសារអត់អាហារនិងជំងឺ ខ្លះទៀតត្រូវបានសម្លាប់ដោយអង្គការចោទប្រកាន់ថាមានជាប់ពាក់ព័ន្ធជាមួយខ្មាំង ។ មួយរយៈក្រោយមក ម្តាយក្មេករបស់ខ្ញុំអាយុ៧០ឆ្នាំបានស្លាប់ដោយជំងឺខ្វះអាហារបរិភោគ ។ ជីវិតពោរពេញដោយភាពភ័យខ្លាច ។ ជារៀងរាល់យប់ ខ្ញុំមិនដែលដេកបានស្រួលទេ ។ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំជាច្រើនត្រូវអង្គការហៅទៅហើយបាត់ខ្លួនរហូត ។*

### ៣) ពិធីរៀបមង្គលការ

មង្គលការ(ឬពិធីបើកវគ្គ) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យខុសគ្នាទាំងស្រុងពីមង្គលការតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ។ កូនកម្លោះក្រមុំទាំងអស់ត្រូវបានរៀបចំក្នុងពិធីរួមតែមួយដែលមានចំនួនពី៣ទៅ១០គូ ក្នុងពិធីតូច ហើយពិធីធំមានពី៣០ទៅ៥០គូឬរហូតដល់ជាង១០០គូក្នុងពិធីនីមួយៗ ។ បុរសនារីភាគច្រើនមិនត្រូវបានអនុញ្ញាតឲ្យជ្រើសរើសគូស្រកររបស់ខ្លួនទេ ។ គូនីមួយៗបានត្រូវចាត់តាំងឡើងដោយអង្គការដែលអះអាងថាជាឪពុកម្តាយរបស់មនុស្សគ្រប់រូប ។ អ្នកខ្លះមិនទាំងស្គាល់ឈ្មោះនិងមុខមាត់អនាគតគូស្រកររបស់ខ្លួនផងទេ រហូតដល់ពេលប្រារព្ធពិធីតែម្តង ។ បងប្អូនសាច់ញាតិមិនអនុញ្ញាតឲ្យចូលរួមក្នុងពិធីមង្គលការឬចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តណាមួយឡើយ ។ សម្លៀកបំពាក់ប្រពៃណី ពិធីរាំវង់ ចម្រៀងប្រពៃណី និងពិធីតាមបែបសាសនាត្រូវបានហាមឃាត់ ។

នារីមួយចំនួនត្រូវបានបង្ខំឲ្យរៀបការជាមួយយុទ្ធជនពិការដែលរងរបួសក្នុងពេលសង្គ្រាម ហើយត្រូវដាច់ដៃ ឬដាច់ជើងម្ខាង ។ នារីដែលជំទាស់មិនទទួលយកបុរសពិការទាំងនេះអាចត្រូវចាប់ឃុំឃាំង ទទួលរងទណ្ឌកម្មជាទម្ងន់ ឬត្រូវបញ្ជូនឲ្យទៅធ្វើការនៅតំបន់ដាច់ស្រយាលឆ្ងាយៗពីផ្ទះ ។ នារីខ្លះដែលជួបប្រទះហេតុការណ៍បង្ខំបែបនេះបានធ្វើអត្តឃាត ។

មូសា សុខា ជនជាតិចាមរស់នៅខេត្តក្រចេះ ជាអតីតប្រធានសមាគមស្ត្រីឃុំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកអំពីការរៀបការរបស់គាត់កាលពីសម័យនោះដូច្នេះថាៈ *នៅឆ្នាំ១៩៧៤ ពេលខ្ញុំមានអាយុដប់ប្រាំឆ្នាំ ខ្ញុំបានរៀបការជាមួយអ្នកលីសែងគ្រឿងសព្វាវុធម្នាក់ឈ្មោះ ណុះ លាស់ ។ ពួកយើងសំណាងល្អណាស់ដែលបានរៀបការមួយខែមុនការអនុម័តច្បាប់ថ្មី ដែល*


ពិធីរៀបការរបស់ខ្មែរក្រហម

*ហាមប្រាមប្រជាជនមិនឲ្យតុបតែងខ្លួននឹងគ្រឿងអលង្ការចក្រពត្តិ ។ អ្វីក៏ដោយដែលប្រើសម្រាប់តុបតែងកាយត្រូវបានចាត់ទុកជារបស់ចក្រពត្តិទាំងអស់ សូម្បីតែគ្រឿងអលង្ការក្លែងក្លាយក៏ដោយ ។ មកត្រឹមពេលនោះ មានបុរសស្ត្រីពី៥ទៅ១០គូ ត្រូវបានបង្ខំឲ្យរៀបការជាមួយគ្នារួចស្រេចទៅហើយ ។ ប្រសិនបើគូណាមួយជំទាស់មិនព្រមការជាមួយគ្នា ពួកគេនឹងត្រូវហៅឲ្យទៅរៀនសូត្រ ។ ប្តីប្រពន្ធដែលទើបការហើយថ្មីៗថ្មោងត្រូវបំបែកចេញពីគ្នា ។ ក្នុងពិធីមង្គលការរបស់ខ្ញុំ ខ្ញុំមានអ្នកកំដរនិងមានពាក់គ្រឿងអលង្ការ ប៉ុន្តែខ្ញុំស្លៀកពាក់ខ្មៅនិងពាក់ស្បែកជើងកង់ឡាន ។ បន្ទាប់ពីការហើយបានបីថ្ងៃ អង្គការបានហៅប្តីខ្ញុំឲ្យទៅសមរភូមិ ព្រោះអង្គការត្រូវការកម្លាំងបន្ថែមដើម្បីវាយរំលំរដ្ឋាភិបាលក្រុងភ្នំពេញ ។ ខ្ញុំបានអង្វរប្រធានភូមិឲ្យប្តីខ្ញុំស្នាក់នៅក្នុងភូមិ ប៉ុន្តែគាត់បានបដិសេធ ។ នៅឆ្នាំ១៩៧៦ ខ្ញុំសម្រាលបានកូនប្រុសម្នាក់ ប៉ុន្តែបានស្លាប់ទៅវិញមួយសប្តាហ៍ក្រោយមកដោយសារជំងឺ ។*

អាពាហ៍ពិពាហ៍ដោយបង្ខំកាន់តែមានសភាពតឹងតែងឡើងបន្ទាប់ពីជ័យជម្នះរបស់ខ្មែរក្រហមឆ្នាំ១៩៧៥ ។ បុរសស្ត្រីជាច្រើនគូត្រូវបានបង្ខំឲ្យរៀបការក្នុងពេលតែមួយ ។ ដេង ហង្ស ប្រជាជនមកពីខេត្តកំពង់ចាមបានរៀបរាប់ពីមង្គលការរបស់គាត់ដូច្នេះថាៈ

*នៅឆ្នាំ១៩៧៨ គឺមួយខែមុនការដួលរលំនៃរបបនេះ អង្គការចាត់តាំងឲ្យខ្ញុំរៀបការ ។ ស្អែកឡើង ខ្ញុំអង្គុយលើកៅអីនៅក្នុងពិធីរៀបការ ដោយតាំងចិត្តថានឹងធ្វើតាមអ្វីដែលអង្គការបញ្ជា ។ ពិធីនោះមានយុវជនយុវនារីដែលត្រូវរៀបការសរុប១៦០គូ ។ ខ្ញុំនិងប្រពន្ធខ្ញុំបានសច្ចាថានឹងរួមរស់ជាមួយគ្នានិងមានកូនមួយក្នុងពេលមួយឆ្នាំ ។ ខ្មែរក្រហមបានចែកខោអាវខ្មៅមួយកំប្លេនិងក្រមាមួយ ហើយមានរៀបចំម្ហូបអាហារឲ្យហូប ។ ក្រោយបដិវត្តន៍ ខ្ញុំនិងប្រពន្ធខ្ញុំវិលមកផ្ទះវិញ ។ ឥឡូវនេះយើងមានកូនប្រាំនាក់ ។*

នៅថ្ងៃរៀបការបុរសនារីទាំងអស់ត្រូវឈរជាពីរជួរ ។ បន្ទាប់មកប្រធានភូមិបញ្ជាឲ្យអ្នកទាំងនេះចាប់ដៃគ្នា ហើយធ្វើការប្តេជ្ញាថានឹងរួមរស់ជាមួយគ្នាអស់មួយជីវិត ។ នេះបញ្ជាក់ថា បុរសនារីទាំងអស់នោះបានរៀបការរួចហើយ ។ ពិធីដ៏ខ្លីនេះនឹងត្រូវបញ្ចប់បន្ទាប់ពីមានការហូបអាហារបន្តិចបន្តួច ។

បន្ទាប់ពីរៀបការហើយ ប្តីប្រពន្ធបានទទួលការអនុញ្ញាតឲ្យរស់នៅជាមួយគ្នាតែពីរ-បីថ្ងៃប៉ុណ្ណោះ ហើយបន្ទាប់មកត្រូវទៅធ្វើការតាមក្រុមរៀងៗខ្លួនវិញ ។ ប្តីប្រពន្ធមួយចំនួនក៏បានទទួលការអនុញ្ញាតឲ្យមកជួបមុខគ្នាក្នុងរវាងពីប្រាំពីរទៅដប់ថ្ងៃម្តងដែរ ។

ខ្មែរក្រហមមើលឃើញពិធីរៀបការតាមប្រពៃណីខ្មែរដូចដែលខ្លួនមើលឃើញការគោរពប្រណិប័តន៍ជំនឿ សាសនា និងការសិក្សានៅតាមសាលាឬមហាវិទ្យាល័យដែរ ។ ខ្មែរក្រហមយល់ថាវាជាការចំណាយពេលឥតប្រយោជន៍ និងគ្មានបានជួយអ្វីទាល់តែសោះក្នុងការបង្កបង្កើនផលស្រូវ ។ មង្គលការរួមត្រូវបង្កើតឡើងដោយសារតែវាចំណាយពេលតិច ហើយពេលវេលាដែលនៅសល់នឹងត្រូវចំណាយទៅលើការងារសហករណ៍និងអ្វីដែលខ្មែរក្រហមហៅថា "បដិវត្តន៍មហាលោតផ្លោះ មហាអស្ចារ្យ" ដែលជាពាក្យស្លោកចម្លងចេញមកពីកុម្មុយនីស្តចិន ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់បញ្ជាក់ឲ្យច្បាស់ថា នឹងមានក្មេងៗចាប់កំណើតដែលអាចបន្តបដិវត្តន៍របស់ខ្លួនបាន ។ សម្រាប់ខ្មែរក្រហម គោលបំណងចម្បងនៃការរៀបការមិនមែនដើម្បីបង្កើតសង្គមគ្រួសារនោះទេ ប៉ុន្តែដើម្បីបង្កើតមនុស្សដែលអាចបម្រើបដិវត្តន៍បាន ។

## ៤) ការរំលោភលើសិទ្ធិនិងពលកម្មរបស់កុមារ

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមានសាលារៀនជាផ្លូវការទេ ។ កុមារត្រូវបានបញ្ជូនឲ្យទៅរៀននៅក្រោមដើមឈើ ឬនៅក្រោមផ្ទះប្រជាជន ។ គ្រូភាគច្រើនជាកសិករក្រដែលអាចអាន និងសរសេរតែបន្តិចបន្តួចប៉ុណ្ណោះ ។ ទោះជាការអប់រំនៅតាមតំបន់មួយចំនួនមានការរីកចំរើនក្នុងឆ្នាំ១៩៧៨ក៏ដោយ (កុមារទទួលបានការសិក្សាថ្នាក់បឋមពី២ទៅ៣ ម៉ោងក្នុងមួយថ្ងៃ) ក៏នៅតែមិនទាន់មានសាលារៀនដែលមានដំណើរការពេញលេញដែរ ។ ខ្មែរក្រហមនិយាយថា "*អង្គការគ្មានទេសញ្ញាប័ត្រ មានតែសញ្ញាឃើញ បើចង់បានបាក់អង បាក់ឌុប ត្រូវទៅយកនៅទំនប់ប្រឡាយ*" ហើយថា "*ការរៀនអក្សររៀនលេខមិនសំខាន់ទេ ការសំខាន់គឺការងារនិងចលនាបដិវត្តន៍*" ។

នៅពេលដែលកុមារត្រូវបានបង្ហាត់បង្រៀនឲ្យចេះអាន និងសរសេរអក្សរបន្តិចបន្តួចនោះ ភាគច្រើននៃការសិក្សាគឺផ្តោតទៅលើការអប់រំនយោបាយ ។ ក្មេងៗជាច្រើនត្រូវបានយកចេញ



កូនកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម

ពីផ្ទះឲ្យទៅចូលរួមវគ្គហ៊ឹកហ៊ឺនមនោគមវិជ្ជាដើម្បីអាចបម្រើក្នុងជួរកងទ័ព កងការពារ ឬនិរសារ ។

កូនក្មេងក៏ត្រូវបានចាត់តាំងឲ្យធ្វើការងារដែរនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការងាររបស់កុមារគឺដើររើសអាចម៍គោកាត់ទន្រ្ទានខែត្រ ប្រមូលលាមកមនុស្សដើម្បីធ្វើជី និងដឹកជញ្ជូនអាវុធទៅសមរភូមិ ដែលនៅទីនោះជួនកាលកុមារត្រូវទទួលរងរបួស ឬក៏ត្រូវគ្រាប់កាំភ្លើងស្លាប់ក៏មាន ។ ជាងនេះទៅទៀត កុមារាកុមារីទាំងនេះ ត្រូវបំបែកចេញពីឪពុកម្តាយ ហើយមិនដែលស្គាល់ភាពកក់ក្តៅគ្រួសារឡើយ ។

ភិន រដ្ឋា អាយុ៤០ឆ្នាំ ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញបានរំលឹកពីរឿងរ៉ាវរបស់គាត់ ដែលជាកូនក្មេងអាយុដប់ឆ្នាំម្នាក់ក្នុងឆ្នាំ១៩៧៥ថាៈ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅស្រុកគិរីវង្សខេត្តតាកែវ ។ នៅទីនោះអង្គការចែកផ្ទះឲ្យមួយខ្នងក្នុងគ្រួសារនីមួយៗ ។ ក្រុមគ្រួសារខ្ញុំរស់នៅដោយពឹងលើការដើររកក្តាម-ខ្យងធ្វើជាម្ហូប ។ បន្ទាប់ពីប្រជុំនយោបាយជាមួយប្រធានភូមិហើយ យើងត្រូវបានចាត់តាំងឲ្យហូបរួម ហើយខ្ញុំមិនអាចរកក្តាម-ខ្យងបានទៀតទេ ។ ដោយសារតែឃ្លានខ្លាំងពេក ខ្ញុំខំសង្វាក់លួចបេះបន្លែដែលយើងបាន



កុមាររៀនអំពីការដាំដុះស្រូវ

ដាំនៅជុំវិញផ្ទះហូបណាស់ ។ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅកងចល័តកុមារដែលស្ថិតនៅឆ្ងាយពីផ្ទះ ។ រយៈពេលបី-បួនខែទើបអង្គការអនុញ្ញាតឲ្យខ្ញុំមកលេងផ្ទះម្តង ។ ការងាររបស់ខ្ញុំគឺសែងកណ្តាប់ក្នុងស្រែ ។ ពេលខ្លះ ខ្ញុំមិនចង់ចុះធ្វើការងារក្នុងស្រែទេ ពីព្រោះខ្ញុំខ្លាចឈ្លើងទាម ។ ប្រធានកងនៅទីនោះតែងតែវាយធ្វើបាបខ្ញុំ ។ ខ្ញុំបានរត់ទៅផ្ទះជាច្រើនដងដើម្បីឲ្យឪពុកម្តាយខ្ញុំជួយ ប៉ុន្តែគ្មានអ្នកណាអាចជួយខ្ញុំបានឡើយ ។ បន្ទាប់មកខ្ញុំបានទៅពួនក្នុងព្រៃអស់មួយរយៈ ។ ខ្ញុំរស់នៅដោយបេះស្លឹកឈើព្រៃ និងផ្លែឈើព្រៃហូបនិងលួចម្ហូបអ្នកភូមិ ។ ដោយមិនអាចទ្រាំបាននឹងស្ថានភាពរស់នៅបែបនោះ ខ្ញុំរត់មកនៅផ្ទះខ្ញុំវិញ ។ ដោយខ្លាចអង្គការ ឪពុកម្តាយខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅកងចល័តវិញ ។ ពេលទៅដល់កងវិញ ប្រធានកងបានធ្វើទារុណកម្មខ្ញុំនិងព្រមានខ្ញុំកុំឲ្យរត់ទៀត ។ ខ្ញុំត្រូវបានចាត់តាំងឲ្យស្រោចបន្លែនិងកើបអាចម៍ជ្រូក ។ ថ្ងៃមួយ ដោយសារខ្ញុំមានការអស់កម្លាំងខ្លាំងនិងទន់ជង្គង់ផង ខ្ញុំដួល ហើយធ្វើឲ្យកំពប់អាចម៍ជ្រូកពីរអម្រែក ។ ប្រធានកងយករំពាត់ខ្សែគោមកវាយខ្ញុំ ហើយរំពាត់នោះខ្ទាតត្រូវភ្នែករបស់ខ្ញុំ ។ ចាប់ពីពេលនោះមកខ្ញុំចេះតែហៀរ

ទឹកភ្នែក ហើយភ្នែកខ្ញុំឡើងក្រហមឈឺចាប់យ៉ាងខ្លាំង ។ ទីបំផុតខ្ញុំត្រូវងងឹតមើលអ្វីលែងឃើញ ។

រស់ សមពៅ ប្រជាពលរដ្ឋរស់នៅទីក្រុងភ្នំពេញបានបាត់បង់សមាជិកគ្រួសារទាំងអស់ក្នុងសម័យខ្មែរក្រហម ។ សមពៅ បានរៀបរាប់ថាៈ គ្រួសាររបស់ខ្ញុំដែលមានសមាជិកប្រាំនាក់ត្រូវបានដឹកទៅភ្នំត្រឡោក ដែលស្ថិតក្នុងស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។ ខ្ញុំនិងកុមារផ្សេងទៀតត្រូវបានចាត់តាំងឲ្យទៅជីកដី លើកទំនប់ឃ្វាលគោ និងដើរកាប់ដើមទន្ទ្រានខែត្រ ។ យើងត្រូវតែធ្វើឲ្យហើយតាមការកំណត់ ។ ប្រសិនបើមិនហើយ យើងនឹងត្រូវកាត់របបអាហារនិងទទួលទារុណកម្ម ។ ឪពុករបស់ខ្ញុំស្លាប់ដោយជំងឺគ្រុនចាញ់ ចំណែកបងស្រីខ្ញុំស្លាប់ដោយសារជំងឺហើមពោះ ។ គ្រាមួយបន្ទាប់ពីធ្វើការហើយ យើងបានមកជួបជុំគ្នាហើយប្រាប់គ្នាទៅវិញទៅមកអំពីប្រវត្តិគ្រួសាររបស់យើង ។ បន្តិចក្រោយ មកបងប្រុសម្នាក់បានដើរចូលមកហើយប្រាប់ខ្ញុំថាម្តាយរបស់ខ្ញុំត្រូវអង្គការយកទៅសម្លាប់ចោលបាត់ទៅហើយ ។ ក្រោយពីទទួលបានដំណឹងនេះភ្លាមទឹកភ្នែកខ្ញុំហូរធ្លាក់មកដោយមិនដឹងខ្លួន ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំអស់ហើយ គ្មានសេសសល់អ្វីទៀតទេ សូម្បីតែរូបខ្លួនឯងក៏ពុំដឹងថាអាចមានជីវិតរស់បានយូរប៉ុណ្ណាដែរ ។ សមាជិកចុងក្រោយតែម្នាក់គត់របស់គ្រួសារខ្ញុំ គឺបងប្រុសរបស់ខ្ញុំដែលបាត់ខ្លួនដោយគ្មានដំណឹងអ្វីបន្តិចបន្តួចសោះ រហូតមកទល់សព្វថ្ងៃនេះ ។

កុមារទាំងឡាយត្រូវបានបង្ហាត់បង្រៀនថា “អង្គការជាឪពុកម្តាយរបស់កុមារាកុមារីនិងយុវជនយុវនារី ។ បើម៉ែឪវាយកូនមានន័យថាមើលងាយអង្គការ ដូច្នេះអង្គការមិនប្រណីឡើយ” ។ កម្មាភិបាលខ្មែរក្រហមបានឲ្យកុមារស៊ើបការណ៍ពីឪពុកម្តាយរបស់ខ្លួន ហើយជូនកាលកុមារទាំងនេះហ៊ានទាំងសម្លាប់ឪពុកម្តាយបង្កើតរបស់ខ្លួនទៀតផង ប្រសិនបើទទួលបានបញ្ជាពីអង្គការ ។ មួយរយៈកាលកន្លងផុតទៅ កុមារទាំងឡាយជឿតែទៅលើអ្វីដែលអង្គការបានប្រាប់ និងគោរពតាមតែបញ្ជារបស់អង្គការប៉ុណ្ណោះ ។

ក្នុងអំឡុងពេលសង្គ្រាមជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧-១៩៧៨ កងទ័ពខ្មែរក្រហមជាច្រើនបានស្លាប់ឬរងរបួសជាទម្ងន់ ។ ខ្មែរក្រហមបានបញ្ជូនកុមារឲ្យទៅសមរភូមិមុខ ដែលនៅទីនោះកុមាររាប់ពាន់ នាក់បានត្រូវរបួសនិងស្លាប់បាត់បង់ជីវិត ។

## ៥) ការបង្ខំឲ្យធ្វើការជាទម្ងន់

ប្រជាជនគ្រប់រូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបាន



ការប្រារព្ធពិធីអបអរសាទរចំពោះការបញ្ចប់ដោយជោគជ័យនូវគម្រោងប្រព័ន្ធប្រឡាយទឹក

ចាត់តាំងឲ្យធ្វើការងារទាំងអស់ ។ កុមារត្រូវបានដាក់ឲ្យធ្វើការងារស្រាលៗ ចំណែកមនុស្សចាស់ៗមានភារកិច្ចមើលថែទាំកុមារតូចៗ និងសត្វពាហនៈនិងត្បាញកន្ទេលស្លឹក ។ មនុស្សដែលមានអាយុលើសពី១៨ឆ្នាំ(កុមារវ័យជំទង់) ត្រូវទទួលការងារធ្ងន់ៗនិងលំបាក ។ កុមារជំទង់ៗទាំងនេះត្រូវជីកប្រឡាយ ឬអាងស្តុកទឹក លើកទំនប់ កាប់ឈើធ្វើផ្ទះ រានដីដើម្បីធ្វើស្រែចម្ការ និងដាំស្រូវ ។ បុរសស្ត្រីប្រហែលពីរ-បីពាន់នាក់ ដែលបក្សទុកចិត្តត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅរោងចក្រឯទីក្រុងភ្នំពេញ ។

ប្រជាជនស្ទើរគ្រប់រូបធ្វើការច្រើនជាងដប់ពីរម៉ោងក្នុងមួយថ្ងៃ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដោយមិនមានពេលសម្រាកនិងទទួលទានអាហារតិចតួចបំផុត ។ ជួនកាលប្រជាជនធ្វើការតាំងពីព្រលឹមស្រាងៗរហូតដល់ពាក់កណ្តាលយប់ បើសិនជាខែភ្លឺ ។ ថ្ងៃណាដែលមិនមានលោកខែ គេអុចភ្លើងបំភ្លឺវាលស្រែដើម្បីធ្វើការបន្ត ។ ប្រសិនបើប្រជាជនតវ៉ានឹងការងារដែលកំណត់ឲ្យដោយប្រធានសហករណ៍ ប្រជាជនទាំងនេះនឹងត្រូវចោទប្រកាន់ថាជាខ្មាំងរបស់បដិវត្តន៍ ហើយនឹងត្រូវបញ្ជូនទៅអប់រំ ។ អ្នកដែលប្រព្រឹត្តកំហុសដដែលៗ ឬកំហុសធ្ងន់ធ្ងរនឹងត្រូវយកទៅសម្លាប់ចោល ។ ការប្រព្រឹត្តបែបនេះគឺផ្ទុយទាំងស្រុងទៅនឹងមាត្រា១២នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលមានសេចក្តីជាអាទិ៍ថាៈ

◆ ប្រជាជនកម្ពុជាគ្រប់រូបមានសិទ្ធិជីវភាពពេញទីខាងសម្ភារៈ ខាងស្មារតី និងខាងវប្បធម៌ ដែលត្រូវបានកែប្រែឲ្យរីកចម្រើនកាន់តែខ្ពស់ឡើងជានិច្ច ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែត្រូវធានាអះអាងខាងជីវភាពទាំងអស់ ។

◆ កម្មករគ្រប់រូបជាម្ចាស់រោងចក្រ ។

◆ កសិករគ្រប់រូបជាម្ចាស់ស្រែចម្ការ ។

◆ ពលករផ្សេងទៀតមានសិទ្ធិមានការងារធ្វើទាំងអស់ ។

◆ ភាពគ្មានការងារធ្វើមិនមានដាច់ខាតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ៦) វិសុទ្ធកម្មនិងការសម្លាប់រង្គាល

ខ្មែរក្រហមតែងតែស្រាវជ្រាវរកចាប់ខ្មាំង ហើយជឿជាក់ថាខ្មាំងមាននៅគ្រប់ទីកន្លែងទាំងអស់ក្នុងទូទាំងប្រទេស ។ ជនសង្ស័យជាច្រើនត្រូវបានចោទប្រកាន់ទាំងប្រឡំថាជាភ្នាក់ងារសម្ងាត់របស់សហរដ្ឋអាមេរិក(សេ.អ៊ី.អា) ភ្នាក់ងារសម្ងាត់របស់សូវៀត(កា.ហ្សេ.បេ) ឬក៏ភ្នាក់ងារសម្ងាត់របស់វៀតណាម ។

ការប៉ះទង្គិចជាមួយវៀតណាមក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ បាននាំទៅដល់ការធ្វើវិសុទ្ធកម្មដ៏ធំធេងមួយ ។ នៅចុងឆ្នាំ១៩៧៧ បន្ទាប់ពី ប៉ុល ពត វិលត្រឡប់មកពីប្រទេសចិនវិញ កងទ័ពវៀតណាមបានវាយចូលភាគបូព៌ានៃប្រទេសកម្ពុជា ។ បី-បួនខែក្រោយមក ទ័ពវៀតណាមបានដកថយទៅវិញ ដោយគៀរយកប្រជាជនស៊ីវិលខ្មែររាប់រយនាក់ទៅជាមួយផង ។ នៅពេលនោះខ្មែរក្រហមបានចោទប្រជាជននិងកម្មាភិបាលភូមិភាគបូព៌ាថាបានចូលដៃចូលជើងជាមួយវៀតណាម ។ ហេតុការណ៍នេះបាននាំទៅដល់ការចាប់ខ្លួន និងសម្លាប់ចោលមនុស្សជាច្រើននាក់ រួមទាំងអ្នកដែលស្មោះត្រង់នឹងខ្មែរក្រហមនិងដៃគូនយោបាយដើងចាស់របស់ខ្លួនដ៏យូរលង់ ដូចជា សោ ភឹម ទៀតផង ។

វិសុទ្ធកម្មដ៏សាហាវយង់ឃ្នងបំផុតនៅក្នុងភូមិភាគនេះកើតឡើងនៅឆ្នាំ១៩៧៨ បន្ទាប់ពីកងពលមួយចំនួននៃភូមិភាគនេះបានធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។ ចាប់តាំងពីខែមិថុនាដល់ខែកញ្ញា នៅពេលដែលការប៉ះទង្គិចជាមួយវៀតណាមកំពុងតែបន្ត តំបន់ភាគច្រើននៅក្នុងភូមិភាគនេះបានក្លាយទៅជាសមរភូមិរវាងកងទ័ពរបស់រដ្ឋាភិបាលកម្ពុជាប្រជា-ធិបតេយ្យនិងកងទ័ពបះបោរ ។ មនុស្សប្រហែលមួយសែននាក់ក្នុងភូមិភាគបូព៌ាបានស្លាប់ក្នុងសមរភូមិនិងដោយសារការសម្លាប់រង្គាល ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនទ័ពពីភូមិភាគនិរតីទៅបង្ក្រាបក្រុមបះបោរ ។ ប្រជាជនរាប់ពាន់នាក់បានរត់ទៅព្រំដែនវៀតណាម គេចពីការសម្លាប់រង្គាលដែលផ្ទុះឡើង បន្ទាប់ពីការមកដល់នៃកងទ័ពទាំងនេះ ។

វិសុទ្ធកម្មក៏កើតមានឡើងដែរនៅភូមិភាគឧត្តរក្នុងឆ្នាំ១៩៧៧ ។ វិសុទ្ធកម្មនេះផ្តោតទៅលើបញ្ញវន្ត និងអ្នកដែលមានជាប់ពាក់ព័ន្ធនឹង កុយ ធួន ដែលធ្វើជាលេខាភូមិភាគឧត្តររហូតដល់ដើមឆ្នាំ១៩៧៦ ។ នៅអំឡុងពេលធ្វើវិសុទ្ធកម្មនេះ អង្គការបានចាប់ខ្លួនរដ្ឋមន្ត្រីក្រសួងព័ត៌មាន ហ៊ូ នឹម, ទីវ អុល (គ្រូរបស់ កុយ ធួន) និងមិត្តភក្តិជាច្រើននាក់ទៀតដែលរួមមាន ភោគ ឆាយ និង ឌឿន ជាដើម ។ មានគម្រោងធ្វើរដ្ឋប្រហារបី-បួនលើក និងមានការ

បះបោរជាច្រើនដង (ជាពិសេស ការបះបោររបស់ជនជាតិចាម) ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែផែនការទាំងនេះសុទ្ធតែបរាជ័យ ហើយបានធ្វើឲ្យការស្រាវជ្រាវរកខ្មាំងបង្កប់ផ្ទៃក្នុងមានសភាពកាន់តែខ្លាំងក្លាឡើង ដែលនាំទៅដល់ការធ្វើវិសុទ្ធកម្មនៅទូទាំងប្រទេស ។

សាន់ គីម៉ាណាស់ អាយុ៧៨ឆ្នាំ រស់នៅក្នុងខេត្តកំពង់ចាម បានរំឭកអំពីការសម្លាប់រង្គាលជនជាតិភាគតិចចាម ដោយខ្មែរក្រហមក្នុងអំឡុងពេលនៃការបះបោរ ជាពិសេសការសម្លាប់ក្រុមគ្រួសាររបស់អ្នកស្រីផ្ទាល់ ។ អ្នកស្រីបានរៀបរាប់ថាៈ នៅសម័យសង្គមរាស្ត្រនិយមមានគ្រួសារជនជាតិចាមរាប់ពាន់គ្រួសាររស់នៅក្នុងភូមិរបស់ខ្ញុំ ។ ពួកខ្មែរក្រហមបានសម្លាប់ពួកគេស្ទើរទាំងអស់ ។ ប្រជាជននៅក្នុងភូមិខ្ញុំនិងភូមិកោះផលទទួលរងនូវអំពើព្រៃផ្សៃនេះច្រើនជាងគេ ពីព្រោះពួកយើងបះបោរប្រឆាំងនឹងពួកខ្មែរក្រហម ។ ចំពោះគ្រួសារខ្ញុំវិញ ពួកវាសម្លាប់ឪពុកម្តាយខ្ញុំ កូនខ្ញុំពីរនាក់ ចៅពីរនាក់ និងបងប្អូនបង្កើតរបស់ខ្ញុំទាំងអស់ ។ កូនប្រុសរបស់ខ្ញុំឈ្មោះ មូសា ត្រូវខ្មែរក្រហមនាំយកទៅបន្ទាប់ពីការបះបោរ ហើយក៏បាត់ខ្លួនរហូត ។ ខ្ញុំឮពាក្យចចាមអារ៉ាមថា វាត្រូវបានសម្លាប់នៅពេលវាតាមរកខ្ញុំ ។ កូនស្រីរបស់ខ្ញុំឈ្មោះ រ៉ហ៊ីអះព្រមទាំងប្តីនិងកូនពីរនាក់ទៀតត្រូវបានសម្លាប់ដោយមិនមានមូលហេតុអ្វីទាំងអស់ ។

បន្ទាប់មក ពួកខ្មែរក្រហមបានបញ្ជូនគ្រួសាររបស់ខ្ញុំទៅភូមិស្រែវាលក្នុងស្រុកស្ទឹងត្រង់ ។ មុនដំបូង ពួកវាចាត់តាំងខ្ញុំឲ្យទៅកាប់ដើមឈើជាមួយអ្នកជម្លៀសមកពីភ្នំពេញ ។ មនុស្សជាច្រើនត្រូវបានសម្លាប់ដោយសារតែពួកគេធ្វើការមិនបានល្អ ឬត្រូវដើមឈើដួលរលំសង្កត់លើ ។ បន្ទាប់មកខ្ញុំត្រូវបានចាត់តាំងឲ្យចិញ្ចឹមជ្រូក ។ ខ្ញុំបានប្រកែកដោយអះអាងថា ខ្ញុំខ្លាចជ្រូកណាស់ ។ ប៉ុន្តែពួកវាបង្ខំខ្ញុំឲ្យធ្វើ ហើយគំរាមកំហែងខ្ញុំថា អង្គការនឹងបញ្ជូនខ្ញុំទៅរៀនសូត្រ ប្រសិនបើខ្ញុំមិនធ្វើ ។ ពួកខ្មែរក្រហមថែមទាំងបង្ខំឲ្យខ្ញុំហូបសាច់ជ្រូកទៀតផង ប៉ុន្តែខ្ញុំប្រកែកដោយនិយាយថា ខ្ញុំមិនដែលហូបសាច់សត្វទេតាំងពីតូចមក ។ តាំងពីពេលនោះមក ពួកវាបានបដិសេធមិនឲ្យអាហារអ្វីទាំងអស់មកខ្ញុំ ។ ខ្ញុំបានសុំអំបិលខ្លះ ប៉ុន្តែពួកវានិយាយថារបបអំបិលបានដាក់នៅក្នុងសម្លសាច់ជ្រូកអស់ហើយ ។ ខ្លួនរបស់ខ្ញុំឡើងហើម ។ ជាសំណាងល្អ ខ្ញុំបានរួចរស់ជីវិតពីរបបនេះ ។ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតរបស់ខ្ញុំវិញនៅឆ្នាំ១៩៧៩ ។ **(នៅមានត)**

**ឌី ខាំបូលី**



គម្រោងលើកទំនប់

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ១៩ ខែកញ្ញា ២០០៧ លោក **នួន ជា** ជួបជាមួយមន្ត្រីនៃអង្គភាពគាំពារការការពារក្តីនៃអង្គជំនុំជម្រះវិសាមញ្ញ ហើយគាត់បានជ្រើសរើសមេធាវីកម្ពុជា លោក សុន អរុណ ដើម្បីការពារគាត់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ។ លោក **នួន ជា** មិនទាន់ជ្រើសរើសមេធាវីបរទេសនៅឡើយទេ ។

លោក សុន អរុណ បានចូលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៦ ។ គាត់ប្រកបអាជីពឯកជនអស់រយៈពេល ១១ឆ្នាំ ហើយមានជំនាញការពារបុគ្គលដែលត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាអំពើភេរវកម្ម ។ ចាប់តាំងពីឆ្នាំ ២០០២ លោក សុន អរុណមានតួនាទីជានាយកនៃក្រុមហ៊ុនមេធាវី EU ASIA Pacific ។

លោក **នួន ជា** អះអាងថាគាត់ពុំមានមធ្យោបាយដើម្បីបង់ប្រាក់សេវាមេធាវីរបស់គាត់ទេ ហេតុដូច្នេះ គ្រោងការជំនួយការច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ នឹងបង់ប្រាក់កម្រៃសេវាសំរាប់លោក សុន អរុណ ស្របពេលការអះអាងរបស់លោក **នួន ជា** កំពុងត្រូវបានវាយតំលៃ ។



ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**Royaume du Cambodge**

**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Chambres Extraordinaires au sein
des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**

**Office of the Co-Investigating Judges**

**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**

**Criminal Case File /Dossier pénal**

**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**

**លេខ/No: 002/19-09-2007**

## ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

## Provisional detention Order
## Ordonnance de placement en détention provisoire

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៦៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **នួន ជា** ភេទ ប្រុស កើតនៅ ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅ ភូមិវត្តគរ ឃុំវត្តគរ ស្រុកសង្កែ ខេត្តបាត់ដំបង ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ

ឪពុកឈ្មោះ ឡៅ លីវ (ស្លាប់) ម្តាយឈ្មោះ ដុស ពាញ (ស្លាប់) ប្រពន្ធឈ្មោះ លី គឹមសេង (រស់) មានកូន ០៣ នាក់ មានទីលំនៅបច្ចុប្បន្ននៅភូមិផ្សារព្រហ្ម ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន

ត្រូវដាក់អោយស្ថិតនៅក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និង ការលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ សីហា ១៩៤៩ ដែលមានចែងនិងផ្តន្ទាទោសតាមមាត្រា៥ មាត្រា ៦ មាត្រា ២៩ ថ្មី និង មាត្រា ៣៩ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថ្ងៃទី២៧ តុលា ២០០៥។

បានឃើញការជជែកដេញដោលដែលបានធ្វើនៅថ្ងៃនេះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## ១- ស្ថានភាពអង្គហេតុ និង អង្គច្បាប់

១- នៅក្នុងករណីបច្ចុប្បន្ន (ដោយមិនប៉ះពាល់ដល់លទ្ធផលនៃការស៊ើបសួរដែលកំពុងដំណើរការ ដែលអាចអោយយើងកំណត់ជាបទល្មើសផ្សេងទៀតដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និង ដែលអាចដាក់បន្ទុកលើជនត្រូវចោទ) **ឈ្មោះ នួន ជា** ត្រូវបានចោទអំពី ៖

- **បទល្មើសប្រឆាំងនឹងមនុស្សជាតិ** (មនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ ការសំលាប់ផុតពូជ ការនិរទេស ការជន្លៀសប្រជាពលរដ្ឋដោយបង្ខំ ការដាក់ជាទាសករ និង អំពើអមនុស្សធម៌ដទៃទៀត) និង

- **បទឧក្រិដ្ឋសង្គ្រាម**ដែលផ្អែកលើការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ សីហា ឆ្នាំ ១៩៤៩ (ការសំលាប់ដោយចេតនា ការធ្វើទារុណកម្ម ការប្រព្រឹត្តអមនុស្សធម៌ ការបង្កព្យសនកម្មធ្ងន់ធ្ងរ ឬការធ្វើអោយឈឺចាប់ខ្លាំងដោយចេតនាដល់រាយកាយ និង សុខភាព ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការនិរទេស ឬ ជន្លៀសដោយបង្ខំ ឬ ការបង្ខាំងជនស៊ីវិលដោយខុសច្បាប់)

២- ជននេះត្រូវបានដាក់បន្ទុកថាបានធ្វើ នៅលើទឹកដីនៃប្រទេសកម្ពុជារវាងថ្ងៃ ១៧ មេសា ១៩៧៥ និង ថ្ងៃទី ៦ ខែ មករា ១៩៧៩ ៖

- ក្នុងឋានៈ ជាអាទិ៍ ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ប្រធានសភាប្រជាជននៃកម្ពុជាប្រជាធិបតេយ្យ នាយករដ្ឋមន្ត្រីស្តីទី និង អនុប្រធាននៃគណៈកម្មាធិការយោធាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា

- ផែនការ មេគំនិត ដឹកនាំ បញ្ជា សម្របសម្រួល និងផ្តល់ជំនួយ ក្នុងការប្រព្រឹត្តនូវបទល្មើសទាំងឡាយខាងលើដោយប្រើប្រាស់នូវអំណាច និង ការគ្រប់គ្រងដោយពេញលេញរបស់ខ្លួនដែលមានលើមន្ទីរសន្តិសុខផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ (មន្ទីរឃុំឃាំងទាំងឡាយ) និង ដោយដឹកនាំ តាមរយៈការដាក់ឲ្យអនុវត្ត និងការធ្វើឲ្យគេគោរពនូវនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលមានលក្ខណៈជាការជន្លៀសប្រជាជនដោយបង្ខំ ការដាក់ជាទាសករ ការធ្វើការងារដោយបង្ខំ ឬ អំពើអមនុស្សធម៌ដទៃទៀត

- នយោបាយជាទូទៅ និង ជាប្រព័ន្ធ សំដៅលើជនស៊ីវិល

- ដោយបញ្ជាក់ថា ក្នុងកំឡុងពេលទាំងអស់ ឬមួយផ្នែកនៃចន្លោះថ្ងៃទី១៧ មេសា ១៩៧៥ និង ថ្ងៃទី៦ មករា ១៩៧៩ កម្ពុជាប្រជាធិបតេយ្យ និង សាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា។

៣- សហព្រះរាជអាជ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញស្នើសុំអោយមានការឃុំខ្លួនបណ្ដោះអាសន្នលើជនត្រូវចោទ ដោយហេតុថាមានហេតុផលជាក់លាក់ដែលជឿថា **នួន ជា** បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួរ និងថា ការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈចាំបាច់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី ដូចជាអ្នកដែលធ្លាប់ស្ថិតនៅក្រោមអំណាចរបស់គាត់ និង ការពារការបំផ្លាញភស្តុតាងនានា។ ម្យ៉ាងវិញទៀត ការឃុំខ្លួនបណ្ដោះអាសន្នមានលក្ខណៈចាំបាច់ដើម្បីធានារក្សាទុកវត្តមានជននេះសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ ដោយពិនិត្យមើលលើលទ្ធភាពដែលអាចរត់គេចខ្លួន និង ដើម្បីរក្សាសុវត្ថិភាពដល់ជនត្រូវចោទផ្ទាល់។ ជាចុងក្រោយ ការឃុំខ្លួននេះមានសារៈសំខាន់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៤- **នួន ជា** ជំទាស់នឹងអង្គហេតុដែលដាក់បន្ទុកលើខ្លួន ដោយគូសបញ្ជាក់ថាគាត់នឹងមានភាពអៀនខ្មាស់បើបានប្រព្រឹត្តអំពើបែបនោះមែន និង អះអាងថា ៖ “*យើងមិនដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងមូលដ្ឋានទេ ដូច្នេះយើងមិនបានដឹងអំពីអ្វីដែលកើតមានឡើងនោះទេ*”។ ជនត្រូវចោទបញ្ជាក់ថាអំណាចពិតប្រាកដក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យស្ថិតនៅក្នុងដៃគណៈកម្មាធិការយោធាដែលគាត់មិនស្ថិតនៅក្នុងនោះទេ។ គាត់បានបន្ថែមថាគាត់គឺជាសមាជិកអំណាចនីតិបញ្ញត្តិ គាត់មិនដែលធ្វើច្បាប់កាប់សម្លាប់ជាតិឯងនោះទេ។ គាត់លើកឡើងថា គាត់ខ្លួនឯងក៏បានបាត់បង់សមាជិកគ្រួសារប្រហែល៤០ នាក់ផងដែរនៅក្នុងព្រឹត្តការណ៍សម័យនោះ។ គាត់ជំទាស់ជានិច្ចចំពោះការដែលគេនិយាយមិនឈប់អំពីជនរងគ្រោះ ១.៧ លាននាក់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនដែលនិយាយអំពីការស្លាប់ដែលបង្កឡើងដោយជនដទៃទៀតនៅមុនឆ្នាំ១៩៧៥ ឬ នៅក្រោយឆ្នាំ១៩៧៩។ ជនត្រូវចោទលើកឡើងថា លក្ខខណ្ឌនៃការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវបានបំពេញទេ ដោយហេតុថា ចាប់តាំងពីគាត់បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាមក គាត់រស់នៅដោយមានសេរីភាពដោយមិនដែលមានបញ្ហាអ្វីកើតឡើងទេ។ គាត់បញ្ជាក់ផងដែរថា គាត់គ្មានចេតនានៅក្នុងការបំផ្លាញភស្តុតាង ឬ ដាក់សម្ពាធលើអ្នកណាម្នាក់ឡើយ ពីព្រោះគាត់មិនមានធាតុឃោរឃៅទេ និង គាត់ក៏ធ្លាប់បួសរៀនផងដែរ។ ម្យ៉ាងទៀត គាត់ក៏មិនដែលធ្លាប់ត្រូវបានគំរាមកំហែងដោយជនណាម្នាក់ដែរ។ ផ្ទុយទៅវិញ គាត់ទទួលបានការស្រលាញ់រាប់អានជាច្រើន ។ ក្រៅពីនេះ គាត់រស់នៅក្បែរព្រំដែនប្រទេសថៃជាច្រើនឆ្នាំមកហើយ ដូចនេះ គាត់អាចនឹងរត់គេចខ្លួនបានយ៉ាងស្រួល ប្រសិនបើគាត់ចង់រត់គេចនោះ។ គាត់ប្រកាសថា គាត់ចង់បំភ្លឺដល់ប្រជាជនកម្ពុជា និង ពិភពលោកទាំងមូលអំពីសត្រូវពិតប្រាកដរបស់កម្ពុជា ដោយបញ្ជាក់ថា គាត់ជាជនស្នេហាជាតិ និង មិនមែនជាជនកំសាកទេ ហើយគាត់ក៏មិនសុខចិត្តអោយកិត្តិយសរបស់ប្រទេសជាតិអាប់អោនដែរ។

## ២- សំអាងហេតុសេចក្ដីសម្រេច

៥- តាមរយៈឯកសារ និង ចម្លើយសាក្សីជាច្រើនដែលដាក់បន្ទុកលើ **នួន ជា** បង្កើតបានជាហេតុផលដែលអាចអោយជឿជាក់ថា **នួន ជា** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុក។ អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ

ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនការហួសហេតុពេកដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។ ម្យ៉ាងវិញទៀត តួនាទីឋានានុក្រមជាពិសេសរបស់ **នួន ជា** (“បងធំទី២”នៃរបបនោះ) នាំអោយសង្ស័យថា ជននេះព្យាយាមនិងរៀបចំធ្វើការដាក់សម្ពាធលើសាក្សី និង ជនរងគ្រោះ។ ក្រៅពីនេះ ទោសឧក្រិដ្ឋជាប់មន្ទីរឃុំឃាំងមួយជីវិតដែល **នួន ជា** ត្រូវប្រឈម អាចនាំឲ្យមានការភ័យខ្លាចថា ជននេះអាចស្វែងរកការគេចខ្លួនពីតុលាការ។

៦- ជាផលវិបាក យល់ឃើញថាការឃុំខ្លួនបណ្តោះអាសន្នមានកសារៈសំខាន់ដើម្បីបង្ការរាល់ការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ និង មានភាពចាំបាច់ផងដែរដើម្បីធានារក្សាទុកវត្តមានជនត្រូវចោទសម្រាប់ដំណើរការស្វែងរកយុត្តិធម៌ និង ដើម្បីរក្សាសណ្តាប់ធ្នាប់សារធារណៈ និង ដើម្បីការពារការពារសុវត្ថិភាពផ្ទាល់របស់ជននេះ ដែលមិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរ៉ឹង និង មានប្រសិទ្ធិភាពអាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចគោលដៅខាងលើនេះ។

## ហេតុដូច្នេះ សម្រេច

ឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ **នួន ជា** ចំនួនរយៈពេលអតិបរមា ១ ឆ្នាំ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៧

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**

ដីកាសម្រេចនេះតាក់តែងឡើងជាភាសាខ្មែរ និង ភាសាបារាំង និង បកប្រែជាភាសាអង់គ្លេសជាក្រោយ។

**យើង លី ច័ន្ទតុលា និង ហាម ហ៊ើល** បានប្រគល់ដីកានេះដល់ឈ្មោះខាងក្រោមនៅថ្ងៃទី........ខែ........... ឆ្នាំ...........

**ជនត្រូវចោទ មេធាវីជនត្រូវចោទ សហព្រះរាជអាជ្ញា ការិយាល័យរដ្ឋបាល ក្រឡាបញ្ជី**

តាមរយៈការជូនដំណឹងនេះ ជនត្រូវចោទ ត្រូវបានប្រាប់ថា:

- ជនត្រូវចោទអាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ននេះ ស្របតាមលក្ខណ្ឌដែលមានចែងក្នុងវិធាន ៧៥ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ ។
- នៅគ្រប់ករណីទាំងអស់ ជនត្រូវចោទ មានសិទ្ធិត្រូវបាននាំខ្លួនទៅជួបសហចៅក្រមស៊ើបអង្កេត យ៉ាងហោចណាស់ រៀងរាល់ ១២០ ថ្ងៃម្តង ហើយ ត្រូវផ្តល់ឱកាសដើម្បីពិភាក្សាអំពីប្រព្រឹត្តិកម្ម និង លក្ខខ័ណ្ឌនៃការឃុំខ្លួន ។
- នៅពេលជួបសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ អាចធ្វើការស្នើសុំផ្សេងៗ ហើយ សហចៅក្រមស៊ើបអង្កេត ត្រូវសម្រេចអំពីសំណើរនេះ។
- ជនត្រូវចោទ អាចធ្វើការកត់សម្គាល់ មុនពេលដែលសហចៅក្រមស៊ើបអង្កេត សម្រេចអំពីការបន្ត ការឃុំខ្លួនជនត្រូវចោទនេះ។ ជនត្រូវចោទ អាចប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចនេះ។
- ក្នុងពេលឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទ ឬមេធាវីរបស់គេ អាចធ្វើសំណើសុំដោះលែងទៅ សហចៅក្រមស៊ើបអង្កេតបានគ្រប់ពេលវេលា ។
- បើស្ថានភាពផ្លាស់ប្តូរក្រោយពេលដាក់ពាក្យសុំចុងក្រោយ ជនត្រូវចោទ អាចដាក់ពាក្យសុំនៅក្រៅឃុំ សាជាថ្មីម្តងទៀត ក្នុងរយៈពេលមិនឱ្យតិចជាង ៩០ថ្ងៃ បន្ទាប់ពីសេចក្តីសម្រេចចុងក្រោយលើពាក្យសុំដោះលែងនៅ ក្រៅឃុំពីពេលមុន។

## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## Extraordinary Chamber in the Court of Cambodia
## Chambres Extraordinaires au sein des Tribunaux Cambodgiens

*សេចក្តីណែនាំអនុវត្ត ០២ / ២០០៧*

# ការចូលរួមនៃជនរងគ្រោះ

*គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក) ដោយពិចារណាទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងកំឡុងពេលកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានចុះហត្ថលេខាថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ (ដែលបន្ទាប់ពីនេះហៅកាត់ថា «កិច្ចព្រមព្រៀង») ។*

*ពិចារណាទៅលើច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងវិសោធនកម្មដែលត្រូវបានអនុម័តប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៧ តុលា ២០០៤ (ដែលបន្ទាប់ពីនេះ ហៅកាត់ថា «ច្បាប់អ.វ.ត.ក») ។*

*ពិចារណាទៅលើវិធានផ្ទៃក្នុងនៃអ.វ.ត.ក ដែលបានអនុម័តដោយកិច្ចប្រជុំពេញអង្គចៅក្រមនៅថ្ងៃទី១២ ខែមិថុនា ២០០៧ និងត្រូវបានចុះហត្ថលេខាឲ្យចូលជាធរមាននៅថ្ងៃទី១៩ មិថុនា ២០០៧ ។*

*អនុលោមទៅតាមវិធាន ២០(៣) នៃវិធានផ្ទៃក្នុងអ.វ.ត.ក ដែលចែងអំពីគណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង ក្នុងការធ្វើការអនុម័តលើសេចក្តីណែនាំអនុវត្តដែលទាក់ទងទៅនឹងដំណើរការនានានៃអ.វ.ត.ក ហើយដែលត្រូវពិនិត្យឡើងវិញដោយកិច្ចប្រជុំពេញអង្គនៅក្នុងកិច្ចប្រជុំពេញអង្គនាពេលបន្តបន្ទាប់ ។*

*តាមន័យដូចខាងលើនេះ សម្រេចចេញសេចក្តីណែនាំអនុវត្តអំពីការចូលរួមនៃជនរងគ្រោះ (ដែលបន្ទាប់ពីនេះហៅកាត់ថា «សេចក្តីណែនាំអនុវត្ត ០២/២០០៧»)*

**មាត្រា ១. បទប្បញ្ញត្តិទូទៅ**

*១.១ ជាការបន្ថែមទៅនឹងការចាត់ទុកជាសាក្សី ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចចូលរួមដោយសកម្មក្នុងកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) តាមរយៈការដាក់ពាក្យបណ្តឹងទៅសហព្រះរាជអាជ្ញាដូចមានចែងពិស្តារក្នុងមាត្រា ២ ខាងក្រោម ឬដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទៅសហចៅក្រមស៊ើបអង្កេត ឬនៅអង្គជំនុំជម្រះសាលាដំបូង ដូចមានចែងពិស្តារនៅក្នុងមាត្រា ៣ ខាងក្រោម ។*

*១.២ អង្គភាពជនរងគ្រោះនៃអ.វ.ត.ក គឺជាកន្លែងទាក់ទងតែមួយគត់សម្រាប់ជនរងគ្រោះទាំងអស់ ឬតំណាងរបស់ពួកគេ ក្នុងការបំពេញបែបបទ ដែលចាំបាច់សម្រាប់ចូលរួមនៅក្នុងដំណើរការជំនុំជម្រះ ។ អង្គភាពជនរងគ្រោះអាចទាក់ទងបានដោយផ្ទាល់សម្រាប់រាល់ព័ត៌មាន និងការគាំទ្រទាក់ទងទៅនឹងការចូលរួមរបស់ជនរងគ្រោះតាមអាសយដ្ឋានដូចខាងក្រោម ÷*

*អង្គភាពជនរងគ្រោះនៃអ.វ.ត.ក*

*ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌដង្កោ*

*រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

គេហទំព័រៈ www.eccc.gov.kh

លេខទូរស័ព្ទៈ ៨៥៥-២៣-២១៩-៨១៤

អាសយដ្ឋានអ៊ីម៉ែលៈ victimsunit@eccc.gov.kh

១.៣ ជាវិធានការអន្តរកាល រហូតដល់ពេលអង្គភាពជនរងគ្រោះដំណើរការ បណ្តឹង និងពាក្យសុំចូលរួមជាភាគីរដ្ឋប្បវេណីត្រូវដាក់ដោយផ្ទាល់ទៅក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ឬការិយាល័យសហចៅក្រមស៊ើបអង្កេត ទៅតាមដំណាក់កាលដែលសមស្រប ។

**មាត្រា ២.នីតិវិធី និងទម្រង់បែបបទនៃការដាក់ពាក្យប្តឹងទៅការិយាល័យសហព្រះរាជអាជ្ញា**

២.១ សហព្រះរាជអាជ្ញា ទទួលខុសត្រូវក្នុងការពិចារណាទៅលើរាល់ពាក្យប្តឹងជាលាយលក្ខណ៍អក្សរ ឬព័ត៌មានទាំងឡាយណាអំពីការចោទប្រកាន់នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ។

២.២ បុគ្គល ឬអង្គការ ឬប្រភពណាផ្សេង ដែលជាសាក្សី ឬជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនោះ ឬបានដឹងពត៌អំពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះ អាចដាក់ពាក្យបណ្តឹង ឬជូនព័ត៌មានទៅសហព្រះរាជអាជ្ញា ។ សមាគមជនរងគ្រោះ ឬមេធាវីជនរងគ្រោះអាចដាក់ពាក្យប្តឹង ក្នុងនាមសមាជិកសមាគមនោះ ឬក្នុងនាមកូនក្តីរបស់ខ្លួនបាន ។

២.៣ អ្នកប្តឹងត្រូវផ្តល់ព័ត៌មានដូចខាងក្រោមៈ

ក. អត្តសញ្ញាណរបស់អ្នកប្តឹង

ខ. កម្មវត្ថុនៃបណ្តឹង

គ. សេចក្តីសង្ខេបនៃអង្គហេតុឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ។

ឃ. ក្រៅពីនេះ ពាក្យប្តឹងត្រូវមាន

- ព័ត៌មានពិស្តារអំពីសាក្សីសំខាន់ៗ
- ភស្តុតាងទាំងឡាយដែលអ្នកប្តឹងមាន និង
- ការបង្ហាញអំពីគោលបំណងរបស់អ្នកប្តឹងថា នឹងចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលការចាប់ផ្តើមការស៊ើបអង្កេតចំពោះសំណុំរឿងនោះ ។

២.៤ ពាក្យប្តឹងត្រូវធ្វើតាមទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះដូចមាននៅក្នុង (ឧបសម្ព័ន្ធ «ក») ។ ពាក្យបណ្តឹងត្រូវបញ្ជូន ឬផ្ញើមកអង្គភាពជនរងគ្រោះដូចមានអាសយដ្ឋាននៅក្នុងមាត្រា១.២ ខាងលើ ។

២.៥ អង្គភាពជនរងគ្រោះអាចជួយអ្នកប្តឹងក្នុងការបំពេញពាក្យប្តឹងរបស់ពួកគេ ក៏ប៉ុន្តែ មានត្រឹមតែជំនួយផ្នែករដ្ឋបាលប៉ុណ្ណោះ ហើយការផ្តល់ជំនួយនេះមិនត្រូវយល់ថារួមបញ្ចូលទាំងជំនួយផ្នែកហិរញ្ញវត្ថុ ឬជំនួយផ្នែកច្បាប់ឡើយ ។

២.៦ អង្គភាពជនរងគ្រោះត្រូវបញ្ជូនរាល់ពាក្យប្តឹងទៅការិយាល័យសហព្រះរាជអាជ្ញា ។ ពាក្យប្តឹងទាំងនោះនឹងត្រូវចុះក្នុងបញ្ជីដែលគ្រប់គ្រងដោយក្រឡាបញ្ជីនៃការិយាល័យសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាអាចស្នើសុំឲ្យអង្គភាពជនរងគ្រោះជួយក្នុងការផ្តល់ការជូនដំណឹងទៅអ្នកប្តឹងវិញ ។

២.៧ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក ពាក្យប្តឹងទាំងនោះមិនអាចជាប្រភពផ្តើមធ្វើការចោទប្រកាន់ជាស្វ័យប្រវត្តិអំពីបទឧក្រិដ្ឋបានទេ ហើយសហព្រះរាជអាជ្ញាត្រូវធ្វើការសម្រេចដោយឆន្ទានុសិទ្ធិ ថាតើត្រូវតម្កល់បណ្តឹងទុកឥតចាត់ការ ឬបញ្ចូលបណ្តឹងនោះទៅក្នុងរឿងដែលការស៊ើបអង្កេតបឋមកំពុងដំណើរការ ឬបើកការស៊ើបអង្កេតបឋម ឬបញ្ចូលពាក្យប្តឹងនោះដោយផ្ទាល់ទៅសហចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការសម្រេចទៅអ្នកប្តឹងជាបន្ទាន់ តាមដែលអាចធ្វើទៅបាន

និងក្នុងគ្រប់ករណីទាំងអស់ មិនត្រូវឲ្យលើសពី៦០ (ហុកសិប) ថ្ងៃ គិតពីថ្ងៃចុះពាក្យប្តឹង ។

២.៨ ដោយអនុលោមទៅតាមវិធានផ្ទៃក្នុងនៃអ.វ.ត.ក សហព្រះរាជអាជ្ញាអាចកែប្រែ ការសម្រេចចិត្តរបស់ខ្លួនគ្រប់ពេលបាន ក្នុងករណីនេះត្រូវជូនដំណឹងទៅអ្នកប្តឹងពីសេចក្តីសម្រេចនេះឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន និងក្នុងគ្រប់ករណីទាំងអស់មិនត្រូវឲ្យលើសរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។

២.៩ អង្គភាពជនរងគ្រោះ និងសហព្រះរាជអាជ្ញាត្រូវធានាអំពីភាពសម្ងាត់នៃរាល់ពាក្យប្តឹងដែលដាក់នៅអ.វ.ត.ក ។

**មាត្រា ៣.ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

៣.១ ជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃ អ.វ.ត.ក អាចចូលរួមក្នុងកិច្ចដំណើរការជំនុំជម្រះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនៃឧក្រិដ្ឋកម្មនោះ ។

៣.២ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ដើម្បីអាចឲ្យចាត់ទុកថាជាជនរងគ្រោះ ដែលស្ថិតនៅក្នុងគោលបំណងរបស់ អ.វ.ត.ក ។

ក. ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មណាមួយស្ថិតនៅក្នុងយុត្តាធិការនៃអ.វ.ត.ក ។

ខ. ការទទួលរងព្យសនកម្មត្រូវតែជា ÷

- ការខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត និង
- ជាផលលំបាកដោយផ្ទាល់ពីឧក្រិដ្ឋកម្មនោះជាព្យសនកម្មដោយផ្ទាល់ខ្លួន និងបានកើតមានពិតប្រាកដមកទល់ពេលបច្ចុប្បន្ន ។

គ. ការខូចខាតផ្លូវចិត្ត អាចគិតទាំងការស្លាប់ញាតិសន្តាន ដែលជាជនរងគ្រោះដោយសារឧក្រិដ្ឋកម្មទាំងនោះ ។

ឃ. ជនរងគ្រោះទាំងអស់ដែលបានបំពេញលក្ខណៈវិនិច្ឆ័យទាំងអស់នេះ មានសិទ្ធិដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយគ្មានការរើសអើងចំពោះលក្ខណៈវិនិច្ឆ័យដូចជា លំនៅស្ថានបច្ចុប្បន្ន ឬសញ្ជាតិឡើយ ។

៣.៣ ជនរងគ្រោះអាចដាក់ពាក្យសុំដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែនៅពេលដែលសំណុំរឿងស្ថិតនៅក្នុងកិច្ចស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេត ឬដែលត្រូវបានបញ្ជូនទៅអង្គជំនុំជម្រះ ។

៣.៤ ពាក្យសុំត្រូវដាក់ទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះទៅតាមករណីសមស្របតាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ។

៣.៥ អង្គភាពជនរងគ្រោះអាចជួយគាំទ្រអ្នកដាក់ពាក្យប្តឹងក្នុងការបំពេញបែបបទ និងបញ្ជូនបែបបទពាក្យសុំនោះទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំដែលពាក់ព័ន្ធ តាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ។

៣.៦ រាល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវមានព័ត៌មានដូចខាងក្រោមៈ

ក. ព័ត៌មានពិស្តារដែលអាចឲ្យធ្វើការបញ្ជាក់ថាអ្នកដាក់ពាក្យបំពេញលក្ខខណ្ឌជាជនរងគ្រោះ

ខ. ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់

គ. លំនៅស្ថានរបស់ជនរងគ្រោះ ការិយាល័យសមាគមជនរងគ្រោះដែលបានចុះបញ្ជីដែលជនរងគ្រោះជាសមាជិក ឬ អាសយដ្ឋានរបស់មេធាវីទៅតាមការសមស្រប ដែលអាចប្រើប្រាស់សម្រាប់ការជូនដំណឹង ។ នៅពេលដែលអាសយដ្ឋាននោះនៅក្រៅប្រទេសកម្ពុជា អ្នកដាក់ពាក្យស្នើសុំ ឬតំណាងត្រូវផ្តល់អាសយដ្ឋាននៅក្នុងប្រទេសកម្ពុជាដែលជាទូទៅអាសយដ្ឋាននោះគឺជាអាសយដ្ឋានរបស់អ្នកតំណាងនៃជនរងគ្រោះ ។

ឃ. ជនរងគ្រោះអាចលើកអំពីវិធានការការពារចំពោះបុគ្គលដែលបានដឹងអំពីឧក្រិដ្ឋកម្មនោះ ដូចជាការការពារអត្តសញ្ញាណនៃជននោះ ។

ង. អ្នកដែលដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវភស្តុតាងដែលបញ្ជាក់អំពីព្យសនកម្មណាមួយដែលខ្លួនទទួលរង ឬភស្តុតាងដែលចង់បង្ហាញអំពីពិរុទ្ធភាពរបស់ចារី និងជនសមគំនិតដែលត្រូវចោទ ។

៣.៧ ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានដោយបំពេញបែបបទព័ត៌មានជនរងគ្រោះ (ឧបសម្ព័ន្ធ «ក») ។ នៅពេលដែលពាក្យស្នើសុំបំពេញចប់សព្វគ្រប់ហើយ ត្រូវបញ្ជូនទៅអង្គភាពជនរងគ្រោះ ។

៣.៨ ពាក្យស្នើសុំដែលបានបំពេញហើយ អង្គភាពជនរងគ្រោះត្រូវបញ្ជូនទៅក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះទៅតាមករណីសមស្របតាមរយៈមន្ត្រីទទួលបន្ទុកសំណុំរឿងជាមួយនឹងព័ត៌មានសំខាន់ៗទាក់ទងនឹងអ្នកតំណាងរួម ។

៣.៩ ប្រសិនបើអាចធ្វើទៅបាន ចៅក្រមត្រូវសម្រេចអំពីការទទួលយកបាន ឬមិនអាចទទួលយកបាននូវពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សេចក្តីសម្រេចនេះបើកផ្លូវឲ្យមានបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬបណ្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូលទៅតាមដំណាក់កាលសមស្រប ។

៣.១០ នៅពេលដែលជនរងគ្រោះ ត្រូវបានអនុញ្ញាតឲ្យចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីហើយ អង្គភាពជនរងគ្រោះមិនមានតួនាទីនៅក្នុងដំណើរការនីតិវិធីទៀតទេ ។ ប៉ុន្តែអង្គភាពនេះក៏អាចនៅផ្តល់ការគាំទ្រក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធទៅនឹងការចូលរួមសមាជិកសមាគមជនរងគ្រោះ ការការពារតាមផ្លូវច្បាប់ និងវិធានការការពារ ។

**មាត្រា ៤ ការតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីដោយមេធាវី**

៤.១ រាល់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការនីតិវិធីនៅអ.វ.ត.កជាដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិមានអ្នកតំណាងដែលជាមេធាវីជាតិ ឬមេធាវីអន្តរជាតិដែលត្រូវសហការជាមួយមេធាវីជាតិ ។

៤.២ អង្គភាពជនរងគ្រោះត្រូវមានបញ្ជីមេធាវីជាតិ និងអន្តរជាតិដែលបានចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយជាមេធាវីដែលអាចធ្វើជាតំណាងឲ្យជនរងគ្រោះ ។

៤.៣ ប្រសិនបើជនរងគ្រោះជ្រើសរើសមេធាវីអន្តរជាតិ មេធាវីអន្តរជាតិនោះត្រូវតែសហការជាមួយមេធាវីជាតិនៅចំពោះមុខអ.វ.ត.ក ។

៤.៤ ក្រុមដើមបណ្តឹងរដ្ឋប្បវេណី អាចជ្រើសរើសមេធាវីតំណាងរួមពីបញ្ជីមេធាវីនៃអង្គភាពជនរងគ្រោះ ។ អង្គភាពជនរងគ្រោះអាចជួយក្នុងការរៀបចំឲ្យមានមេធាវីតំណាងរួមគ្នានេះ ។ ក្នុងករណីចាំបាច់ ចៅក្រមអាចតម្រូវឲ្យក្រុមដើមបណ្តឹងរដ្ឋប្បវេណីធ្វើការជ្រើសរើសមេធាវីតំណាងរួម ឬជ្រើសតាំងមេធាវីតំណាងនោះដោយខ្លួនឯង ។

**មាត្រា ៥ សមាគមជនរងគ្រោះ**

៥.១ សមាគមជនរងគ្រោះអាចជួយដើមបណ្តឹងរដ្ឋប្បវេណី តែសមាគមជនរងគ្រោះនោះមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេនៅក្នុងនីតិវិធី ។ ពួកគេគ្រាន់តែជាអ្នកតំណាងឲ្យសមាជិករបស់ខ្លួន ដែលជាដើមបណ្តឹងរដ្ឋប្បវេណី ។ អាស្រ័យហេតុនេះ សមាជិកណាមួយនៃសមាគមជនរងគ្រោះត្រូវផ្តល់ព័ត៌មានផ្ទាល់ខ្លួន នៅក្នុងពាក្យស្នើសុំជាដើមបណ្តឹងរដ្ឋប្បវេណីនោះ ។ ប៉ុន្តែពួកគេអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតផ្តល់វិធានការការពារព័ត៌មានទាំងនោះ ។

៥.២ ដើម្បីអនុញ្ញាតឲ្យសមាគមជនរងគ្រោះ ធ្វើក្នុងនាមជនរងគ្រោះដែលជាសមាជិកបាន លុះណាតែសមាគមជនរងគ្រោះនោះបានចុះបញ្ជីសមាគមនៅអង្គភាពជនរងគ្រោះ ដើម្បីធ្វើជាតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីនៃ អ.វ.ត.ក ដែលបញ្ជីនេះត្រូវបានកំណត់ឡើងដោយអង្គភាពជនរងគ្រោះ ស្ថិតនៅក្រោមការត្រួតពិនិត្យដោយសហចៅក្រមស៊ើបអង្កេតនិងអង្គជំនុំជម្រះ ។

៥.៣ ទម្រង់ពាក្យស្នើសុំដើម្បីចុះក្នុងបញ្ជីសមាគមជនរងគ្រោះអាចរកបាននៅអង្គភាពជនរងគ្រោះ ហើយអាចរកបាននៅលើ

គេហទំព័រអ.វ.ត.កដែរ ។

៥.៤ អង្គភាពជនរងគ្រោះនឹងផ្ដល់ទៅឲ្យជនរងគ្រោះ នូវបញ្ជីនៃសមាគមជនរងគ្រោះ ដែលត្រូវបានអនុញ្ញាតឲ្យធ្វើជាតំណាងជនរងគ្រោះ ។

៥.៥ ដើម្បីអាចទទួលបានការអនុញ្ញាតចុះក្នុងបញ្ជីសមាគមជនរងគ្រោះ សមាគមជនរងគ្រោះត្រូវផ្ដល់ទៅអង្គភាពជនរងគ្រោះនូវឯកសារដែលបង្ហាញថាសមាគមនោះបានចុះបញ្ជីត្រឹមត្រូវ ឬបានត្រូវបង្កើតនៅក្នុងប្រទេសណាមួយ ដែលសមាគមនោះធ្វើប្រតិបត្តិការ ។

៥.៦ សមាគមជនរងគ្រោះដែលប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ត្រូវចុះបញ្ជីទៅតាមនីតិវិធីដែលមានជាធរមាន ។ សម្រាប់ព័ត៌មានពិស្ដារបន្ថែម សូមធ្វើការទំនាក់ទំនងអាសយដ្ឋានដូចខាងក្រោមៈ

ក្រសួងមហាផ្ទៃ

អាសយដ្ឋានៈ អគារលេខ២៧៥ មហាវិថីនរោត្តម ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទៈ ៨៥៥-២៣-៧៥០-៨០២/១២១-៧០៧,៧២៦-១៤៨

លេខទូរសារៈ ៨៥៥-២៣-២១២-៧០៨/៧២៦-០៥២

អ៊ីម៉ែលៈ moi@interior.gov.kh, គេហទំព័រអាសយដ្ឋានៈ www.interior.gov.kh

៥.៧ សមាគមជនរងគ្រោះបរទេសដែលតំណាងឲ្យជនរងគ្រោះដែលមានទីលំនៅនៅបរទេស នៅចំពោះមុខអ.វ.ត.ក មិនត្រូវបានបកស្រាយថាធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ ។

៥.៨ សមាគមជនរងគ្រោះត្រូវបង្ហាញភស្តុតាងថា ខ្លួនត្រូវបានអនុញ្ញាតឲ្យធ្វើជាអ្នកតំណាងជនរងគ្រោះដែលជាសមាជិកនៃសមាគមខ្លួននៅក្នុងដំណើរការនីតិវិធីអ.វ.ត.ក ។

៥.៩ សមាគមជនរងគ្រោះទាំងអស់អាចត្រូវបានតំណាងដោយមេធាវី ទៅតាមនីតិវិធី ពិស្ដារនៅក្នុងមាត្រា៤ខាងលើ ។

៥.១០ សមាគមជនរងគ្រោះទាំងអស់ មានសិទ្ធិប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចដែលទាក់ទងទៅនឹងពាក្យស្នើសុំចុះបញ្ជីសមាគមជនរងគ្រោះនៅក្នុងអង្គភាពជនរងគ្រោះទៅអង្គបុរេជំនុំជម្រះ ។

៥.១១ នៅក្នុងករណីដែលមានការបដិសេធ ឬមិនមានសេចក្ដីសម្រេចនៃអង្គភាពជនរងគ្រោះ សមាគមជនរងគ្រោះអាចប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះក្នុងរយៈពេល១៥ថ្ងៃ (ដប់ប្រាំ) គិតពីថ្ងៃទទួលបានការជូនដំណឹងអំពីសេចក្ដីសម្រេចចិត្តរបស់ប្រធានអង្គភាពជនរងគ្រោះ ឬនៅបញ្ចប់នៃរយៈពេល ៣០ថ្ងៃ (សាមសិប) ទៅតាមការសមស្រប ។

៥.១២ បើទោះបីជាមានជនរងគ្រោះមួយចំនួនជ្រើសរើសវិធីចូលរួមតាមរយៈសមាគមជនរងគ្រោះក៏ដោយ វាមិនប៉ះពាល់ដល់សិទ្ធិរបស់ជនរងគ្រោះដទៃទៀត ក្នុងការចូលរួមជាភាគីរដ្ឋប្បវេណីនៅក្នុងសំណុំរឿងដូចគ្នានោះទេ ។

**មាត្រា ៦ ការដាក់ និងការជូនដំណឹងអំពីឯកសារ**

៦.១ នៅពេលដែលពាក្យស្នើសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានទទួលហើយ រាល់ការដាក់ឯកសារ និងការជូនដំណឹងអំពីឯកសារដែលទាក់ទងទៅនឹងសំណុំរឿងនោះត្រូវតែធ្វើឡើងជាមួយក្រឡាបញ្ជីនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំដែលពាក់ព័ន្ធតាមរយៈមន្ត្រីទទួលបន្ទុកកិច្ចការសំណុំរឿង ដែលធ្វើចំណាត់ការលើសំណុំរឿងនោះ ដោយអនុលោមទៅតាមសេចក្ដីណែនាំអនុវត្តក្នុងការដាក់ឯកសារនៅអ.វ.ត.ក ។

៦.២ ជនរងគ្រោះ មេធាវីជនរងគ្រោះ និងសមាគមជនរងគ្រោះមានកាតព្វកិច្ចក្នុងការផ្ដល់ព័ត៌មានអំពីអាសយដ្ឋាននៅក្នុងប្រទេសកម្ពុជា សម្រាប់គោលបំណងក្នុងមាត្រានេះ ។ (ដកស្រង់អត្ថន័យដើមទាំងស្រុងពីឯកសាររបស់អ.វ.ត.ក)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

*ឧបសម្ព័ន្ធ "ក"*

☐ ការិយាល័យសហព្រះរាជអាជ្ញា
☐ ការិយាល័យសហចៅក្រមស៊ើបអង្កេត

សំណុំរឿងលេខ:

# ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ

## ផ្នែក "ក"

**ព័ត៌មានផ្ទាល់ខ្លួននៃជនរងគ្រោះ**

| | |
|---|---|
| ១. នាមត្រកូល និងនាមខ្លួន: | ២. ភេទ ☐ ប្រុស ☐ ស្រី |
| ៣. ទីកន្លែងកំណើត: | ៤. សញ្ជាតិ: |
| ៥. អាយុ/ថ្ងៃខែឆ្នាំកំណើត (ប្រសិនបើស្គាល់ ថថ/ខខ/ឆឆឆឆ): | ៦. មុខរបរ: |
| ៧. ស្ថានភាពគ្រួសារ ☐ នៅលីវ ☐ រៀបការ ☐ លែងលះ ☐ ពោះម៉ាយ/មេម៉ាយ ☐ ផ្សេងៗ | |
| ៨. ឈ្មោះឪពុក ឬអាណាព្យាបាល: | ឈ្មោះម្តាយ: |
| ៩. តើមានអ្នកនៅក្នុងបន្ទុកចំនួនប៉ុន្មាននាក់? *សូមសរសេរជាលេខ.* | |
| ១០. តើអ្នកធ្លាប់មានពិការភាពពីមុនឬទេ? ☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើឆ្លើយថា បាទ/ចាស សូមរៀបរាប់លំអិត: | |
| ១១. តើភស្តុតាងនៃអត្តសញ្ញាណខាងក្រោមណាមួយដែលអ្នកមាន? *សូមបញ្ជាក់ជាលេខ* | |
| **ប្រភេទនៃភស្តុតាងនៃអត្តសញ្ញាណ** | **លេខ និង យោងផ្សេងៗ** |
| ☐ លិខិតឆ្លងដែន | |
| ☐ បណ្ណបើកបររថយន្ត | |
| ☐ អត្តសញ្ញាណប័ណ្ណ (ដូចជាកាតសំគាល់និស្សិត, បុគ្គលិក) | |
| ☐ លិខិតបញ្ជាក់ពីអាជ្ញាធរដែនដី | |
| ☐ លិខិតចុះឈ្មោះនៅក្នុងជំរុំ | |
| ☐ កាតសំគាល់ចេញដោយអង្គការមនុស្សធម៌(ដូចជា UNHCR, WFP) | |
| ☐ ឯកសារពន្ធ | |

| | |
|---|---|
| ☐ ប័ណ្ណបោះឆ្នោត | |
| ☐ ផ្សេងៗ | |
| ☐ គ្មាន | |

**សំរាប់អង្គភាពជនរងគ្រោះតែប៉ុណ្ណោះ**

**ពាក្យស្នើសុំ:**

☐ សាក្សី ☐ ពាក្យប្តឹង ☐ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

**សំរាប់:**

☐ សហព្រះរាជអាជ្ញា ☐ សហចៅក្រមស៊ើបអង្កេត

| | |
|---|---|
| ១២. សូមបំពេញគ្រប់ចំនុចដែលតំរូវការសំរាប់អ្នក | |
| ☐ អាសយដ្ឋានបច្ចុប្បន្ន ☐ ប្រសិនបើអ្នកមិនមានអាសយដ្ឋានពិតប្រាកដ សូមផ្តល់នូវអាសយដ្ឋានចុងក្រោយគេ | |
| លេខ/ប្លុក: | ផ្លូវ: |
| ក្រុម/ភូមិ: | ឃុំ/សង្កាត់: |
| ស្រុក/ខណ្ឌ: | ខេត្ត/ក្រុង: |
| ប្រទេស: | |
| ១៣. អាសយដ្ឋានសំរាប់ទំនាក់ទំនង *សូមគូសទៅតាមភាពសមស្រប.* | |
| ☐ ខ្ញុំចង់អោយទាក់ទងទៅតាមអាសយដ្ឋានដូចមាននៅក្នុងចំនុចលេខ១២. | |
| ☐ ខ្ញុំចង់អោយទាក់ទងតាមរយះបុគ្គលដែលជាតំណាងរបស់ខ្ញុំដូចខាងក្រោម:<br>☐ មេធាវី: ☐ សមាគមជនរងគ្រោះ: | |
| ☐ ខ្ញុំចង់អោយទាក់ទងទៅតាមអាសយដ្ឋានដូចខាងក្រោម: | |
| លេខ/ប្លុក: | ផ្លូវ: |
| ក្រុម/ភូមិ: | ឃុំ/សង្កាត់: |
| ស្រុក/ខណ្ឌ: | ខេត្ត/ក្រុង: |
| ប្រទេស: | |
| ☐ ខ្ញុំចង់អោយទាក់ទងទៅតាមទូរស័ព្ទនេះ: | |



Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

| |
|---|
| តើអ្នកធ្លាប់ដាក់ពាក្យប្តឹង ឬ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ឬកន្លែងណាមួយផ្សេងទៀត?<br>☐ បាទ/ចាស ☐ ទេ<br>ប្រសិនបើឆ្លើយថា បាទ/ចាស សូមមេត្តាបញ្ជាក់អំពីពាក្យស្នើសុំ នៅពេលណា និង ទីកន្លែងណា<br>ពាក្យស្នើសុំ<br>ទីកន្លែង: ថ្ងៃ ខែ ឆ្នាំ |

## ផ្នែក "ខ"

### ព័ត៌មានទាក់ទងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់

*សូមភ្ជាប់នូវចំលើយទាក់ទងនឹងផ្នែកនេះដោយក្រដាសដាច់ដោយឡែកប្រសិនបើចាំបាច់*

| |
|---|
| ១. សូមផ្តល់នូវព័ត៌មានពិស្តារអំពីឧក្រិដ្ឋកម្ម |
| ទីកន្លែង (*ភូមិ, ស្រុក ,តំបន់, ភូមិភាគ)*: |
| កាលបរិច្ឆេទ (ថថ/ខខ/ឆឆឆឆ): |
| ការពិពណ៌នាអំពីឧក្រិដ្ឋកម្ម*(តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើង ហើយកើតឡើងដោយរបៀបណា?)*: |
| ២. តើអ្នកណាដែលអ្នកជឿជាក់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ហើយមូលហេតុអ្វីដែលអ្នកជឿជាក់បែបនេះ?<br>*សូមឆ្លើយសំណួរនេះទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន* |
| ៣. តើអ្នកជាជនរងគ្រោះក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៤. តើអ្នកជាសាក្សីនៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៥. តើអ្នកបានដឹងអំពីជនរងគ្រោះ ឬសាក្សីនៅក្នុងឧក្រិដ្ឋកម្មទាំងនោះដែរឬទេ? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស (និងប្រសិនបើអ្នកមានលទ្ធភាព), សូមផ្តល់ឈ្មោះនិងអាសយដ្ឋានរបស់ពួកគេ, លើកលែងតែអ្នកដឹងថាពួកគេចង់នៅជាអនាមិក, ឬវាអាចធ្វើអោយមានហានិភ័យចំពោះអ្នក ឬអ្នកណាផ្សេងទៀត)*: |
| ៦. តើអ្នកមានទំនាក់ទំនងអ្វីជាមួយសាក្សីទាំងនោះ(ជាក្រុមគ្រួសារ, អ្នកជិតខាង, មិត្តភក្តិ, ។ល។)? ☐ បាទ/ចាស ☐ ទេ<br>*(ប្រសិនបើឆ្លើយថាបាទ/ចាស, សូមបញ្ជាក់)*: |
| ដើម្បីអនុញ្ញាតអោយដើមបណ្តឹងរដ្ឋប្បវេណីអាចចូលរួមបាន, ព្យសនកម្មត្រូវតែជា ក) រូបកាយ, សម្ភារៈ ឬ ផ្លូវចិត្ត; ខ) ប៉ះពាល់ដោយផ្ទាល់ពីបទល្មើសនោះជាលក្ខណៈបុគ្គល និងមានឥទ្ធិពលរហូតមកដល់ពេលបច្ចុប្បន្ន។ |



Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

## ផ្នែក "គ"

### ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

| |
|---|
| *អ្នកត្រូវបំពេញក្នុងផ្នែកនេះ ប្រសិនបើអ្នកមានបំណងចង់ចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការស៊ើបសួរ* |
| ១. សូមបញ្ជាក់អំពីដំណាក់កាលនីតិវិធីដែលអ្នកមានបំណងចង់ចូលរួម<br>សំណុំរឿងលេខ: |
| ២. សូមបញ្ជាក់អំពីព្យសនកម្ម, ការបាត់បង់ឬ ផលវិបាកដែលបានទទួល និង សូមធ្វើការអត្ថាធិប្បាយដោយសង្ខេប<br>(ដូចជាព្យសនកម្មនៅលើរូបកាយ, ផ្លូវចិត្ត និងភាពតានតឹងនៅក្នុងចិត្ត, បាត់បង់ ឬខូចខាតនូវទ្រព្យសម្បត្តិ): |
| ៣. តើអ្នកត្រូវបានវេជ្ជបណ្ឌិតពិនិត្យក្រោយពីព្រឹត្តការណ៍នោះកើតឡើងឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៤. តើអ្នកបានព្យាបាលដោយប្រើប្រាស់ថ្នាំ ឬដោយវិធីព្យាបាលផ្លូវចិត្តដែរឬទេ? ☐ បាទ/ចាស ☐ ទេ |
| ៥. ប្រសិនបើបាទ/ចាស តើអ្នកមានកំណត់ត្រាអំពីការប្រើប្រាស់ថ្នាំ ឬដោយវិធីព្យាបាលផ្លូវចិត្តទាំងនោះដែរឬទេ?<br>☐ បាទ/ចាស ☐ ទេ<br>*ប្រសិនបើឆ្លើយថាបាទ/ចាស, សូមគូសទៅតាមភាពសមស្របខាងក្រោម និងផ្តល់ឯកសារចំលងមួយច្បាប់ប្រសិនបើអាច.*<br>☐ របាយការណ៍វេជ្ជបណ្ឌិត, មន្ទីរពេទ្យ, ឬមណ្ឌលសុខភាព ☐ កម្មរស្មី X ☐ វេជ្ជបញ្ជា/វិកិយប័ត្រថ្នាំ<br>☐ ផ្សេងៗ សូមបញ្ជាក់ ☐ មិនមានអ្វីទាំងអស់ដូចខាងលើ |
| ៦. តើស្ថានភាពនៃព្យសនកម្មនោះមានរហូតមកដល់សព្វថ្ងៃដែរឬទេ? ☐ បាទ/ចាស ☐ ទេ<br>*ប្រសិនបើឆ្លើយបាទ/ចាស សូមបញ្ជាក់អោយបានពិស្តារ:* |
| ៧. តើអ្នកមានបំណងចងទាមទារអោយមានសំណងជាលក្ខណៈសមូហភាព ឬជាផ្លូវចិត្តណាមួយដែរឬទេ? ☐ បាទ/ចាស ☐ ទេ<br>*ប្រសិនបើឆ្លើយបាទ/ចាស សូមបញ្ជាក់អោយបានពិស្តារ:* |



Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

# ផ្នែក "ឃ"

## ហត្ថលេខា

១. ហត្ថលេខាជនរងគ្រោះ

*សូមមេត្តាចុះហត្ថលេខា ឬផ្តិតម្រាមដៃ និងចុះកាលបរិច្ឆេទនៅលើបែបបទនេះ ទោះបីជានរណាម្នាក់ធ្វើក្នុងនាមរបស់អ្នក ឬ មាននរណាម្នាក់ជួយអ្នកក្នុងការបំពេញបែបបទនេះ*

ខ្ញុំសូមបញ្ជាក់ថា:

- ព័ត៌មានទាំងអស់ដែលបានផ្តល់ក្នុងបែបបទនេះពិតជាត្រឹមត្រូវពិតប្រាកដមែន ប្រសិនបើមានចំនុចណាមិនពិត ខ្ញុំសូមទទួលទោសតាមច្បាប់ជាធរមាន

- ខ្ញុំមានបំណងចង់ចូលរួមក្នុងនីតិវិធីនៅចំពោះមុខអ.វ.ត.ក ជា: ☐ សាក្សី ☐ ជាអ្នកប្តឹង ☐ ដើមបណ្តឹងរដ្ឋប្បវេណី

*ប្រសិនបើចង់តាំងខ្លួនជា "ដើមបណ្តឹងរដ្ឋប្បវេណី", សូមបញ្ជាក់អោយច្បាស់ថាបានបំពេញនៅក្នុងផ្នែក "គ"*

ទីកន្លែងធ្វើ: ថ្ងៃ: ខែ: ឆ្នាំ:

*ហត្ថលេខា ឬស្នាមម្រាមដៃជនរងគ្រោះ និង ឈ្មោះ*

ឈ្មោះសាក្សី:

ហត្ថលេខាសាក្សីក្នុងការបំពេញ: ហត្ថលេខា.........................................................

២.ហត្ថលេខាបុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះដោយមានការយល់ព្រមពីជនរងគ្រោះ

ដោយមានការយល់ព្រមពីជនរងគ្រោះ:

ខ្ញុំឈ្មោះ ,

*ឈ្មោះជនរងគ្រោះ*

យល់ព្រមអោយឈ្មោះ ធ្វើជាអ្នកតំណាង

*សរសេរឈ្មោះបុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះ, ក្នុងនាមខ្ញុំ*

អោយបំពេញបែបបទនិងដាក់ពាក្យសុំនេះ

ទីកន្លែងធ្វើ: ថ្ងៃ: ខែ: ឆ្នាំ:

*ហត្ថលេខាឬស្នាមម្រាមដៃរបស់បុគ្គលដែលជាអ្នកតំណាងអោយជនរងគ្រោះ និងឈ្មោះ*

ឈ្មោះសាក្សី

ហត្ថលេខាសាក្សីក្នុងការបំពេញបែបបទនេះ: ហត្ថលេខា.........................................................

5

Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

នៅមុនពេលដាក់បែបបទពាក្យស្នើសុំនេះ, សូមពិនិត្យមើលឡើងវិញ និងគូសនៅខាងក្រោមនេះទៅតាមការសមស្រប:

☐ ខ្ញុំបានភ្ជាប់មកជាមួយក្នុងពាក្យសុំនេះនូវឯកសារដូចខាងក្រោម:

១.

២.

៣.

☐ ខ្ញុំបានចុះហត្ថលេខា ឬផ្តិតម្រាមដៃនៅគ្រប់ទំព័រនៃបែបបទ និង ឯកសារដែលបានដាក់ភ្ជាប់មកជាមួយ

សូមបញ្ជាក់អំពីចំនួនទំព័រសរុបនៃទំព័ររបស់បែបបទនេះរួមទាំងទំព័របន្ថែម និងឯកសារភ្ជាប់ផ្សេងៗទៀត:

| ជនរងគ្រោះ: | បុគ្គលតំណាងអោយជនរងគ្រោះ: |
|---|---|
| ☐ ខ្ញុំបានផ្តល់សេចក្តីចំលងឯកសារជាភស្តុតាងនៃអត្តសញ្ញាណឆ្លើយតបទៅនឹងតំរូវការនៅក្នុងសំនួរទី១១ នៃផ្នែក “ក” ។<br>☐ ខ្ញុំបានផ្តល់ព័ត៌មានឆ្លើយតបនឹងតំរូវការនៅក្នុងសំនួរទី១៣ នៃផ្នែក “ក” ។<br>☐ ខ្ញុំបានចុះហត្ថលេខា ឬផ្តិតម្រាមនៅក្នុងប្រអប់ទី១នៅក្នុងផ្នែក “ឃ” ។ | ☐ ខ្ញុំបានចុះហត្ថលេខា ឬ ផ្តិតម្រាមដៃនៅក្នុងប្រអប់ទីពីរ នៅក្នុងផ្នែក “ឃ” |

**កំណត់ចំណាំ**

នៅពេលដែល អ.វ.ត.ក ទទួលបែបបទនេះ អ្នកនឹងទទួលបាននូវការបញ្ជាក់ ។ ការបញ្ជាក់នេះនឹងផ្តល់ទៅអ្នកជាមួយនឹងលេខដែលបានចុះបញ្ជីដែលអ្នកត្រូវប្រើនៅក្នុងការទំនាក់ទំនងជាមួយតុលាការ ។ ប្រសិនបើអ្នកផ្តល់ព័ត៌មានបន្ថែមមកតុលាការ សូមប្រើប្រាស់លេខដែលបានផ្តល់អោយនេះ ដើម្បីអោយគេអាចបន្ថែមនៅលើពាក្យស្នើសុំរបស់អ្នក ។ សូមបញ្ជាក់ថាដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវការប្រើប្រាស់ពេលវេលវែង និងអ.វ.ត.ក អាចត្រូវការប្រើប្រាស់ពេលវេលាមួយដើម្បីធ្វើការសំរេចលើពាក្យស្នើសុំ ។

ការដាក់បែបបទនេះគឺធ្វើឡើងដោយមិនមានគិតថ្លៃ ។

អង្គភាពជនរងគ្រោះអាចទំនាក់ទំនងបានតាមរយៈអាសយដ្ឋានខាងក្រោម ឬតាមរយៈអ៊ីម៉ែល victimsunit@eccc.gov.kh ។

6

Extraordinary Chambers in the Courts of Cambodia National Road 4 ,Chaom Chau , Dangkao Phnom Penh
Mail Po Box 71 ,Phnom Penh Tel:+855(0)23 218914 Fax:023 218941
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Chaom CHau, Damgkao, Phnom Penh
Boite postale 71, Phnom Penh. Tel : Tel:+855(0)23 218914 Fax:023 218941

# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ៈ
# កំណែទម្រង់គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

### ***៣) ឧទាហរណ៍អំពីតុលាការចម្រុះ***

*យើងឈប់ពិនិត្យមើលការពិពណ៌នាទិដ្ឋភាពផ្នែកទ្រឹស្តី និងគោលបំណងនៃសក្តានុពលរបស់គំរូតុលាការចម្រុះ ផ្នែកនេះនឹងរៀបរាប់អំពីតុលាការចម្រុះដែលត្រូវបានបង្កើតឡើងដោយផ្តោតទៅលើចំណុចខ្វះខាតរបស់តុលាការទាំងនោះ ។ ទី១) ផ្នែកនេះនឹងពណ៌នាអំពីតុលាការចម្រុះដែលត្រូវបានបង្កើតឡើងមុនគេនៅទីម័រខាងកើត ដោយធ្វើការកត់សម្គាល់ថា តុលាការនេះជួបប្រទះកង្វះខាតផ្នែកថវិកានិងបញ្ហានយោបាយធ្ងន់ធ្ងរ ។ ហ៊ុមព័ទ្ធទៅដោយភាពអសកម្ម រាប់តាំងពីការផ្ទេរអំណាចដោយគ្មានការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិរហូតដល់ការបរាជ័យរបស់កម្មវិធីកសាងសមត្ថភាពសម្រាប់មន្ត្រីទីម័រខាងកើតដែលគ្មានបទពិសោធន៍ តុលាការនេះមិនបានប្រើប្រាស់សក្តានុពលរបស់ខ្លួនឲ្យអស់ពីលទ្ធភាពទេ ។ ទី២) ផ្នែកនេះសង្ខេបការវិវត្តនៃបញ្ញត្តិលេខ១៦៤របស់ក្រុមការងាររបស់តុលាការកូសូវ៉ូ ដោយពិនិត្យត្រួសៗអំពីវិធីដែលកូសូវ៉ូបានអនុវត្តដើម្បីកែលម្អគំរូតុលាការចម្រុះនេះដោយប្របាច់បញ្ចូលបុគ្គលិកអន្តរជាតិទៅក្នុងប្រព័ន្ធតុលាការក្នុងស្រុកដើម្បីបង្កើនល្បឿននិងកែលម្អគុណភាពនៃការសម្រេចចិត្តក្នុងស្រុក ។ ទី៣) ផ្នែកនេះសិក្សាអំពីតុលាការពិសេសនៅប្រទេសសេរ៉ាឡេអូន និងធ្វើការសន្មតថាតុលាការនេះសម្រេចបានស្តង់ដារ ប្រសិទ្ធភាពខ្ពស់និងការផ្សព្វផ្សាយដល់ប្រជាជនក្នុងស្រុកបានច្រើនបំផុត ក្នុងចំណោមតុលាការដែលត្រូវបានបង្កើតក្នុងពេលកន្លងមក បើទោះបីជានៅមានផ្នែកជាច្រើនដែលត្រូវធ្វើការកែលម្អក៏ដោយ ។ ទី៤) ផ្នែកនេះពិនិត្យទៅលើអង្គជំនុំជម្រះវិសាមញ្ញនៅកម្ពុជា បើទោះបីជាការវិភាគនឹងផ្តោតទៅលើរចនាសម្ព័ន្ធរបស់អង្គជំនុំជម្រះនិងដំណើរការបង្កើតវា ជាជាងការវាយតម្លៃ ប្រតិបត្តិការដែលមិនទាន់ចាប់ផ្តើមបានពេញលេញរបស់អង្គជំនុំជម្រះក៏ដោយ ។ ទី៥) ផ្នែកនេះរៀបរាប់ដោយសង្ខេបអំពីតុលាការពិសេសអ៊ីរ៉ាក់ ។ តុលាការកំពូលផ្នែកឧក្រិដ្ឋកម្មអ៊ីរ៉ាក់ដែលអ្នកបង្កើតតុលាការទាំងនេះខកខានមិនបានដកស្រង់យកមេរៀនពិសោធន៍របស់តុលាការចម្រុះកន្លងមក និងបានបង្កើតឲ្យមានតុលាការក្នុងស្រុកស្តង់ដារអន្តរជាតិមួយដែលប្រសិទ្ធភាពរបស់វាត្រូវរងគ្រោះដោយសារអំពើហិង្សានិងបញ្ហាច្បាប់នានា ។ ទី៦) ផ្នែកនេះវិភាគអំពីតុលាការចម្រុះថ្មីនៅប៊ូស្នៀ ដែលហាក់ដូចជាកំពុងបង្ហាញឲ្យឃើញពីគំរូតុលាការចម្រុះមួយដែលល្អបំផុត បើ*



*ប្រជាជននៅក្នុងអគារសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ*

ប្រៀបធៀបទៅនឹងតុលាការចម្រុះដែលធ្លាប់បានបង្កើតឡើងកន្លងមក ។ ដោយសារថា បញ្ហាទាំងនេះមានការវិវត្តន៍ប្រែប្រួលយ៉ាងឆាប់រហ័ស ការពិពណ៌នាទាំងនេះអាចនឹងមានការផ្លាស់ប្តូរ ។

## ក) អង្គភាពព្រហ្មទណ្ឌកម្រិតធ្ងន់ និងក្រុមប្រឹក្សាព្រហ្មទណ្ឌកម្រិតធ្ងន់ពិសេសប្រចាំតុលាការក្រុងឌីលី

នៅពេលធ្វើប្រជាមតិក្នុងឆ្នាំ១៩៩៩ នៅទីម័រខាងកើត ដើម្បីសម្រេចឯករាជ្យភាពចេញពីប្រទេសឥណ្ឌូនេស៊ី មនុស្សចំនួនជាង១០០០នាក់ត្រូវបាត់បង់ជីវិតនៅក្នុងការវាយប្រហារបង្ហូរឈាម ។ ការរំលោភបំពានសិទ្ធិមនុស្សទ្រង់ទ្រាយធំបានកើតឡើងទៅលើប្រជាជនស៊ីវិល ហើយមនុស្សជាង២៥០.០០០នាក់ បានលាក់ខ្លួន ជម្លៀស ឬត្រូវបណ្តេញចេញដោយបង្ខំឲ្យទៅរស់នៅឥណ្ឌូនេស៊ី ។ ទាហានស៊ីឈ្លួលដែលគាំទ្រប្រទេសឥណ្ឌូនេស៊ី និងកងកម្លាំងរក្សាសន្តិសុខនៅឥណ្ឌូនេស៊ីក៏បានដុតនិងបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធក្នុងទ្រង់ទ្រាយធំផងដែរ ។ ក្រោយពីមានការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដោយទាហានឥណ្ឌូនេស៊ី ដើម្បីបំភ័យសកម្មជន ដើម្បីឯករាជ្យកំហឹងរបស់សហគមន៍អន្តរជាតិបានគៀបសង្កត់រដ្ឋាភិបាលឥណ្ឌូនេស៊ី ដែលស្ទាក់ស្ទើរក្នុងការរៀបចំឲ្យមានការកាត់ទោស ។ ជាមួយនឹងវត្តមានរបស់អង្គការសហប្រជាជាតិនៅក្នុងតំបន់ជាច្រើនលើកនៅកោះទីម័រខាងកើត តែខ្វះឆន្ទៈក្នុងការប្រឈមមុខនឹងឥណ្ឌូនេស៊ី អង្គការសហប្រជាជាតិពឹងផ្អែកលើការសន្យារបស់ឥណ្ឌូនេស៊ីដែលថានឹងរៀបចំឲ្យមានការកាត់ទោសជនជាប់សង្ស័យ នៅទីក្រុងហ្សាកាតា ។

ទន្ទឹមពេលជាមួយគ្នានេះដែរ អង្គការសហប្រជាជាតិបានបង្កើតនូវស្ថាប័នមួយដែលមានលក្ខណៈជាអន្តរជាតិមួយផ្នែកនៅក្នុងទីក្រុងឌីលី ប្រទេសទីម័រខាងកើតដើម្បីផ្តន្ទាទោសឧក្រិដ្ឋជនក្នុងស្រុកទាំងឡាយណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្រិតធ្ងន់នៅប្រទេសទីម័រខាងកើត ។

រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ប្រចាំទីម័រខាងកើតបានបង្កើតនូវអង្គភាពរដ្ឋអាជ្ញា និងតុលាការដែលមានឈ្មោះថា អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ដែលស្ថិតនៅក្រោមចំណុះរបស់អគ្គរដ្ឋអាជ្ញា និងក្រុមចៅក្រមពិសេសដែលទទួលបន្ទុកលើបទល្មើសឧក្រិដ្ឋកម្រិតធ្ងន់នៅក្នុងតុលាការក្រុងឌីលី ។

តុលាការក្រុងឌីលី ត្រូវបានបង្កើតដោយរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសទីម័រខាងកើតនៅក្នុងខែមីនា ឆ្នាំ២០០០ (ព្រមពេលជាមួយនឹងតុលាការក្រុងដទៃទៀតដែរ) ដើម្បីអនុវត្តយុត្តាធិការផ្តាច់មុខទៅលើបទឧក្រិដ្ឋកម្រិតធ្ងន់បំផុត ដូចជាអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាមនិងបទល្មើសនានាប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងពេលណាមួយ ព្រមទាំងអំពើឃាតកម្ម ការរំលោភសេពសន្ថវៈ និងការធ្វើទារុណកម្ម ដែលបានប្រព្រឹត្តឡើងចន្លោះពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៩ ។ នៅខែមិថុនា ឆ្នាំ២០០០ ចៅក្រមពិសេសជាច្រើនក្រុមត្រូវបានបង្កើតឡើងនៅក្នុងតុលាការក្រុងឌីលី និងសាលាឧទ្ធរណ៍ ដែលមានសមាសភាពចៅក្រមអន្តរជាតិចំនួន២រូប និងចៅក្រមជនជាតិទីម័រ ចំនួន១រូប នៅក្នុងក្រុមនីមួយៗ ។ ដោយស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការក្រុងឌីលី ក្រុមចៅក្រមចម្រុះគ្នាទាំងនេះបានប្រើប្រាស់ទាំងច្បាប់អន្តរជាតិនិងច្បាប់ទីម័រខាងកើតដែលគ្រប់គ្រងដោយរដ្ឋបាលបណ្តោះអាសន្ន អ.ស.ប ។ ការប្រឡាច់បញ្ចូលគ្នារវាងរដ្ឋអាជ្ញាជាតិនិងអន្តរជាតិ នៅក្នុងអង្គចៅក្រមពិសេស ឆ្លុះបញ្ចាំងឲ្យឃើញនូវការរួមបញ្ចូលគ្នារវាងបុគ្គលិក រដ្ឋអាជ្ញាជាតិ និងអន្តរជាតិនៅក្នុងអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ ។

ប៉ុន្តែអកុសល តុលាការទីម័រខាងកើតដែលជាតុលាការដំបូងបំផុតទទួលបន្ទុកដោះស្រាយបទឧក្រិដ្ឋ ប្រភេទបែបនេះ ដែលបំពេញការងារនៅលើកោះមួយដែលទទួលរងការបំផ្លិចបំផ្លាញនិងមានទីតាំងនៅក្បែរប្រទេសអាណានិគមដែលមិនស្គាល់កំហុសរបស់ខ្លួនទទួលរងគ្រោះយ៉ាងដំណំ ។ ទាំងការកាត់ក្តីនៅទីក្រុងហ្សាកាតាប្រទេសឥណ្ឌូណេស៊ី និងការកាត់ក្តីដែលឧបត្ថម្ភថវិកាដោយអង្គការសហប្រជាជាតិធ្វើឡើងនៅតុលាការក្រុងឌីលី មិនបានបង្កើតឲ្យមានការទទួលខុសត្រូវដែលទន្ទឹងរង់ចាំជាយូរមកហើយ និងដែលបានសន្យាចំពោះជនរងគ្រោះជនជាតិទីម័រខាងកើតទេ ។

ដោយខ្វះមូលនិធិនិងខ្វះប្រសិទ្ធភាពនោះ អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់នេះ (SCU) បានចាប់ផ្តើមដំណើរការបានល្អ ក៏ប៉ុន្តែលទ្ធភាពនេះបានជួបប្រទះនឹងកង្វះផែនការជាយុទ្ធសាស្ត្រ កង្វះមូលនិធិ ការផ្ទេរអំណាចឆាប់ពេកទៅឲ្យយុត្តាធិការទីម័រខាងកើតដែលគ្មាន

បទពិសោធន៍ បរាជ័យនៃកម្មវិធីកសាងសមត្ថភាព និងសកម្មភាពនយោបាយក្នុងស្រុកៈ

*រដ្ឋាភិបាលប្រទេសទីម័រខាងកើត... បានដើរតួនាទីយ៉ាងសំខាន់មួយក្នុងការធ្វើឲ្យចុះអន់ថយដល់កម្មវិធីត្រួតពិនិត្យការបណ្តុះបណ្តាល ដែលជាមូលហេតុនាំឲ្យមានកង្វះខាតធនធានក្នុងការបន្តដំណើរការសាលាកាត់ក្តីនេះ នឹងធ្វើឲ្យជាប់គាំងដល់ការតែងតាំងរបស់ចៅក្រមនៅក្នុងអង្គពិគ្រោះយោបល់ពិសេស ។ មន្ត្រីក្រសួងយុត្តិធម៌បានច្រានចោលនូវសំណើជាច្រើនដែលសុំមូលនិធិសម្រាប់តុលាការនិងកម្មវិធីកសាងសមត្ថភាព ។ រឿងនេះត្រូវបានរាយការណ៍ប៉ុន្តែមិនបានបញ្ជាក់ឲ្យបានច្បាស់លាស់ថា នៅក្នុងរដូវក្តៅឆ្នាំ២០០២ ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាមេរិក (USAID) បានផ្តល់ជំនួយជាទឹកប្រាក់ចំនួន ៨,២លានដុល្លារសហរដ្ឋអាមេរិកដល់អង្គការសង្គមស៊ីវិលមួយចំនួន បន្ទាប់ពីសំណើរបស់អង្គការនេះទៅកាន់តុលាការ «ក្នុងគោលបំណងផ្តល់ថវិកាយ៉ាងច្រើននោះ» ត្រូវបានបដិសេធ... ។ បុគ្គលិកម្នាក់នៃអង្គការមូលនិធិក្រៅរដ្ឋាភិបាលមួយរបស់អូស្ត្រាលីបានបង្ហាញនូវភាពស្រងាកចិត្តជាខ្លាំងថា សំណើរបស់ខ្លួនក្នុងការផ្តល់មូលនិធិដោយគ្មានល័ក្ខខ័ណ្ឌដល់បុគ្គលិកអន្តរជាតិដែលកាន់មុខតំណែងមួយចំនួននៅក្នុងការិយាល័យការពារកូនក្តីក៏ត្រូវបានច្រានចោលដែរ... ។ ការច្រានចោលម្តងហើយម្តងទៀតរបស់ក្រសួងចំពោះសំណើសុំផ្តល់មូលនិធិនិងបុគ្គលិកអន្តរជាតិអាចមានការពាក់ព័ន្ធទៅនឹងរបៀបវារៈនយោបាយមួយដែលផ្តល់ឲ្យជនជាតិ និងភាសាព័រទុយហ្គាល់ នូវឧត្តមភាពខ្ពស់បំផុតក្នុងការក្លាយជាបុគ្គលិក និងភាសានៅក្នុងតុលាការ ។*

នយោបាយភាសាគឺជាប្រធានបទប្រែប្រួលឆាប់រហ័សរវាងរដ្ឋាភិបាលទីម័រនិងរដ្ឋបាលអង្គការសហប្រជាជាតិ ។

ចំណុចអសកម្មរបស់អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់អាចបណ្តាលមកពី«បរាជ័យជាប្រចាំរបស់អង្គការសហប្រជាជាតិក្នុងការពិភាក្សាជាមួយនឹងមន្ត្រីទីម័រខាងកើតឲ្យបានល្អិតល្អន់ប្រកបដោយអត្ថន័យ និងមានលក្ខណៈបត់បែនលើផ្នែកស្ថាប័ន» ។ ក៏ដូចជាភាពផុយគ្នា នៅក្នុងតួនាទីរបស់អង្គការសហប្រជាជាតិដែលបុគ្គលិករបស់អង្គភាពនេះជារឿយៗរវល់រវក់រវីគ្មានបទពិសោធន៍ និងគ្មានសណ្តាប់ធ្នាប់ ។ ឥទ្ធិពលតុលាការទៅលើប្រជាជនក្នុងស្រុកត្រូវខូចខាតដោយសារមិនបានផ្តល់តម្លៃដល់ការចូលរួមរបស់ប្រជាជនក្នុងស្រុក ហើយយុត្តិសាស្ត្ររបស់ខ្លួនត្រូវបានរិះគន់ជាចំហ ដោយសារការខកខានមិនបានប្រកាន់យកនូវដំណើរការកាត់ក្តីឲ្យបានត្រឹមត្រូវតាមស្តង់ដារ ។ ភាពយឺតយ៉ាវនិងគុណភាពមិនគួរឲ្យទុកចិត្តនៃការស៊ើបអង្កេតរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ.... បាននាំឲ្យមានការបាត់បង់នូវជំនឿទុកចិត្ត ក្នុងចំណោមប្រជាជនទីម័រខាងកើតទៅលើសមត្ថភាពឬឆន្ទៈរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិក្នុងការនាំយកឧក្រិដ្ឋជនមកកាត់ទោស... [ហើយ]ឥឡូវនេះអង្គការសំខាន់ៗលែងមានឆន្ទៈសហការជាមួយអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ទៀតហើយ» ។

ការងារតុលាការកាន់តែមានភាពស្មុគស្មាញខ្លាំងឡើងៗ ដោយសារតែអង្គការសហប្រជាជាតិធ្វើកិច្ចការដ៏លំបាកមួយក្នុងការធ្វើសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមួយ នៅទីម័រខាងកើត ក៏ប៉ុន្តែមិនបានយកចិត្តទុកដាក់ឲ្យបានគ្រប់គ្រាន់ទៅលើច្បាប់ប្រពៃណីរបស់ទីម័រខាងកើត «ដែលល្បីសុសសាយថា ស្មុគស្មាញ ប៉ុន្តែជាញឹកញាប់មានសារសំខាន់» ។

តួនាទីរបស់អង្គការសហប្រជាជាតិត្រូវបានធ្វើឲ្យកាន់តែស្មុគស្មាញឡើងថែមទៀត ដោយសារតែការបញ្ចប់អាណត្តិរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០២ នៅពេលដែលរដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិបញ្ចប់ការងាររបស់ខ្លួន ហើយទីម័រខាងកើតបានក្លាយជារដ្ឋមួយឯករាជ្យដោយមានបេសកកម្មគាំទ្ររបស់អង្គការសហប្រជាជាតិនៅក្នុងប្រទេសទីម័រខាងកើតជំនួសមុខងារមួយចំនួនរបស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ ។

ការបង្កើតស្ថាប័ននៅក្នុងប្រទេសទីម័រខាងកើត គួរតែផ្តោតការយកចិត្តទុកដាក់ឲ្យបានច្រើនទៅលើការនាំយកជំនាញឬឯកទេសអន្តរជាតិ មកបម្រើឲ្យរយៈពេលអន្តរកាលមួយ ដោយតែងតាំងសមភាគីជនជាតិទីម័រខាងកើតជាច្រើន ឲ្យធ្វើជាអនុប្រធាននៅក្នុងរយៈពេលសាកល្បងមួយ និងដោយមានសមភាគីអន្តរជាតិម្នាក់ៗទទួលបាននូវការហ្វឹកហ្វឺនដ៏សមរម្យផងដែរ ។ ពួកគេអាចត្រូវបាន

ផ្តល់អំណាចឲ្យជាបណ្តើរៗ ដើម្បីធ្វើការទទួលខុសត្រូវយ៉ាងពេញលេញក្នុងឋានៈជាចៅក្រម រដ្ឋអាជ្ញា និងអ្នកការពារក្តី ។ មន្ត្រីយុត្តិធម៌ តុលាការព្រហ្មទណ្ឌ និងយុត្តិធម៌ព្រហ្មទណ្ឌជនជាតិឥណ្ឌូនេស៊ីទាំងអស់បានជម្លៀសចេញពីប្រទេសទីម័រខាងកើត នៅពេលដែលប្រទេសឥណ្ឌូនេស៊ីដកថយនៅឆ្នាំ១៩៩៩ ដោយបន្សល់ទុកនូវជនជាតិទីម័រមួយចំនួនតូចដែលមានសញ្ញាប័ត្រផ្នែកច្បាប់ ហើយមិនមាននរណាម្នាក់ធ្លាប់ធ្វើការជាចៅក្រមផងទេ ។ មានតែម្នាក់គត់ ដែលមានបទពិសោធន៍ធ្លាប់ធ្វើជារដ្ឋអាជ្ញា ។ ប្រទេសទីម័រខាងកើតត្រូវការចាំបាច់នូវកម្មវិធីកសាងសមត្ថភាពក្នុងទ្រង់ទ្រាយធំ ក៏ប៉ុន្តែការហ្វឹកហ្វឺនដល់បុគ្គលិកក្នុងស្រុកកើតមានឡើងតែក្នុងទ្រង់ទ្រាយតូចមួយប៉ុណ្ណោះ ។ ជាដំបូង អង្គការសហប្រជាជាតិមិនមានគម្រោងផ្ទេរជំនាញ ឬបង្កើតនូវកេរដំណែលទុកឲ្យប្រជាជនទីម័រនោះទេ ។ កម្មវិធីហ្វឹកហ្វឺនត្រូវបានបង្កើតឡើងនៅឆ្នាំ២០០២ ដោយមានការផ្តល់មូលនិធិពីប្រទេសន័រវេសសម្រាប់ប្រាក់បៀវត្សរ៍របស់សិក្ខាកាម ក៏ប៉ុន្តែគេកំណត់ឲ្យកម្មវិធីនេះសម្រាប់តែបុគ្គលិករបស់អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ប៉ុណ្ណោះ ដោយជួយផ្តល់យោបល់ក្នុងលក្ខណៈមិនផ្លូវការដល់ចៅក្រមនៅក្នុងអង្គពិភាក្សាពិសេសទាំងនោះ ។

ក៏ប៉ុន្តែ បើទោះបីជាមានការដាក់កម្រិតនានាខាងផ្នែកធនធាន និងនយោបាយលើអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់នេះក៏ដោយ ក៏អ្នកអនុវត្តដែលមានការប្តេជ្ញាចិត្តមួយក្រុមតូចអាចសម្រេចបាននូវវិធានការផ្តល់យុត្តិធម៌ក្នុងកម្រិតមួយតូចដល់ជនរងគ្រោះដោយសារជម្លោះរបស់ប្រទេសទីម័រខាងកើតដែរ ។ សមិទ្ធផលរបស់តុលាការនេះត្រូវធ្វើការស្វែងយល់នៅក្នុងបរិបទនៃបេសកកម្មរបស់ខ្លួននិងនៅក្នុងស្ថានការណ៍ដែលខ្លួនបានជួបប្រទះ ។ អង្គចៅក្រមពិសេសទទួលបន្ទុកឧក្រិដ្ឋកម្មកម្រិតធ្ងន់នៅក្នុងតុលាការក្រុងឌីលី បានចេញដីកាចោទប្រកាន់ជាច្រើនប្រកបដោយភាពក្លាហាន ដែលអ្នកទាំងនោះត្រូវប្រឈមមុខនឹងការគំរាមកំហែងនិងការរារាំងយ៉ាងខ្លាំងពីប្រទេសឥណ្ឌូនេស៊ី ។ ជាពិសេស សាលាក្តីនេះបានចេញដីកាចាប់ខ្លួនលោក វីរ៉ង់តូ អតីតមេបញ្ជាការយោធារបស់ប្រទេសឥណ្ឌូនេស៊ីចំពេលដែលលោកឈរឈ្មោះជាបេក្ខជនប្រធានាធិបតី ហើយធ្វើការចោទប្រកាន់លើរូបគាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងអំឡុងពេលដែលគាត់កាន់មុខតំណែង ។ ដីកានេះត្រូវបានចេញរយៈពេលជាងមួយឆ្នាំ បន្ទាប់ពីលោក វីរ៉ង់តូត្រូវបានចោទប្រកាន់ដោយរដ្ឋអាជ្ញាក្នុងអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់របស់ប្រទេសទីម័រខាងកើត ហើយក្នុងរយៈពេលមិនដល់មួយខែផង បន្ទាប់ពីគាត់ទទួលបានការតែងតាំងជាបេក្ខជនប្រធានាធិបតីរបស់គណបក្សហ្គុលកា ។ មន្ត្រីប្រទេសឥណ្ឌូនេស៊ីបានបញ្ជាក់ច្បាស់ថា ប្រទេសរបស់ខ្លួនមិនបានគិតថា តុលាការរបស់ប្រទេសទីម័រខាងកើតមានយុត្តាធិការលើជនជាតិរបស់ខ្លួននោះទេ ហើយបាននិយាយថាប្រទេសឥណ្ឌូនេស៊ីមិនមានបំណងចាប់ខ្លួន ឬធ្វើបត្យាប័នបញ្ជូនជនទាំងឡាយណាដែលត្រូវបានចោទប្រកាន់ដោយអង្គចៅក្រមពិសេសទាំងនេះទេ ។

លោកស្រី ស៊ូហ្សាណា លីនតុន បានលើកឡើងនូវហេតុផលថា ឧបសគ្គនានា «មិនត្រូវធ្វេសប្រហែសឡើយ» ហើយថា គំនិតផ្តួចផ្តើមយុត្តិធម៌របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិត្រូវតែស៊ីសង្វាក់គ្នាទៅនឹងដំណើរនៃអាណត្តិរបស់ខ្លួន «ដើម្បីកសាងប្រទេសមួយពីបាតដៃទទេ» ។ លោកស្រីបានសង្កត់ធ្ងន់ថា រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនេះបានក្លាយទៅជា «អ្នកថែរក្សាទឹកដីដែលត្រូវបានបំផ្លិចបំផ្លាញនិងរងរបួសជាមួយនឹងអគារតែមួយប៉ុណ្ណោះដែលមិនទទួលរងខូចខាតដោយសារអង្គការសហប្រជាជាតិ «បានបង្កើតនូវប្រព័ន្ធតុលាការមួយដែលមិនធ្លាប់មានទាល់តែសោះពីមុនមក ។ នៅក្នុងប្រព័ន្ធតុលាការដែលងាយប្រេះស្រាំនេះ អង្គការសហប្រជាជាតិបានខិតខំពុះពារបង្កើតយន្តការពិសេសមួយដើម្បីចាត់ការអំពើយង់ឃ្នងបំផុតដែលមិនអាចពណ៌នាបាន» ។ ការប្រឈមមុខនឹងឧបសគ្គធំៗដែលបណ្តាលមកពីការបំផ្លិចបំផ្លាញជារូបវន្តរបស់យុទ្ធនាការឆ្នាំ១៩៩៩ ការនិរទេសខ្លួនទាំងហ្វូងៗរបស់ជនជាតិទីម័រខាងកើតដែលមានកម្រិតអប់រំខ្ពស់និងកង្វះខាតធនធាន «សាលាកាត់ក្តីនេះនៅតែបន្តដំណើរទៅមុខ ។ អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ជាពិសេស... បានឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការរិះគន់នានានិងឆ្លងកាត់ការរៀបចំរចនាសម្ព័ន្ធជាថ្មីនិងការកែលម្អកាន់តែទូលំទូលាយ ។ រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិបានឆ្លើយតបជាវិជ្ជមានទៅនឹងអត្ថបទរិះគន់ទៅលើ

និន្នាការពីដំបូងរបស់ខ្លួនផ្តោះទៅរកបិតុនិយមដ៏សប្បុរសធម៌ដែលដាក់ចេញនូវជនជាតិទីម័រខាងកើត [និង] «ទីម័រភាវូបនីយកម្ម» បានក្លាយជាកម្មវត្ថុដ៏សំខាន់មួយរបស់បេសកកម្មនេះដោយមានជនជាតិទីម័រខាងកើតកំពុងផ្លាស់ប្តូរទៅកាន់មុខតំណែងដឹកនាំជាបន្តបន្ទាប់ ។ អំពើហិង្សា ឆ្នាំ១៩៩៩ បើទោះបីជាដំណើរការកាត់ក្តីខ្លះមិនមានគុណភាពគ្រប់គ្រាន់ក៏ដោយ ក៏ចំណុចទាំងនេះនិងដំណើរវិវត្តជាវិជ្ជមានដទៃៗទៀតត្រូវតែផ្តល់ជាដំណឹងអំពីការងាររបស់អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ដល់អ្នករិះគន់ទាំងឡាយ ។

នៅឆ្នាំ២០០៣ ចំនួនអ្នកស៊ើបអង្កេតត្រូវបានកាត់បន្ថយ ហើយអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់មួយត្រូវបានបិទទ្វារ ។ នៅខែឧសភា ឆ្នាំ២០០៤ ក្រុមប្រឹក្សាសន្តិសុខបានសម្រេចចិត្តថាអង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់គួរបញ្ចប់ការងារស៊ើបអង្កេតរបស់ខ្លួនត្រឹមខែវិច្ឆិកា ឆ្នាំ២០០៤ និងបញ្ចប់រាល់សកម្មភាពទាំងអស់នៅត្រឹមថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ ។ អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់បានបញ្ចប់ប្រតិបត្តិការរបស់ខ្លួនតាមសេចក្តីសម្រេចចិត្តនេះ ហើយបានធ្វើការចោទប្រកាន់ចុងក្រោយក្នុងខែធ្នូ ឆ្នាំ២០០៤ ធ្វើឲ្យចំនួនការចោទប្រកាន់កើនឡើងដល់៩៥ករណី ដោយមានជនជាប់ចោទចំនួន៣៩១នាក់នៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃរចនាសម្ព័ន្ធបញ្ជាការរបស់កងទ័ពឥណ្ឌូនេស៊ីនិងកងឈ្លបទីម័រខាងកើត ប្រឈមមុខនឹងការចោទប្រកាន់យ៉ាងហោចណាស់ក៏មួយដែរ ។ គេត្រូវតែទទួលស្គាល់និងកោតសរសើរចំពោះករណីចោទប្រកាន់និងកាត់ទោសទាំងនេះរួមទាំងវីរភាពរបស់អង្គភាពឧក្រិដ្ឋកម្មកម្រិតធ្ងន់ក្នុងការត្រៀមលក្ខណៈសម្រាប់ការផ្ទេរការងារដូចជាៈ ការថតឯកសារចំនួន៦០.០០០ទំព័រ ការបង្កើតទិន្នន័យសម្រាប់ការស្រាវជ្រាវ ការបកប្រែឯកសារសំខាន់ៗទៅជាភាសា Tetum ការចោទប្រកាន់ឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានលើករណីដែលមិនទាន់ចប់សព្វគ្រប់ ការធ្វើសេចក្តីព្រាង សេចក្តីណែនាំសម្រាប់អ្នកស៊ើបអង្កេតនាពេលអនាគត និងការរៀបចំឲ្យមានកិច្ចប្រជុំសហគមន៍នៅក្នុងស្រុកនីមួយៗដើម្បីពន្យល់ពីអ្វីដែលកំពុងកើតឡើង ។

## ១) អង្គពិគ្រោះយោបល់បញ្ញត្តិលេខ ៦៤ នៅក្នុងតុលាការកូសូវ៉ូ

ជម្លោះនៅកូសូវ៉ូដែលភាគច្រើនបំផុត ប្រព្រឹត្តដោយកងកម្លាំងជនជាតិស៊ែបមកលើជនជាតិភាគតិច អាល់បានី បានបណ្តេញជនជាតិកូសូវ៉ូចំនួនប្រមាណ៨សែននាក់និងធ្វើឲ្យប្រជាជនចំនួន៥សែននាក់ក្នុងចំណោមប្រជាជនសរុបដែលតាមការប៉ាន់ស្មានប្រជាជនចំនួន១,៧លាននាក់នៅមុនពេលជម្លោះកើតឡើងរស់នៅខ្ចាត់ខ្ចាយតាមស្រុកនិងទីក្រុងជនជាតិភាគតិចអាល់បានី រស់នៅដោយសភាពស្ងាត់ជ្រងំ ។ នៅខែមិថុនា ឆ្នាំ១៩៩៩ បន្ទាប់ពីយុទ្ធនាការទម្លាក់គ្រាប់បែកដឹកនាំដោយអង្គការណាតូដែលជួយបញ្ឈប់មិនឲ្យមានអំពើឃោរឃៅ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានចេញសេចក្តីសម្រេចមួយបង្កើតឲ្យមានបេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ ។ ជាមួយនឹងភារកិច្ចស្តារឡើងវិញនូវវិធានការរក្សាសណ្តាប់ធ្នាប់នៅក្នុងតំបន់មួយដែលត្រូវបានបំផ្លិចបំផ្លាញដោយសារសង្គ្រាមនិងការរើសអើងប្រឆាំងនឹងជនជាតិភាគតិចអាល់បានី អស់រយៈពេលជាច្រើនទសវត្សរ៍ អាណត្តិរបស់បេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូរួមមានការកាត់ទោសជនដែលទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលបានកើតឡើង ។ ជាមួយនឹងការផ្លាស់ប្តូរប្រព័ន្ធយុត្តាធិការក្នុងស្រុក រចនាសម្ព័ន្ធរូបវន្ត ដែលត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទាំ វត្តមានអ្នកទោសដែលជាប់គ្រាំគ្រែងពាសពេញពន្ធនាគារនិងការត្រៀមលក្ខណៈកាត់ទោសចំពោះអ្នកដែលប្រព្រឹត្តអំពើឃោរឃៅព្រៃផ្សៃបំផុតក្នុងទ្រង់ទ្រាយធំ ដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅអតីតយូហ្គោស្លាវី បេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូបានខិតខំប្រឹងប្រែងដោះស្រាយអ្វីដែលនៅពេលនោះកំពុងតែប្រែក្លាយយ៉ាងឆាប់រហ័សទៅជាវិបត្តិទាក់ទងនឹងការទទួលខុសត្រូវនិងយុត្តិធម៌ ។

ជួនពេលខ្លះ ការខិតខំប្រឹងប្រែងទាំងនេះបានផ្តល់លទ្ធផលអាក្រក់ច្រើនជាងលទ្ធផលល្អ ឧទាហរណ៍ដូចជានៅពេលដែលអង្គការសហប្រជាជាតិប្រើឯកសារដែលមានលក្ខណៈច្របូកច្របល់ដូចជាៈ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៨៩របស់កូសូវ៉ូ បញ្ញត្តិរបស់បេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ និងអនុសញ្ញារបស់សហភាពអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ហើយដែលបានចំណាយពេលអស់ជាច្រើនខែដើម្បីបកប្រែនិងចែកចាយឯកសារច្បាប់ទាំងនោះ ។ បន្ទាប់ពីមានការជជែកវែកញែកយ៉ាងច្រើនអំពីការបង្កើតតុលាការពិសេសមួយដែលឲ្យឈ្មោះថា តុលាការឧក្រិដ្ឋកម្ម

ជាតិពន្ធនិងសង្គ្រាមនៅកូសូវ៉ូ ឧបសគ្គកង្វះថវិកា និងផ្នែកនយោបាយ បាននាំទៅរកភាពទ័លច្រក ហើយតុលាការត្រូវបានបោះបង់ចោល ។

ទន្ទឹមគ្នានោះដែរ ស្លាកស្នាមនៃអតីតរបបជិះជាន់ដែលធ្វើឲ្យអន្តរាយដល់ភាពជឿជាក់របស់សាធារណជនទៅលើប្រព័ន្ធយុត្តិធម៌ដែលមិនបានផ្តល់យុត្តិធម៌ឲ្យជនជាតិភាគតិចអាល់បានី និងដែលគ្រប់គ្រងដោយជនជាតិស៊ែប ត្រូវបានគេយល់ឃើញថាជាពួកជិះជាន់កៀបសង្កត់ ។ «ពីដំបូងជាមួយនឹងការពិគ្រោះយោបល់តិចតួចជាមួយប្រជាជនក្នុងស្រុកអាជ្ញាធរ បេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូបានប្រកាសច្បាប់ដែលកំពុងអនុវត្តនៅកូសូវ៉ូដែលត្រូវបានកែសម្រួលដើម្បីឲ្យស្របទៅនឹងស្តង់ដារសិទ្ធិមនុស្សអន្តរជាតិថាជាច្បាប់របស់សហព័ន្ធសាធារណរដ្ឋយូហ្គោស្លាវី/ប្រទេសស៊ែប៊ី ។ ការសម្រេចចិត្តនេះបានធ្វើឲ្យជនជាតិភាគតិចអាល់បានីនៅកូសូវ៉ូជាច្រើន ដែលយល់ឃើញថាច្បាប់សហព័ន្ធសាធារណរដ្ឋយូហ្គោស្លាវី, ស៊ែប៊ី គឺជាច្បាប់របស់របបស៊ែបដែលមានលក្ខណៈកៀបសង្កត់នោះ មានការខឹងសម្បាយ៉ាងខ្លាំង ។ ចៅក្រមកូសូវ៉ូជនជាតិអាល់បានី បានបដិសេធការអនុវត្តន៍ច្បាប់ដែលបង្កឲ្យមានការច្របូកច្របល់កាន់ធំឡើង ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ បេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូបានចេញសេចក្តីសម្រេចថ្មីជាច្រើន ប៉ុន្តែនៅតែជួបការលំបាកបញ្ហាខ្វះបុគ្គលិក ។

បញ្ហាអំពីការសម្រេចចិត្តកំណត់យកច្បាប់ដើម្បីមកអនុវត្តមានសភាពកាន់តែធ្ងន់ធ្ងរឡើងដោយសារតែមានការអាក់អន់ចិត្តចំពោះការខកខានរបស់អង្គការសហប្រជាជាតិក្នុងការពិគ្រោះយោបល់ជាមួយអ្នកក្នុងស្រុកនៅពេលសម្រេចចិត្តទៅលើបញ្ហាយុត្តាធិការ ដែលនេះជាបរាជ័យមួយកាន់តែធ្ងន់ធ្ងរឡើងដោយសារតែខ្វះមន្ត្រីដែលត្រូវបានគេជ្រើសរើសឬសង្គមស៊ីវិលមួយដែលមានដំណើរការនៅក្រោយពេលមាន ជម្លោះ ។ ក្រោយពេលដែលបេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ ទទួលគ្រប់គ្រងកូសូវ៉ូ តុលាការក៏ខ្វះបុគ្គលិកដែលមានបទពិសោធន៍ «ព្រោះថាមានតែចៅក្រមជនជាតិស៊ែបមួយចំនួនតូចប៉ុណ្ណោះដែលមានបំណងចង់ធ្វើការនៅក្នុងតុលាការនេះ ហើយសូម្បីតែអ្នកដែលត្រូវបានតែងតាំងជាបន្តបន្ទាប់ក៏លាលែងពីតំណែងទៅទៀតដើម្បីឆ្លើយតបទៅនឹងសម្ពាធរបស់ក្រុងបែលក្រាដ» ។ កង្វះតំណាងជនជាតិស៊ែបនៅក្នុងតុលាការ បាននាំឲ្យមានមន្ទិលសង្ស័យទៅលើភាពស្របច្បាប់និងឯករាជ្យភាពរបស់តុលាការពីសំណាក់ប្រជាជនស៊ែប ។ សាលក្រមមួយចំនួនរបស់ចៅក្រមជនជាតិអាល់បានីប្រឆាំងនឹងកូនក្តីជនជាតិស៊ែប ត្រូវបានគេមើលឃើញថាមានលក្ខណៈច្បាស់ជាក់ស្តែងរហូតធ្វើឲ្យអង្គចៅក្រមចម្រុះអន្តរជាតិនិងក្នុងស្រុកច្រានចោលសាលក្រមទាំងនេះ ។ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០០ បន្ទាប់ពីមានកូដកម្មបង្អត់អាហារនៅមេត្រូវិកាធ្វើឡើងដោយអ្នកជាប់ឃុំឃាំងភាគច្រើនជាជនជាតិស៊ែបកូសូវ៉ូដែលកំពុងត្រូវបានស៊ើបអង្កេតឬកំពុងរង់ចាំការកាត់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម តំណាងពិសេសរបស់អគ្គលេខាធិការបានចេញបញ្ញត្តិលេខ២០០០/៣៤ ដែលបន្ថែមអំណាចឲ្យបេសកកម្មរបស់អង្គការសហប្រជាជាតិនៅកូសូវ៉ូ តែងតាំងចៅក្រម និងរដ្ឋអាជ្ញាអន្តរជាតិ នៅក្នុងទឹកដីកូសូវ៉ូទាំងមូល ។

បញ្ញត្តិទាំងអស់នេះដែលអនុញ្ញាតឲ្យចៅក្រមបរទេសចូលរួមក្នុងដំណើរការកាត់ក្តីជាមួយចៅក្រមក្នុងស្រុកនៅក្នុងតុលាការក្នុងស្រុកដែលមានស្រាប់របស់កូសូវ៉ូ ហើយដែលអនុញ្ញាតឲ្យមេធាវីបរទេសរួមគ្នាជាមួយមេធាវីក្នុងស្រុក ដើម្បីចោទប្រកាន់ឬការពាររឿងក្តីបាននាំឲ្យមានការបង្កើតអង្គពិគ្រោះយោបល់បញ្ញត្តិលេខ៦៤ នៅក្នុងតុលាការកូសូវ៉ូដែលអនុវត្តបញ្ចូលគ្នារវាងច្បាប់អន្តរជាតិនិងច្បាប់ក្នុងស្រុក ។ អង្គការសហប្រជាជាតិជឿថា ការអញ្ជើញអ្នកជំនាញបរទេសមកធ្វើការដែលនឹងជួយកសាងសមត្ថភាពនិងឯករាជ្យភាពក្នុងស្រុកដោយមានការរួមកម្លាំងគ្នាយ៉ាងសកម្មនៅក្នុងដំណើរការរបស់យុត្តាធិការក្នុងស្រុកដែលទទួលរងការបំផ្លិចបំផ្លាញ ។ ការតែងតាំងបុគ្គលិកបរទេសនៅក្នុងតុលាការតាំងពីដំបូងពិតជាបានជួយកាត់បន្ថយការព្រួយបារម្ភអំពីអនាគតរបស់តុលាការ ។ ប៉ុន្តែយោងទៅតាមចំនួនចៅក្រមបរទេសនិងអំណាចតិចតួចដែលពួកគេមាន ការតែងតាំងនេះមិនបានដោះស្រាយនូវការព្រួយបារម្ភអំពីអព្យាក្រឹតភាពរបស់តុលាការបានទាំងស្រុងទេ ។

អង្គពិគ្រោះយោបល់បញ្ញត្តិលេខ៦៤ នៅក្នុងតុលាការកូសូវ៉ូ បានពើបប្រទះនឹងបញ្ហាមួយចំនួន ជាពិសេសនៅក្នុងការស្វែងរកថវិកានិងជួលបុគ្គលិកបរទេសដែលមានសមត្ថភាព ។

ចៅក្រមបរទេសមួយចំនួនដែលត្រូវបានជ្រើសរើសឲ្យមកបំពេញការងារមិនមានការយល់ដឹងផ្នែកវប្បធម៌ គ្មានជំនាញគ្រប់គ្រាន់ និង/ឬមិនសូវចេះដឹងផ្នែកច្បាប់អន្តរជាតិ ឬចេះភាសាអង់គ្លេសមិនស្ទាត់ជំនាញ ។ មិនមានយន្តការដើម្បីបណ្តុះបណ្តាលចៅក្រមក្នុងស្រុកទេ ហើយនៅប្រេស្ទីណា ចៅក្រមបរទេសនិងក្នុងស្រុកមានការិយាល័យនៅក្នុងអគារផ្សេងពីគ្នា ។ ជាលទ្ធផលអ្នកអត្ថាធិប្បាយខ្លះដូចជា *Sylvia de Bertodano* បានប្រកាសថា អង្គពិគ្រោះយោបល់បញ្ញត្តិ ៦៤ គឺជារឿងគួរឲ្យខកចិត្ត ។

បើទោះបីជាមានចំណុចខ្វះខាតទាំងនេះក៏ដោយ ហើយបើទោះបីជាការបញ្ចូលចៅក្រមបរទេសមិនបានជួយដោះស្រាយបញ្ហាដែលតុលាការបានជួបប្រទះទាំងអស់ក៏ដោយ ការតែងតាំងចៅក្រមបរទេស និង(រដ្ឋអាជ្ញា) នៅក្នុងតុលាការក្នុងស្រុក... ក្នុងសំណុំរឿងដែលមានបញ្ហាធ្ងន់ធ្ងរ (ដែលពាក់ព័ន្ធនឹងការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ) បានជួយលើកកម្ពស់ទស្សនៈអំពីទិដ្ឋភាពឯករាជ្យភាពរបស់យុត្តាធិការនិងភាពស្របច្បាប់របស់តុលាការនេះ នៅក្នុងក្រសែភ្នែករបស់ប្រជាជនក្នុងស្រុកច្រើនស្រទាប់ ។ ពិសេសជាងគេនោះ សូម្បីតែនៅក្នុងចំណោមជនជាតិស៊ែប «សាលក្រមរបស់តុលាការចម្រុះបានកាត់បន្ថយការព្រួយបារម្ភអំពីអនាគត ។ នៅទីបំផុត តុលាការកូសូវ៉ូបានកាត់ទោសជនល្មើសដែលត្រូវបានចោទប្រកាន់ប្រកបដោយប្រសិទ្ធភាព និងបានកាត់បន្ថយវិបត្តិផ្នែកនីត្យានុកូលភាពបានមួយផ្នែកធំ ។ «យ៉ាងហោចណាស់ក៏មានរបាយការណ៍មួយបានផ្តល់យោបល់ថា វត្តមានរបស់បុគ្គលិកបរទេសបានលើកកម្ពស់គុណភាពយុត្តិធម៌ឲ្យដល់ក្នុងករណីទាំងនោះ បើទោះបីជាវាបានរិះគន់តុលាការលើទិដ្ឋភាពជាច្រើនក៏ដោយ» ។ លោក គ្លីន វីលៀមសាន់ ដែលជាប្រធាននាយកដ្ឋានយុត្តិធម៌របស់កូសូវ៉ូពីខែតុលា ឆ្នាំ២០០១ ដល់ខែវិច្ឆិកា ឆ្នាំ២០០២ បានវាយតម្លៃថា អង្គពិគ្រោះយោបល់៦៤ គឺជាជោគជ័យចម្រុះមួយ ។ គាត់បានលើកឡើងថា បើទោះបីជាមាន ចៅក្រម និងរដ្ឋអាជ្ញាមួយចំនួនមិនមានគុណសម្បត្តិគ្រប់គ្រាន់មានការគំរាមកំហែងខ្លះទៅលើបុគ្គលិកក្នុងស្រុកដល់ទីកន្លែងពី សំណាក់ជនល្មើស ហើយនៅពេលខ្លះមានការទម្លាក់ការទទួលខុសត្រូវលើរឿងក្តីប្រកបដោយគ្រោះថ្នាក់ទៅឲ្យបុគ្គលិកបរទេសក៏ដោយ ក៏អង្គពិគ្រោះយោបល់ ៦៤បានដើរតួនាទីយ៉ាងមានតម្លៃនៅកូសូវ៉ូដែរ ។ បើទោះបីជាប្រឈមនឹងការខឹងសម្បាពីសំណាក់មនុស្សជាច្រើនដែលប្រឆាំងទៅនឹងតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅយូហ្គោស្លាវីក៏ដោយ ក៏គាត់ជឿជាក់ថាបុគ្គលិកបរទេសនិងបុគ្គលិកក្នុងស្រុកបានរក្សានូវចំណងទាក់ទងគ្នាទៅវិញទៅមកនៅក្នុងរចនាសម្ព័ន្ធតុលាការចម្រុះដែលធ្វើឲ្យគាត់យល់ឃើញថាជាការនាំមកនូវអារម្មណ៍ល្អចំពោះតុលាការនេះពីសំណាក់ប្រជាជនក្នុងស្រុក ។ របាយការណ៍របស់ **OSCE** បានវាយតម្លៃខ្ពស់ចំពោះបទពិសោធន៍ទូទៅរបស់តុលាការចម្រុះនៅកូសូវ៉ូ ដោយផ្តល់ជំនឿលើការអះអាងដែលថាករណីតុលាការនៅកូសូវ៉ូតំណាងឲ្យការកែលំអចំពោះគំរូតុលាការចម្រុះមួយដែលមានដំណើរការនៅទីម័រខាងកើត បើទោះបីជាមានភាពខ្វះចន្លោះជាច្រើនក្តី ។ **(នៅមានត)** **អេរ៉ែល ហ៊ីហ្គូនេត**

**(តមកពីទំព័រ១)**

វាគ្រាន់តែមានន័យថា ដោយសារអង្គជំនុំជម្រះវិសាមញ្ញមានធនធាននិងពេលវេលាមានកំណត់ និងជំនុំជម្រះតែមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មក្នុងរយៈកាលពីឆ្នាំ១៩៧៥ – ១៩៧៩ ជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់មកលើរូបលោក–អ្នកប្រហែលជាមិនត្រូវចោទប្រកាន់ដោយអង្គជំនុំជម្រះវិសាមញ្ញទេ ហើយការរងគ្រោះរបស់លោក–អ្នកផ្ទាល់ខ្លួននឹងប្រហែលជាមិនត្រូវបានលើកយកពិភាក្សាដោយអង្គជំនុំជម្រះវិសាមញ្ញដែរ ។

ប៉ុន្តែ សំណើសុំចូលរួមរបស់លោក–អ្នកនឹងក្លាយជាផ្នែកមួយនៃឯកសារប្រវត្តិសាស្ត្រ និងបានរួមចំណែកដល់ការយល់ដឹងរបស់យើងទាក់ទងនឹងអ្វីដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជានៅក្នុងរយៈពេលនោះ ។ ដូចគ្នាដែរ លោក–អ្នកអាចបន្តរួមចំណែកដល់ដំណើរការផ្សះផ្សាជាតិ តាមរយៈការសម្តែងយោបល់អំពីប្រភេទនៃការជួសជុលសំណងជាសមូហភាព ឬជានិមិត្តរូបដែលលោក–អ្នកចង់ឲ្យអង្គជំនុំជម្រះវិសាមញ្ញផ្តល់ឲ្យជនរងគ្រោះនៅចុងបញ្ចប់នៃដំណើរការជំនុំជម្រះ ។

**អាន ហេនដែល**

# អ្នកថតរូបអះអាងថា: ជនបរទេសស្លាប់នៅក្នុងគុករបស់ប៉ុលពត

ទោះបីជាមានជនជាតិបរទេស ៧៩រូប និងអ្នកទោសសង្គ្រាមវៀតណាមរាប់រយនាក់ត្រូវបានដឹងថាស្លាប់នៅក្នុងគុកសម្ងាត់របស់ប៉ុលពតក៏ដោយ តែអតីតអ្នកថតរូបពីរនាក់នៅមន្ទីរស-២១ បានឲ្យដឹងថា ចំនួននេះនៅមានច្រើនទៀត ។

ពីកន្លែងរស់នៅបច្ចុប្បន្នក្នុងខេត្តមួយនៅខាងត្បូងរាជធានី អតីតអ្នកថតរូប នឹម អ៊ឹម ដែលធ្លាប់ថតរូបអ្នកទោសរាប់ពាន់នាក់ដែលត្រូវបានធ្វើទារុណកម្ម ឬក៏សម្លាប់នៅមន្ទីរស-២១បាន និយាយថា គាត់ចាំជនជាតិញូវហ្សឺឡែន គូបា ស៊ីស អ្នកបើកបរកប៉ាល់ជនជាតិថៃ និងអ្នកទោសជាច្រើនទៀតដែលគាត់និយាយថាប្រហែលជាមានការបាត់ខ្លួនដោយមិនមាននៅក្នុងឯកសារ ។

អ៊ឹម និយាយថា *«មានអ្នកទោសច្រើនណាស់ តែខ្ញុំចាំច្បាស់ជាងគេគឺជនជាតិគូបា ។ រឿងនេះកើតឡើងនៅឆ្នាំ១៩៧៧ គាត់មានម៉ាស៊ីនថតមួយ ហើយពួកគេរឹបអូសវាបាត់ ។ គាត់នៅក្មេង និងមានពុកចង្កាទៀត គេចាប់គាត់ពីសមុទ្រមក ។ អ្វីដែលខ្ញុំចងចាំបានច្រើនជាងគេនោះគឺគាត់មានទឹកមុខក្រៀមក្រំ ប៉ុន្តែគាត់មិនបានស្រែកទេ...គាត់ត្រូវបានសម្លាប់ដោយដុតទាំងរស់»* ។

អ៊ឹម ដែលស្គាល់ថាជា នឹម គីមស្រៀង បច្ចុប្បន្នអាយុ៥៥ឆ្នាំ ត្រូវបានមនុស្សជាច្រើន រួមទាំងនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ ផងដែរបានជឿថាគាត់ស្លាប់ ។ តែតាមពិតគាត់ជាប់ឃុំឃាំងដោយសារតែគាត់វាយអ្នកជិតខាងម្នាក់រហូតដល់ស្លាប់នៅឆ្នាំ១៩៩៧ ហើយទើបតែចេញពីគុកពេលថ្មីៗនេះ ។

កំណត់ត្រាដ៏ផ្ចិតផ្ចង់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញឲ្យឃើញថាជនរងគ្រោះជាជនជាតិញូវហ្សឺឡែនម្នាក់នៅឆ្នាំ១៩៧៨ ក៏ដូចជាជនជាតិអាមេរិក អូស្ត្រាលី ឡាវ បារាំង ថៃ ជ្វានិងឥណ្ឌាដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ជនរងគ្រោះគូបា ឬក៏ស៊ីស មិនត្រូវបានកត់ត្រាទុក ដូចនេះហើយអ្នកប្រវត្តិសាស្ត្រទទួលស្គាល់ថា ការស្រាវជ្រាវនៅខ្វះចន្លោះឬមិនគ្រប់គ្រាន់ ។

ការអះអាងរបស់ អ៊ឹម និងការនឹកឃើញឡើងវិញពីជីវិតរបស់គាត់នៅអតីតវិទ្យាល័យមួយដែលបានផ្លាស់ប្តូរទៅជាគុកឃោរឃៅមួយក្នុងពិភពលោកនៅអំឡុងពេលខ្មែរក្រហមគ្រប់គ្រងអំណាចពីឆ្នាំ១៩៧៥-១៩៧៩ បានបង្ហាញកាន់តែច្បាស់ពីជីវិតក្រោមរបបឯកោនេះ ។

ពួកគេប្រហែលជាអាចផ្តល់ដំណឹងខ្លះដល់គ្រួសារដែលនៅឆ្ងល់ថាតើមានអ្វីកើតឡើងចំពោះសមាជិកគ្រួសារដែលបានបាត់ខ្លួនតាំងពីបីទសវត្សរ៍មកហើយ ។

ញ៉ែម អេន អតីតអ្នកធ្វើការជាមួយ នឹម អ៊ឹម បញ្ជាក់បន្ថែមទៅលើការអះអាងរបស់ អ៊ឹម ថា ជនបរទេសច្រើនជាងនេះបានបាត់ខ្លួនដោយគ្មានបន្សល់ស្លាកស្នាមពិតប្រាកដនៅមន្ទីរស-២១ ។

អ៊ឹម និយាយថា *«ខ្ញុំជឿថារាល់ឯកសារទាំងអស់មិនមាននៅសល់ទេ ។ ខ្ញុំនៅចងចាំអំពីក្រុមជនបរទេសនៅឆ្នាំ១៩៧៧ ។ ពួកគេត្រូវបានចាប់ពីសមុទ្រមកដោយមានដែនទីលម្អិតមួយនិងម៉ាស៊ីនថតនៅក្នុងនោះមានរួមទាំងជនជាតិថៃផងដែរ ។*

បទសម្ភាសន៍នៅផ្ទះរបស់ អ៊ឹម នៅសប្តាហ៍នេះ គាត់បកស្រាយអំពីរបៀបធ្វើឲ្យឯកសារនៅមន្ទីរស-២១ កាន់តែស្មុគស្មាញ ហើយការចូលទៅក្នុងគុកនេះធ្វើឲ្យជីវិតរបស់គាត់កាន់តែជួបគ្រោះថ្នាក់ ។

អ៊ឹម និយាយថា *«នៅឆ្នាំ១៩៧៧ យើងមិនបានព្យួរស្លាកលេខនៅជុំវិញករបស់អ្នកទោសទេ យើងគ្រាន់តែថតរូបប៉ុណ្ណោះ ។ បន្ទាប់មកយើងធ្វើឯកសារដោយយកចិត្តទុកដាក់ជាងនេះ»* ។

នៅក្នុងឆ្នាំដដែល អ្នកទោសជាច្រើននាក់ត្រូវបានបញ្ជូនទៅកាន់ព្រៃស ប្រសិនបើ ឌុច សម្រេចថាអ្នកទាំងនោះមានកំហុស ។ ក្រោយមកមនុស្សជាច្រើនត្រូវចាប់បញ្ជូនមក ហើយមានកំហុសកាន់តែច្រើន ។

ឌុច ហៅ កាំង ហ្គេកអ៊ាវ ជាប្រធានមន្ទីរស-២១ ។ គាត់ត្រូវបានចោទប្រកាន់ជាផ្លូវការពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចំណាយថវិកា ៥៦លានដុល្លារដោយមានការចូលរួមពីអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំដែលរស់រានមានជីវិតមួយចំនួនតូចដែល

រំពឹងថាការកាត់ក្តីនឹងត្រូវធ្វើឡើងនៅឆ្នាំក្រោយ ។

ដេវីដ ឆេនដល័រ អ្នកប្រវត្តិសាស្ត្រនិងអ្នកនិពន្ធសៀវភៅមានចំណងជើងថា «សំឡេងពីមន្ទីរស-២១» គាត់បានប្រមើមើលថាប្រជាជនប្រហែលជា១៨០០០នាក់ ត្រូវបានជាប់នៅក្នុងគុកទួលស្លែងហើយ មានតែមនុស្សមួយចំនួនប៉ុណ្ណោះ ត្រូវរួចផុតជីវិតពីកន្លែងនេះ ។

ប៉ុន្តែ អ៊ឹម ចងចាំថា បដិវត្តន៍របស់គាត់គឺខុសប្លែកពីមនុស្សរាប់ពាន់នាក់ដែលបានស្លាប់ បន្ទាប់ពីចូលមន្ទីរស-២១ និងមនុស្សរាប់លាននាក់ទៀតដែលស្លាប់ដោយការអត់ឃ្លាននិងធ្វើការរហូតស្លាប់ ។ គាត់រស់នៅក្បែរផ្សារធំមួយនៅទីក្រុងភ្នំពេញ គឺផ្សារថ្មី និងនៅជិតហាងទំប៉ុង ដែលធ្វើនំសម្រាប់កម្មាភិបាលធំៗ ។

គាត់ទៅធ្វើការដោយជិះកង់ឬម៉ូតូ ។ រាល់ថ្ងៃគាត់អាចឃើញឡានតែមួយប៉ុណ្ណោះ ។ គាត់ចងចាំថាបន្ទាប់ពីធ្វើការ គាត់ញាំអាហារពេលល្ងាច ហើយទៅផ្ទះ ។

ប្រជាជនខ្មែរជាង២លាននាក់ បានស្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយការអត់ឃ្លាន ជំងឺ ការធ្វើការហួសកម្លាំង ទារុណកម្ម ឬការប្រហារជីវិត ។ អ៊ឹម អ្នកដែលបម្រើជាកងជីវពលភូមិ មុននឹងក្លាយជាអ្នកថតរូបនៅភ្នំពេញនៅហាងផ្តិតរូបអន្តរជាតិ អះអាងថា គាត់មិនដែលឃើញបទឧក្រិដ្ឋណាមួយប្រឆាំងមនុស្សជាតិដូចគ្នាទេ ។

ខ្មែរក្រហមដែលនិយមលទ្ធិម៉ៅជ្រុលហួសបានទុកទីក្រុងឲ្យនៅទំនេរ ហើយបញ្ជូនប្រជាជនរាប់លាននាក់ទៅវាលស្រែក្នុងការប៉ុនប៉ងកែប្រែប្រទេសឲ្យទៅជាសង្គមកសិកម្មមួយស្អាតស្អំ ។

អ៊ឹម និយាយថា គាត់មិនមានយោបល់អ្វីទេទៅលើរបបសព្វថ្ងៃ ។ គាត់ចងចាំថា ឌុច ជាបុរសម្នាក់ដែលដូចគាត់ដែរដែលធ្វើតាមតែបញ្ជានិងធ្វើអ្វីតាមតែគេប្រាប់ដែលគាត់មិនដឹងថាបញ្ជានោះចេញមកពីណាផងទេ ។ ប៉ុន្តែគាត់បានទំលុកអំពីជនបរទេសដ៏ចម្លែកដែលជាប់នៅមន្ទីរស-២១ ។ គាត់និយាយថា គាត់នៅតែចងចាំជនបរទេសនោះ ទោះបីជាឯកសារបញ្ជាក់ថាជននោះមិនមានវត្តមាននៅក្នុងនោះក៏ដោយ ។ គាត់ញាក់ស្មាហើយនិយាយថាៈ «មនុស្សជាច្រើនបានបាត់ខ្លួន» ។

**ភ្នាក់ងារសារព័ត៌មានអាល្លឺម៉ង់**

# អតីតអ្នកថតរូបនៅទួលស្លែងមិនបានអះអាងថា បានដឹងពួរឿង សម្លាប់ជនជាតិញូហ្សីឡែន គូបា ស៊ីស និងអ្នកបើកកាណូត ជនជាតិថៃ នៅមន្ទីរស-២១

ស-២១ ជាមន្ទីរសន្តិសុខថ្នាក់ខ្ពស់បំផុតរបស់របបខ្មែរក្រហម ។ មន្ទីរសន្តិសុខនេះមានតួនាទីជាកន្លែងឃុំឃាំងដ៏សាហាវឃោរឃៅមួយយ៉ាងពិតប្រាកដ ។ ពាក្យ «ស» ជាអក្សរកាត់របស់ពាក្យសន្តិបាល មានន័យថា «នគរបាលសន្តិសុខ» ។ អ្វីដែលបានកើតឡើងនៅគុកនេះនៅតែលងក្នុងអារម្មណ៍របស់ជនដែលនៅរស់បានមួយចំនួន ។ បើទោះជាអ្នកមិនឆ្លងកាត់ការជាប់ឃុំនៅក្នុងគុកនេះក៏ដោយ ក៏ការភ័យខ្លាច ភាពតក់ស្លុត និងការស្រក់ទឹកភ្នែកតែងតែកើតមានឡើងជាដរាបពេលបានចូលដល់របងគុកនេះ ។

ក្នុងអំឡុងការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលដឹកនាំដោយប៉ុល ពត ប្រជាជនសាមញ្ញពុំបានដឹងពីវត្តមាន ឬការធ្វើទារុណកម្ម ការសួរចម្លើយ ការបន្ទាបបន្ថោកតម្លៃមនុស្ស និងការកាប់សម្លាប់ដែលកើតមាននៅក្នុងគុកនេះឡើយ ។ គុកនេះហាក់ដូចជាបង្កើតឡើងជាស្ថាប័នសម្ងាត់មួយដែលដឹងឮត្រឹមតែមន្ត្រីខ្មែរក្រហមថ្នាក់ខ្ពស់មួយចំនួនតូចប៉ុណ្ណោះ ។ ប៉ុន្តែនៅពេលកងទ័ពវៀតណាមនិងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយរំដោះប្រទេសបាននៅឆ្នាំ១៩៧៩ ទើបគុកសម្ងាត់នេះត្រូវបានដឹងឮជាសាធារណៈ ។

នឹម អ៊ឹម ជាអតីតជាងថតរូបនៅមន្ទីរស-២១ និយាយថា វាជាការសំខាន់ដែលរបបណាក៏ដោយចាំបាច់ត្រូវមានកន្លែងឃុំឃាំងមនុស្សដើម្បីគ្រប់គ្រងបញ្ហាសន្តិសុខរបស់ប្រទេស ។ រឿងរ៉ាវរបស់គាត់មិនខុសគ្នាពីរឿងរ៉ាវរបស់អ្នកធ្វើការដទៃទៀត

នៅមន្ទីរស-២១នេះប៉ុន្មានទេ ដោយគាត់បានអះអាងថា គាត់បានដឹងតែរឿងរ៉ាវបន្តិចបន្តួចដែរដែលកើតឡើងនៅទីនេះ ។ អ៊ឹម បានទទួលស្គាល់ថា មានជនបរទេសមួយចំនួនត្រូវបាននាំយកមកគុកនេះដែលភាគច្រើនជាជនជាតិវៀតណាម ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏គាត់មិនបានអះអាងថា គាត់បានដឹងតែពីការចាប់ខ្លួនជនជាតិបរទេសដែលមានជនជាតិញូវហ្ស៊ីឡែន គូបា ស៊ីស និងអ្នកបើកកាណូតជាជនជាតិថៃទេ ។ ទាំងនេះគឺវាផ្ទុយពីអត្ថបទមួយដែលសរសេរថា នឹម អ៊ឹម ពិតជាដឹងពីរឿងចាប់ខ្លួនអ្នកទោសបរទេសទាំងនេះ ។

ប្រវត្តិរូបរបស់ នឹម អ៊ឹម ជាប្រវត្តិរូបមួយក្នុងចំណោមប្រវត្តិរូបជាងមួយម៉ឺនច្បាប់ដែលប្រមូលទុកដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គោលបំណងសំខាន់ពីររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺការចងចាំនិងយុត្តិធម៌ ។ ដើម្បីសម្រេចបាននូវគោលបំណងនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងមួយហៅថាការជំរុញឲ្យមានការទទួលខុសត្រូវជាគម្រោងមួយក្នុងចំណោមគម្រោងជាច្រើនដែលកំពុងដំណើរការ ។ គម្រោងនេះត្រូវបានបង្កើតឡើងដើម្បីប្រមូលព័ត៌មានទាក់ទងនឹងអតីតកម្មា-ភិបាល និងកងទ័ពខ្មែរក្រហមដើម្បីស្វែងយល់ពីចំណងខក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ ការងារសំខាន់របស់ក្រុមនេះគឺធ្វើសម្ភាសន៍ជាមួយកងទ័ពខ្មែរក្រហមនៅតាមភូមិកំណើតរបស់ខ្លួនដែលផ្តល់ឲ្យដឹងនៅក្នុងប្រវត្តិរូបនេះ ។ ប្រសិនបើឈ្មោះនៅក្នុងប្រវត្តិរូបបានស្លាប់បាត់បង់ជីវិត ក្រុមរបស់កម្មវិធីនេះនឹងសម្ភាសក្រុមគ្រួសារ និងសាច់ញាតិដើម្បីព្យាយាមទទួលបានព័ត៌មានស្តីពីរបបខ្មែរក្រហមកាន់តែច្រើន ។

នៅឆ្នាំ២០០៣ ក្រុមរបស់កម្មវិធីនេះមានគ្នាបីនាក់ បានចុះទៅកាន់ស្រុកកំណើតរបស់ អ៊ឹម ។ ជាអកុសលក្រុមការងារនេះមិនបានជួបសម្ភាស អ៊ឹម ព្រោះនៅពេលនោះគាត់ជាប់ឃុំឃាំង ក៏ប៉ុន្តែក្រុមការងារបានជួបជាមួយបងស្រីគាត់ដើម្បីជូនប្រវត្តិរូបរបស់ អ៊ឹម ដែលធ្វើឡើងនៅជំនាន់ខ្មែរក្រហម ។


នឹម អ៊ឹម ឆ្នាំ២០០៧

ទើបតែថ្មីនេះ អ៊ឹម ត្រូវបានដោះលែងពីពន្ធនាគារ ហើយបានផ្តល់បទសម្ភាសន៍ដល់ក្រុមការងារដើម្បីជាផលប្រយោជន៍សម្រាប់ក្មេងជំនាន់ក្រោយយល់ដឹងពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។

នឹម អ៊ឹម បានសម្រេចចូលបដិវត្តន៍នៅឆ្នាំ១៩៧០ ដើម្បីរំដោះព្រះមហាក្សត្រនិងប្រជាជនក្រីក្រពីពួកចក្រពត្តិមូលធននិងពួកសក្តិភូមិដែលជិះជាន់ប្រទេស ។ ដំបូងគាត់ធ្វើជាឈ្លបឃុំនៅស្រុកកំណើត តែក្រោយមកគាត់ទៅវាយប្រយុទ្ធនៅសមរភូមិជាច្រើនតាមការចាត់តាំងដើម្បីវាយរំលំរបបលន់ នល់ រហូតដល់គាត់មានរបួសដៃនិងស្លូតថែមទៀត ។ ដោយសារតែរបួសនេះ ណាត ជាប្រធានកងពល៧០៣ បានចាត់តាំងគាត់ធ្វើជាងថតរូបប្រចាំកងពល៧០៣ នៅក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥

ជាពេលដែលកងទ័ពខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ។ រហូតដល់ឆ្នាំ១៩៧៧ អ៊ីម ត្រូវបានផ្លាស់ប្តូរទៅក្រុមថតរូបអ្នកទោសនៅមន្ទីរស-២១ ដែលនៅទីនោះគាត់ចាំថាមានក្រុមផ្សេងគ្នាសម្រាប់ថតរូប ។

អត្ថបទមួយដែលមានចំណងជើងថា «ដានថតរូបអះអាងថាជនបរទេសស្លាប់នៅក្នុងគុករបស់ ប៉ុល ពត» អ្នកនិពន្ធបានធ្វើការបកស្រាយខុសពីការនិយាយប្រាប់របស់ អ៊ីម មួយចំនួន ។ អ៊ីម និយាយថា គាត់មិនបានដឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងគុកនេះទេ ដោយសារគាត់ធ្វើការតែនៅក្នុងបន្ទប់ថតរូបអ្នកទោសដែលនាំយកមកដោយឆ្មាំគុកប៉ុណ្ណោះ ហើយគាត់មិនបានអះអាងថាបានដឹងឮពីការចាប់ក្រុមអ្នកទោសបរទេសមកមន្ទីរស-២១ ដូចដែលអត្ថបទលើកឡើងនោះទេ ។ នៅមន្ទីរសន្តិសុខឃោរឃៅមួយនេះមានបទបញ្ជាតឹងរ៉ឹងណាស់សម្រាប់កម្មាភិបាលធ្វើការ បើធ្វើខុសពីបទបញ្ជា អ្នកទាំងនោះនឹងប្រឈមមុខនឹងគ្រោះថ្នាក់មិនខាន ។ គាត់បាននិយាយថា ការងាររបស់គាត់គឺថតរូបអ្នកទោសនៅក្នុងបន្ទប់របស់គាត់ តែមិនបានដឹងមានរឿងអ្វីកើតឡើងចំពោះអ្នកទោសបន្ទាប់ពីថតរូបរួចនោះទេ ។ អ្នកសរសេរអត្ថបទខាងលើបានសរសេរថា អ៊ីម «នៅចាំជនជាតិ ញូវហ្សេឡែន គួបាស៊ីស អ្នកបើកកាណូតជនជាតិថៃ និងនៅមានច្រើនទៀតដែលបាត់ដំណឹង» ។ បញ្ហាលើកឡើងនេះពិតជាមិនត្រឹមត្រូវបើយោងទៅតាមសម្តីរបស់ អ៊ីម ។

អ៊ីម បញ្ជាក់ថា គាត់មិនដែលបានឃើញអ្នកទោសបរទេសទាំងនោះទេ ។ តាមពិតគាត់គ្រាន់តែបានឃើញតាមរយៈរូបថតជនបរទេសបីនាក់ដែលកម្មាភិបាលខ្មែរក្រហមយកហ្វីលមកឲ្យគាត់ផ្តិតប៉ុណ្ណោះ ។ នៅក្នុងចំណោមនោះមានម្នាក់មានពុកចង្កា ដែលគេប្រាប់គាត់ថាជាជនជាតិគួបា ។ គាត់មិនបានដឹងពីការចាប់ខ្លួននិងហេតុការណ៍ដែលកើតឡើងចំពោះអ្នកទោសទាំងនោះទេ ។ ហេតុនេះគាត់មិនបានដឹងពីមូលហេតុនៃការចាប់ខ្លួនឬក៏ការស្លាប់រស់របស់អ្នកទាំងនោះឡើយ ។ បើយោងទៅលើការប្រាប់របស់ អ៊ីម ការអះអាងណាមួយដែលថាជនជាតិគួបាត្រូវបានដុត ហើយសម្លាប់នៅមន្ទីរស-២១នោះជារឿងមិនពិតឡើយ ។

អ៊ីម បន្តទៀតថា ការលើកឡើងរបស់អត្ថបទនៅមានកំហុសពីរថែមទៀត ។ ទីមួយគឺរឿងស្លាកលេខដែលព្យួរនៅករបស់អ្នកទោស ។ អត្ថបទបានដកស្រង់សម្តី អ៊ីមថា «នៅឆ្នាំ១៩៧៧ យើងមិនបានព្យួរស្លាកនៅកអ្នកទោសទេ យើងគ្រាន់តែថតប៉ុណ្ណោះ» ។ តាមពិត គាត់និយាយថា ក្រុមគាត់ព្យួរស្លាកនៅកអ្នកទោសរហូតចាប់តាំងពីគាត់ចូលធ្វើការដំបូងនៅឆ្នាំ១៩៧៧ ។ ជាបឋមគាត់គ្រាន់តែសរសេរលេខនៅលើស្លាកនោះប៉ុណ្ណោះ តែក្រោយមកសរសេរឈ្មោះនិងថ្ងៃខែបន្ថែមទៀត ។ ប្រការខុសមួយទៀតគឺការអះអាងថា នឹម អ៊ីម និង ញ៉ែម អេន ជាអ្នករួមការងារ ។ ការពិតអ្នកទាំងពីរបានអះអាងថាមិនដែលស្គាល់គ្នាឡើយ ។ អ៊ីម គិតស្មានថា ញ៉ែម អេន ប្រហែលជាធ្វើការនៅក្រុមផ្សេងគ្នានៅមន្ទីរស-២១ ។

បើទោះជា នឹម អ៊ីម មិនបាននិយាយធ្ងន់ៗពីអ្វីដែលបានកើតឡើងនៅមន្ទីរស-២១ក៏ដោយ ក៏គាត់គ្មានការស្ទាក់ស្ទើរក្នុងការគាំទ្រដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមឡើយ ។ ចំពោះគាត់ ការកាត់ទោសនេះនឹងជាគំរូមួយសម្រាប់អ្នកដឹកនាំជំនាន់ក្រោយមិនឲ្យប្រព្រឹត្តអំពើសាហាវយង់ឃ្នងបែបនេះ និងធានាមិនឲ្យរបបដូចនេះកើតមានជាថ្មីទៀត ។ គាត់បាននិយាយថា ប្រជាជនជាច្រើនបានស្លាប់នៅក្នុងរបបនេះ នៅក្នុងនោះមានប្អូនប្រុសរបស់គាត់ពីរនាក់ដែរ ។ អ៊ីម មានការសោកស្តាយចំពោះការចូលរួមរបស់ខ្លួននៅក្នុងបដិវត្តន៍កុម្មុយនីស្តដែលបានផ្តាច់ជីវិតមនុស្សរស់ជិតពីរលាននាក់ ។

ចំណុចសំខាន់របស់ខ្ញុំក្នុងការសរសេរអត្ថបទនេះគឺដើម្បីបញ្ជាក់ថាប្រវត្តិសាស្ត្ររបបខ្មែរក្រហមឬរបបកម្ពុជាប្រជាធិបតេយ្យមានសារសំខាន់ណាស់សម្រាប់ប្រជាជនកម្ពុជា ដូច្នេះក្នុងនាមជាអ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ អ្នកប្រវត្តិសាស្ត្រ ត្រូវតែផ្សព្វផ្សាយការស្រាវជ្រាវល្អនិងព័ត៌មានដែលពិតនិងត្រឹមត្រូវ ។ បើទោះជារបបខ្មែរក្រហមបានផុតរលត់ទៅជាងសាមសិបឆ្នាំមកហើយក្តី ក៏រឿងរ៉ាវ ការចងចាំនិងការឈឺចាប់ផ្ទាល់ខ្លួននៅតែមាននិងប៉ះពាល់ដល់ជីវិតបច្ចុប្បន្នរបស់អ្នករស់រានមានជីវិត ។ អាស្រ័យហេតុនេះ យើងមិនគួរឲ្យអារម្មណ៍និងការដកស្រង់សម្តីខុសសម្រាប់គោលបំណងជាក់លាក់ណាមួយដែលអាចកែប្រែប្រវត្តិសាស្ត្រជាពិសេសនៅក្នុងករណីសោកនាដកម្មនៃរបបប្រល័យពូជសាសន៍បែបនេះឡើយ ។ **ព្រុំ ផល្លា**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្ដើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្ដុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្ដល់ជូននូវសេវា៣យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្ដី ស្ដាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្ដល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង លី សុខឃាង តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ក្រុមហាកិម-ទូន កំពុងបំពេញពាក្យបណ្ដឹង



ក្រុមហាកិម-ទូន កំពុងបំពេញពាក្យបណ្ដឹង

# សុន្ទរកថារបស់លោកឯកអគ្គរដ្ឋទូត ចូសេហ្វ មូសូមេលី ក្នុងពេលជួបប្រជុំជាមួយជនជាតិចាម ដែលជាអ្នកដាក់ពាក្យប្តឹង ទៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៧

អរុណសួស្តី! អ៊ីសាឡាមូ អាឡៃគុម! សូមស្វាគមន៍ដែលបានអញ្ជើញមកកាន់ផ្ទះរបស់ខ្ញុំ អាឡាន វ៉ាសាឡាន! កាលពីឆ្នាំទៅមានជនរងគ្រោះដោយរបបខ្មែរក្រហមចំនួនជាងមួយពាន់នាក់បានមកអង្គុយ នៅកន្លែងដែលលោក-អ្នកកំពុងតែអង្គុយនេះ ហើយយើងបាននិយាយគ្នាអំពីបទឧក្រិដ្ឋដ៏ធំមួយក្នុងចំណោមបទឧក្រិដ្ឋធំៗបំផុតនៅក្នុងសតវត្សរ៍ទី២០ ដែលមិនទាន់ទទួលការដាក់ទណ្ឌកម្មក្រោយពីការប្រព្រឹត្តអស់រយៈពេល៣០ឆ្នាំ ។ ដូចយើងទាំងអស់គ្នាដឹងស្រាប់ហើយ ខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់ជនជាតិខ្មែរជាលក្ខណៈប្រព័ន្ធអស់ជាងពីរលាននាក់ ។ ពេលនោះគ្មាននរណាម្នាក់មានសុវត្ថិភាពទេមិនថា អ្នកនោះជាជនជាតិចាម វៀតណាម ព្រះសង្ឃ អ្នកក្រុង អ្នកមានសញ្ញាប័ត្រ ឬអ្នកពាក់វ៉ែនតាទេ ។ អ្នកទាំងនេះរួមនិងមនុស្សជាច្រើនទៀតដោយរួមទាំងសាច់ញាតិគ្រួសារត្រូវខ្មែរក្រហមសម្លាប់ទាំងអស់ ។

ជនជាតិចាមទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង ។ ខ្មែរក្រហមមិនអត់ឱនឲ្យអ្នកដែលមានជំនឿលើព្រះ ឬអ្នកដែលជឿថាការសម្លាប់ផ្ទុយទៅនឹងច្បាប់របស់ព្រះឡើយ ។ សម្រាប់ខ្មែរក្រហមតាំងខ្លួនជាព្រះនិងជាច្បាប់ ។ ខ្មែរក្រហមមានសិទ្ធិដាច់ខាតក្នុងការសម្លាប់ ឬទុកជីវិតឲ្យនរណាក៏បាន ។ ភាពគឃ្លើនបែបនេះចៀសមិនផុតពីរលំរលាយទេ ។

ក្នុងពេលថ្មីៗនេះ នៅទីបំផុត មានដំណើរវិវត្តន៍ច្រើនក្នុងការនាំឃាតករទាំងនេះមកកាត់ទោស ។ ការជឿនលឿននេះមិនមានភាពរលូនទេ និងមានឧបសគ្គទៀតផង ប៉ុន្តែដោយសារភាពអត់ធ្មត់និងការប្រឹងប្រែងជម្នះឧបសគ្គទាំងនេះទើបសម្រេចបានក្នុងការបង្កើតឡើងនូវតុលាការកាត់ទោសខ្មែរក្រហមនេះ ។ វិធានផ្ទៃក្នុងត្រូវបានអនុម័ត ថ្ងៃសេវាមេធាវីត្រូវបានព្រមព្រៀងគ្នា ហើយមានការចាប់ខ្លួនមនុស្សពីរនាក់ ការស៊ើបអង្កេតបន្ថែមកំពុងតែដំណើរការទៅមុខ ហើយសវនាការសាធារណៈមុនពេលកាត់សេចក្តីក៏កំពុងត្រូវបានកំណត់ពេលវេលាធ្វើដែរ ។ ឥឡូវនេះយើងជួបជុំគ្នាដើម្បីអបអរឱកាសមួយទៀតជាប្រវត្តិសាស្ត្រនោះគឺការដាក់ពាក្យបណ្តឹងដោយជនជាតិចាមម្នាក់ៗដែលជាជនរងគ្រោះ ។

ទង្វើមួយក្នុងចំណោមទង្វើនានាដែលគួរឲ្យសរសើររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការកាត់ទោសខ្មែរក្រហមគឺថា ជនរងគ្រោះម្នាក់ៗក្នុងរបបខ្មែរក្រហមអាចចូលរួមក្នុងការដាក់បណ្តឹងព្រហ្មទណ្ឌទៅព្រះរាជអាជ្ញា ឬចូលរួមក្នុងដំណើរដែលកំពុងតែប្រព្រឹត្តទៅក្នុងនាមជាភាគីស៊ីវិល ។ ការណ៍នេះមានភាពសមរម្យណាស់ ពីព្រោះការលុបបំបាត់ចោលទាំងស្រុងនូវទស្សនៈដែលផ្តល់សេរីភាពដល់មនុស្សម្នាក់ និងការបដិសេធនូវតម្លៃដែលមិនអាចកាត់ថ្លៃបានរបស់ជីវិតមនុស្សម្នាក់ៗនោះគឺជាគោលបំណងសំខាន់របស់ខ្មែរក្រហម ។ ខ្មែរក្រហមប្រហែលជាមិនយល់ស្របជាមួយនឹងគម្ពីរកូរ៉ានដែលចែងថា ការឆក់យកជីវិតរបស់ជនស្លូតត្រង់ម្នាក់ប្រៀបបាននឹងការសម្លាប់មនុស្សជាតិទាំងមូលនោះទេ (ផ្នែកទី៥:៣២) ។ សម្រាប់ខ្មែរក្រហម ការសម្លាប់ប្រជាជនស្លូតត្រង់មានហេតុផលត្រឹមត្រូវ ប្រសិនបើការសម្លាប់នោះបម្រើឲ្យបំណងរបស់ខ្លួនក្នុងការកសាងឋានសួគ៌មិនពិតមួយនៅលើដែនដីយើងនេះ ។ ដូច្នេះវាជាការសមហេតុផលណាស់ដែលនៅពេលនេះ ជនរងគ្រោះម្នាក់ៗត្រូវបានអនុញ្ញាតឲ្យដាក់ពាក្យបណ្តឹងដើម្បីបង្ហាញពីការឈឺចាប់របស់ខ្លួន ។

ចៅក្រមក្នុងតុលាការកាត់ក្តីខ្មែរក្រហមគួរទទួលបានការសរសើរចំពោះការបង្កើតឲ្យមានអង្គភាពទទួលបន្ទុកជនរងគ្រោះដើម្បីជួយអ្នកដែលដាក់ពាក្យបណ្តឹង ឬចូលរួមជាមួយនឹងការ

អនុវត្តន៍តាមភាគីស៊ីវិល ។ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏គួរតែទទួលបានការកោតសរសើរផងដែរក្នុងការជួយជនរងគ្រោះជនជាតិចាមនៅក្នុងកិច្ចខិតខំនេះ ។ ជាមួយនឹងការដាក់ពាក្យបណ្ដឹងទាំងនេះ ជនជាតិចាមទាមទារយកមកវិញនូវផ្នែកមួយនៃអត្តសញ្ញាណរបស់ខ្លួនដែលមានការទាក់ទងយ៉ាងច្បាស់ទៅនឹងប្រវត្តិសាស្ត្ររាប់រយឆ្នាំរបស់ប្រទេសកម្ពុជា ។ ទោះបីជាមេដឹកនាំខ្មែរក្រហមប្រឹងប្រែងខ្លាំងយ៉ាងណាក្ដីដើម្បី «កម្ទេចចោល» នូវសាសនានិងប្រពៃណីរបស់លោក-អ្នកក្ដី ក៏លោក-អ្នកអាចស៊ូទ្រាំបានហើយកំពុងតែរុងរឿងជាថ្មីក្នុងប្រទេសកម្ពុជាមួយដែលប្រកបទៅដោយភាពបើកចំហនិងភាពអត់ឱន ។

ការដាក់ពាក្យបណ្ដឹងរបស់ជនរងគ្រោះមានគោលបំណងសំខាន់ពីរ គឺការចងចាំនិងយុត្តិធម៌ ។ នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ អត្រាស្លាប់របស់ជនជាតិចាមមានចំនួនច្រើនជាង២ដងចំនួនប្រជាជនទូទៅ ។ ដោយសារតែបងប្អូនជនជាតិចាមការពារនូវជំនឿនិងប្រពៃណីរបស់ខ្លួន បងប្អូនត្រូវបានចាត់ទុកថាជា «សត្រូវប្រភេទទី១»របស់ខ្មែរក្រហម ។ ជនជាតិចាមស្ថិតនៅក្នុងចំណោមមនុស្សតិចតួចដែលហ៊ានងើបឡើងតស៊ូប្រឆាំងនឹងអំពើព្រៃផ្សៃនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយដោយសារតែសេចក្ដីក្លាហាននេះហើយទើបធ្វើឲ្យបងប្អូនជនជាតិចាមទទួលរងនូវការឈឺចាប់យ៉ាងខ្លាំង ។

នៅពេលដែលពាក្យបណ្ដឹងជនរងគ្រោះកំពុងមានដំណើរការទៅមុខ ប្រជាពលរដ្ឋកម្ពុជាទាំងអស់នឹងសម្លឹងទៅរកអង្គការសហប្រជាជាតិ តុលាការកាត់ទោសខ្មែរក្រហម និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីឆ្លើយតបនូវការប្រឈមមុខដ៏សំខាន់មួយចំនួន ។ តុលាការកាត់ទោសខ្មែរក្រហម ជាប្រភេទតុលាការឧក្រិដ្ឋកម្មសង្គ្រាមថ្មីមួយប្រភេទ ហើយជាលើកទីមួយហើយដែលផ្អែកលើទម្លាប់ផ្នែកច្បាប់ស៊ីវិល ដូចនេះការលំបាកនិងការឈឺចាប់មិនអាចចៀសរួចឡើយ ។ តុលាការកាត់ទោសខ្មែរក្រហម ពេលនេះកំពុងជួបប្រទះនូវបញ្ហាក្នុងការគ្រប់គ្រងដែលបង្ហាញថា មិនត្រឹមតែភាពថ្មីថ្មោងរបស់ខ្លួនទេ ប៉ុន្តែថែមទាំងបានបង្ហាញពីភាពលំបាកក្នុងការផ្ដល់ជំនួយបច្ចេកទេសរបស់អន្តរជាតិដល់ក្របខណ្ឌនៃតុលាការក្នុងស្រុកផងដែរ ។ ការធ្វើឲ្យប្រសើរឡើងវិញនូវការគ្រប់គ្រងរបស់តុលាការកាត់ទោសខ្មែរក្រហមមានសារសំខាន់នៅពេលដែលយើងធ្វើដំណើរទៅមុខ ។

តុលាការកាត់ទោសខ្មែរក្រហម ក៏ប្រឈមមុខនឹងបញ្ហាក្នុងការផ្ដល់យុត្តិធម៌ឲ្យបានទាន់ពេលវេលាផងដែរ ។ ដើម្បីបើកសវនាការដែលមានប្រសិទ្ធភាព គឺត្រូវការធនធានជាច្រើននិងការចាត់ចែងឲ្យបានត្រឹមត្រូវ ។ ធនធានទាំងនេះត្រូវពឹងផ្អែកទៅលើម្ចាស់ជំនួយដែលនឹងទាមទារថា ថវិកានឹងត្រូវចំណាយឲ្យបានច្បាស់លាស់និងមានតម្លាភាព ។ ដំណើរការនៃសាលាក្ដីខ្មែរក្រហមនឹងតម្រូវឲ្យមាននូវយន្តការត្រួតពិនិត្យបន្ថែមទៀតក្នុងទ្រង់ទ្រាយណាមួយដែលធ្វើការទន្ទឹមគ្នាជាមួយនឹងរដ្ឋបាលរបស់តុលាការនេះ ។

ជាទីបញ្ចប់ ដោយសារថានេះគឺជាតុលាការដែលអនុវត្តតាមស្តង់ដាយុត្តិធម៌អន្តរជាតិសម្រាប់បទល្មើសប្រឆាំងនឹងមនុស្សជាតិ យើងគួរតែយកចិត្តទុកដាក់ជាពិសេសដើម្បីធានាឲ្យបានថាដំណើរការរបស់សាលាក្ដីនេះមិនត្រូវប្រឡាក់ប្រឡូសនឹងការចោទប្រកាន់ពីបទពុករលួយ ឬបក្ខពួកនិយមឡើយ ។ នីតិវិធីនៃដំណើរក្ដីព្រហ្មទណ្ឌនេះគឺ ជាការទុកចិត្តដ៏ពិសិដ្ឋមួយនៅក្នុងការងារដ៏ពិសិដ្ឋរបស់យើងដើម្បីធានាថាគ្មាននរណាម្នាក់នឹងទទួលផលចំណេញពីការខិតខំប្រឹងប្រែងរបស់យើងក្នុងការនាំយកឃាតករដែលបានសម្លាប់ប្រជាពលរដ្ឋកម្ពុជារាប់លាននាក់នេះទៅកាត់ទោសនៅតុលាការនោះឡើយ ។

ប៉ុន្តែពេលវេលាកាន់តែខើច ដោយសារឃាតករទាំងនោះកាន់តែចាស់និងបាត់រូបរាងទៅ ។ ជានិច្ចកាល ការអត់ធ្មត់គឺជាគុណធម៌មួយ ប៉ុន្តែវាក៏អាចជាឧបសគ្គដ៏ធំមួយសម្រាប់យុត្តិធម៌ដែរ ។ សម្រាប់អ្នកទាំងឡាយដែលបានស្លាប់បាត់បង់ជីវិតនិងអ្នកទាំងឡាយដែលបានរងទុក្ខវេទនា មរណភាព និងការឈឺចាប់ត្រូវតែទទួលបានយុត្តិធម៌និងការគោរពបូជា ។ ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ គួរតែទទួលបានយុត្តិធម៌ប្រជាជនកម្ពុជាគួរតែទទួលបាននូវការឆ្លើយតបយ៉ាងសមរម្យមួយដើម្បីបំពេញសេចក្ដីស្រេកឃ្លានយុត្តិធម៌របស់ខ្លួន ។

# សកម្មភាពបំពេញពាក្យបណ្តឹងរបស់ជនជាតិ







# ចាមមុស្លីមថ្ងៃទី២៥-២៦ ខែតុលា ឆ្នាំ២០០៧









# ការពិតដែលដក់ក្នុងអារម្មណ៍នៃជីវិតកុមារភាពខ្ញុំ

ចុងឆ្នាំ១៩៧៤ ភ្លៀងរ៉ុក្កែតបានធ្លាក់ស្រោចមកលើតំបន់ក្រុងនៃទីរួមខេត្តតាកែវដែលគ្រប់គ្រងដោយយោធារបស់សេនាប្រមុខ លន់ នល់ ស្ថិតក្រោមការឧបត្ថម្ភរបស់សហរដ្ឋអាមេរិក ហៅថា «សាធារណរដ្ឋខ្មែរ» ។

ដើមឆ្នាំ១៩៧៥ សង្គ្រាមដណ្តើមអំណាចបន្តផ្តាច់ជីវិតជាតិសាសន៍ឯងកាន់តែខ្លាំងឡើង ជាសញ្ញាបញ្ជាក់ថាសង្គ្រាមនិងឈានជិតដល់ទីបញ្ចប់ហើយ ។

នៅពាក់កណ្តាលខែមេសា ភ្លើងសង្គ្រាមនៃការបែកបាក់សាមគ្គីជាតិខ្មែរបានបញ្ចប់ដោយភាគីសាធារណរដ្ឋខ្មែរបានទទួលនូវការបរាជ័យយ៉ាងអាម៉ាស់ ។

**ការមកដល់នៃកងទ័ពរំដោះ**

ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ វិទ្យុដែលផ្សាយចេញពីទីក្រុងភ្នំពេញពុំតែខ្យល់ ។ នៅតាមផ្លូវក្នុងទីរួមខេត្តតាកែវ រថយន្តដែលមានទង់ក្រហមនិងអមដោយទ័ពថ្មើរជើងក្នុងឯកសណ្ឋានពណ៌ខ្មៅប្រដាប់ដោយអាវុធគ្រប់ប្រភេទបានបើកសម្រុកចូលប្រៀបដូចជាទឹកបាក់ទំនប់ ។ ក្បួនយោធាថ្មើរជើងដើរជាក្រុមៗ ។ អ្នកដើរមុខកាន់ទង់ពណ៌ក្រហមលើកគ្រវីគ្រវាត់អមដោយសំឡេងជយឃោស «បរាជ័យ!ចក្រពត្តិអាមេរិក» «ជយោ! កងទ័ពរំដោះ» «បរាជ័យពួកចក្រពត្តិនិយម» និងមានសំឡេងអបអរគាំទ្រពីអ្នកអមតាមចិញ្ចើមផ្លូវយ៉ាងខ្សៀវខ្សារ ព្រោះគ្មានការប្រឆាំងពីក្រុមម្ខាងទៀត ។

ក្បួនយោធាបានបន្តទៅមុខនិងអមដោយសំឡេងបាញ់រះផង ។ នៅអមសងខាងផ្លូវតាមមុខផ្ទះនានា មនុស្សម្នាកាន់តែមានចំនួនច្រើនឡើងឈរត្រៀបត្រាស្វាគមន៍ដំណើរមកដល់នៃកងទ័ពរំដោះ ។ ផ្ទះជាច្រើនចាប់ផ្តើមលើកក្រណាត់សជាបណ្តើរៗដែលតំណាងឲ្យសន្តិភាពនិងអព្យាក្រឹត ។



តែប៉ុន្មានម៉ោងប៉ុណ្ណោះដំណឹងនៃការបរាជ័យរបស់របប «សាធារណរដ្ឋខ្មែរ» បានជ្រួតជ្រាបពេញទីរួមខេត្តទាំងមូល ហើយផែនការមួយដែលធ្វើឲ្យប្រជារាស្ត្រក្នុងក្រុងតាកែវភ្ញាក់ផ្អើលនោះគឺជម្លៀសប្រជាជនចេញពីផ្ទះទៅកាន់ទីជនបទតាម ការពន្យល់របស់កងទ័ពរំដោះថា «*ការចាកចេញនេះតែ៣ថ្ងៃប៉ុណ្ណោះ ព្រោះខ្លាចអាមេរិកទម្លាក់គ្រាប់បែក*» ។ ឯអាមេរិកដែលនៅពីក្រោយសាធារណរដ្ឋខ្មែរបានស្ថិតក្នុងភាពស្ងប់ស្ងៀមគ្មានប្រតិកម្មអ្វីចំពោះការបរាជ័យដ៏អាម៉ាស់នេះបន្តិចឡើយ ។

កាលនោះខ្ញុំមានអាយុ៩ឆ្នាំ ក៏បានមកឈរហែហមមួយស្របក់ដែរ ។

ផ្ទះខ្ញុំនៅមុំផ្លូវទៅកាន់ក្បាលពោធិ៍ ខាងត្បូងឆៀងខាងកើតទីរួមខេត្ត ។ បងប្រុសខ្ញុំអាយុ១៨ឆ្នាំ ខ្ញុំនិងគាត់តែងទៅណាមកណាជាមួយគ្នា ។ ខ្ញុំមានបងប្អូនបង្កើត៥នាក់ ហើយខ្ញុំជាកូនទី៤ ។ ដូច្នេះគ្រួសារខ្ញុំមានសមាជិក៧នាក់ ។ ឪពុកខ្ញុំជាទាហានរបបសាធារណរដ្ឋ

ខ្មែរ មុនបែកឆ្នាំ១៩៧៥ អង្គភាពគាត់ត្រូវបញ្ជូនមកការពារខ្សែក្រវ៉ាត់ក្រុងភ្នំពេញរហូតបែកឆ្នាំ១៩៧៥ ។

## ទីក្រុងភ្នំពេញ

មួយថ្ងៃបន្ទាប់ ម៉ោងប្រហែល៧ព្រឹកស្នូរកាំភ្លើងមិនទាន់ស្ងាត់នៅឡើយ ការប្រយុទ្ធគ្នានៅមានព្រះប៉េះរប៉ោះដោយកន្លែង ។ នៅតាមផ្លូវទៅកាន់ក្បាលពោធិ៍មានផ្ទះប្រជាជនជាច្រើននៅជាប់ខ្សែក្រវ៉ាត់ការពារទីរួមខេត្តរហូតមកជាប់ផ្លូវធំ ។ ឯផ្ទះរបស់ខ្ញុំនៅឆ្ងាយពីខ្សែក្រវ៉ាត់ប្រហែល១០០ម៉ែត្រ ។ គ្រួសារនីមួយៗបានរៀបចំអីវ៉ាន់ត្រៀមចេញដំណើរ ។ នៅខាងមុខផ្ទះខ្ញុំមានរទេះគោមួយកំពុងឈប់រង់ចាំជួយដឹកអីវ៉ាន់ឲ្យគ្រួសារខ្ញុំ ។ រទេះនេះជាគ្រួសាររបស់ ពូធូ និង មីងរីម ដែលរាប់អានឪពុកម្ដាយខ្ញុំដូចជាបងប្អូន ។ អ្នកទាំងពីរដឹងថា គ្រួសារខ្ញុំនៅពេលនេះគ្មានអ្នកជិះហរក្នុងការដឹកជញ្ជូនអីវ៉ាន់ទេ ព្រោះឪពុកខ្ញុំនៅឯភ្នំពេញឯណោះ ។

ទោះបីជាអីវ៉ាន់របស់គ្រួសារខ្ញុំត្រូវបានបញ្ជូនដាក់លើរទេះហើយក្ដី ប៉ុន្តែម្ដាយខ្ញុំហាក់ដូចជាទឹកមុខមិនសប្បាយសោះ ព្រោះគាត់ព្រួយបារម្ភឪពុកខ្ញុំមិនដឹងសុខទុក្ខយ៉ាងណា?

ក្បួនដំណើររបស់យើងបានចាប់រំកិលឆ្ពោះទៅកាន់ផ្លូវធំ ។ បងប្រុស អឿន បណ្ដើរកង់មួយមានចងអីវ៉ាន់សំពីងសំពោង ។ បងស្រី សារ៉េត ដឹកគោមួយក្បាល ឯខ្ញុំក៏ដឹកគោមួយក្បាលដែរ ។ ប្អូនស្រីនៅតូចអង្គុយលើរទេះគោជាមួយ មីងរីម ។

មកដល់មន្ទីរពេទ្យខេត្ត ខ្ញុំបានប្រទះឃើញសាកសពទាហានស្លាប់ពីរនាក់នៅលើចិញ្ចើមផ្លូវ និងមានរទេះដាក់អ្នកជំងឺបីបួនដួលគ្មានសណ្ដាប់ធ្នាប់នៅចិញ្ចើមផ្លូវ ។ តាមផ្លូវខ្ញុំប្រទះសាកសពជាហូរហែ ប៉ុន្តែគ្មានអ៊ីចម្លែកឡើយព្រោះស៊ាំភ្នែកទៅហើយ ។

ប្រហែលជាថ្ងៃត្រង់ ក្បួនដំណើររបស់ពួកយើងបានមកដល់នៅទីវាលស្រឡះមួយឆ្ងាយពីទីរួមខេត្ត មានក្រុមយុទ្ធជនអាវខ្មៅជាច្រើននាក់បានឈរត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់មកលើក្រុមអ្នកដំណើរ ។ នៅចិញ្ចើមផ្លូវម្ខាងមានក្រុមយុវជនជាច្រើនអង្គុយដោយទឹកមុខដូចហាក់ដូចជាអស់សង្ឃឹមក្នុងរឿងអ្វីមួយដោយសារដៃទាំងពីររបស់យុវជននោះត្រូវចងស្លាបសេក ។

ដោយបាត់បង អឿន យូរពេកម៉ែក៏ត្រឡប់ក្រោយតាមរកគាត់ ហើយក៏បានឃើញតែអីវ៉ាន់និងកង់ដែលដាក់ផ្ដេកចោលនៅកៀនចិញ្ចើមផ្លូវ ។ ក្បួនដំណើរត្រូវបន្តទៅមុខទៀត ។ នៅតាមផ្លូវម្ដាយខ្ញុំបានជួបមិត្តភក្តិ បងអឿន ដែលដើរក្បែរនោះបានប្រាប់ម្ដាយខ្ញុំថាបង អឿន គេចាប់ដៃរនៅខាងមុខឯណោះ ។ បន្ទាប់មក បងអឿន ត្រូវដោះលែងមកវិញដោយសារគាត់ជាសិស្ស ។

ប្រជាជនជម្លៀសទាំងអស់ត្រូវបានអនុញ្ញាតឲ្យឈប់នៅវត្តចំប៉ាដែលមានទីធ្លាធំទូលាយ នៅកណ្ដាលទីធ្លាវត្តមានដើមឈើហូបផ្លែជាច្រើនមុខនិងស្រះទឹកថ្លាឈ្វេង ដែលធ្វើឲ្យទីនោះទទួលការកោតស្ញប់ស្ញែងចាប់អារម្មណ៍ដល់គំនិតអ្នកច្នៃប្រឌិតនិងអ្នកថែទាំ ។

ពូធូ ក៏មានស្រុកកំណើតនៅម្ដុំវត្តចំប៉ាដែរ ប៉ុន្តែគាត់មិនទាន់ចូលភូមិរបស់គាត់ទេ គាត់រង់ចាំមើលក្រែងបានជួបពុកខ្ញុំ ។ ពូធូសន្យាថា បើមិនបានជួបឪពុកទេ គាត់នឹងជូនពួកខ្ញុំឲ្យដល់ស្រុកទើបគាត់ត្រឡប់មកស្រុកគាត់វិញ ។

ទីអារាមដែលកាលពីមុនធ្លាប់តែស្ងប់ស្ងាត់និងព្រៃតែសូរស័ព្ទសំឡេងធម៌ ឥឡូវបានក្លាយទៅកន្លែងប្រមូលផ្ដុំសំឡេងខ្សៀវខ្សានៃហ្វូងមនុស្សនិងសំឡេងទួញសោកសង្រេងនៃអ្នកព្រាត់ប្រាសគ្រួសារឪពុកម្ដាយបងប្អូនទៅវិញ ។

នៅទីនោះអង្គការបានឲ្យក្រុមចាស់ៗទៅប្រជុំរៀនសូត្ររាល់ថ្ងៃ ។ បួនប្រាំថ្ងៃបន្ទាប់មក គ្រួសារខ្ញុំនិងគ្រួសារ ពូធូ អស់ម្ហូបអាហារ ។ ម្ដាយខ្ញុំឆ្លៀតពេលទៅភូមិក្បែរនោះដូរបានស្ករត្នោតមួយស្នុកមកទុកគ្រាន់ទទួលទាន ។ កាលពីមុនខ្ញុំមិនដែលហូបបាយជាមួយស្ករទេ ម្ដាយខ្ញុំបានបង្ហាត់ពីរបៀបហូបជាមួយស្ករ ។ គ្រួសារខ្ញុំនិងគ្រួសារពូធូ ហូបរបៀបនេះអស់ជាច្រើនថ្ងៃ ។

ថ្ងៃមួយពេលត្រឡប់ពីរៀនសូត្រវិញ ម្ដាយខ្ញុំបណ្ដើរឪពុកខ្ញុំមកជាមួយ ។ ដំបូងខ្ញុំមើលគាត់មិនស្គាល់ថាជានរណាទេ ព្រោះគាត់ស្លៀកពាក់ខោអាវខ្មៅជូតក្បាលក្រមា បណ្ដើរកង់តួប្រុសមួយគ្រឿង ហើយនៅកន្ទុយមានសៀតកាំបិតផ្កាក់ដងវែងទៀតផង ។ ដោយមិនអស់ចិត្តខ្ញុំក៏តាមមើលគាត់ដោយហ្មត់ចត់ទើបស្គាល់គាត់ថាជាឪពុករបស់ខ្ញុំ ។ ខ្ញុំស្ទុះរត់ទៅឱបគាត់ដោយក្ដីនឹករព្ញក គាត់ក៏បានចាប់លើកខ្ញុំឱបរួបដាក់ចុះវិញ ។

ឪពុកខ្ញុំអង្គុយជជែកលេងជាមួយ ពូធូ និង មីងរីម និងអរគុណគាត់ទាំងពីរស្ទើរមិនដាច់ពីមាត់ ។ ពីរបីថ្ងៃក្រោយ ពូធូ ក៏

លាឪពុកម្តាយខ្ញុំទៅស្រុកកំណើតគាត់វិញ ។ ពុកបាននាំពួកខ្ញុំពីកន្លែងនោះមកកន្លែងថ្មីដើម្បីជួបជុំលោកតា លោកយាយ គ្រួសារពូវៀន និងគ្រួសារ ពូស៊ុយ ដែលមកពីភ្នំពេញ ។

## កសាងខ្លួនឲ្យក្លាយទៅជាមនុស្សរបស់អង្គការ

ចំណាយពេលអស់ជាច្រើនថ្ងៃ ក្រុមគ្រួសារខ្ញុំនិងតាយាយ ព្រមទាំងក្រុមគ្រួសារមាមីងទាំងអស់បានមកដល់ភូមិត្រពាំងវែង ឃុំព្រៃរំដេង ស្រុកគីរីវង្ស ដែលជាស្រុកកំណើតរបស់យើង ។ ផ្ទះចាស់របស់យើងអង្គការមិនអនុញ្ញាតឲ្យរស់នៅទេ មនុស្សរបស់អង្គការបានប្រកាសថាៈ «ពួកអ្នកថ្មីត្រូវតែជម្រុះកម្មសិទ្ធិសួនតួ ដូចនេះអ្នកថ្មីគ្មានបានបន្សល់ទ្រព្យសម្បត្តិផ្ទះសម្បែងអ្វីទេ ទ្រព្យសម្បត្តិផ្ទះសម្បែងដែលអ្នកគិតជារបស់អ្នកនោះជាជយភណ្ឌរបស់អង្គការដែលទើបរំដោះបានពីចក្រពត្តិអាមេរិក» ។ ពុកខ្ញុំបានមកស្នាក់អាស្រ័យជាមួយប្អូនបង្កើតរបស់គាត់ឈ្មោះ ឆន ។

នៅពេលមកដល់ដំបូងអង្គការបានបែងចែកប្រជាជនជាបីក្រុមៈ ក្រុមអ្នកទើបជម្លៀសមកថ្មី «អ្នកថ្មី»ជាអ្នកដែលគ្មានកម្មសិទ្ធិគ្រប់គ្រងលើដីធ្លី ផ្ទះសម្បែង ទ្រព្យសម្បត្តិ មានកម្មសិទ្ធិត្រឹមសម្លៀកបំពាក់និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃបន្តិចបន្តួចក្នុងផ្ទះបាយប៉ុណ្ណោះ ។ ចំណែកអ្នកភូមិចាស់ចែកជាពីរៈ «អ្នកមូលដ្ឋាន»និង«អ្នកពេញសិទ្ធិ» ។ **អ្នកមូលដ្ឋានៈ** ជាអ្នកស្រុកចាស់មានកម្មសិទ្ធិគ្រប់គ្រងផ្ទះសម្បែងដីធ្លីកាលពីមុន ។ **អ្នកពេញសិទ្ធិៈ** មានសិទ្ធិគ្រប់គ្រងដូចអ្នកមូលដ្ឋានដែរ និងជាអ្នកដែលអង្គការមានទំនុកចិត្តជាងគេព្រោះអ្នកពេញសិទ្ធិមានកូនចូលបម្រើក្នុងជួរកងទ័ព ។

ការងារដំបូងរបស់ក្រុមចាស់ៗគឺឡើងភ្នំរកកាប់ឈើឫស្សីមកធ្វើផ្ទះ ។ សង់ផ្ទះរួចអង្គការឲ្យយើងរើអីវ៉ាន់ទៅភ្លាម មិនអនុញ្ញាតឲ្យយើងនៅជុំជាមួយអ្នកមូលដ្ឋានទៀតទេ ។ ផ្ទះខ្ញុំនៅចុងខាងត្បូងភូមិ ។ ពេលព្រឹក កុមារតូចៗទៅរៀនថ្នាក់រួមដោយមិនគិតកម្រិតយល់ដឹង ពេលរសៀលយកគោទៅឃ្វាលនៅវាលស្រែ ។

រដូវភ្លៀងបានមកដល់ ឆ្លៀតពេលទំនេរប្រធានភូមិបានណែនាំពុកឲ្យពង្រាបគោ ព្រោះគោមិនទាន់ទឹម ចំណែកម៉ែទៅធ្វើការនៅរោងជី ។ សារធាតុជីដែលគេផ្សំមាន លាមកនិងទឹកនោមមនុស្សលាយជាមួយដីដំបូកនិងរុក្ខជាតិស្មៅមួយចំនួនទៀតដូចជាដើមទន្ទ្រានខែត្រនិងស្មៅអំបោស ។ របបហូបចុកបែងចែកអង្ករឲ្យតាមចំនួនសមាជិកក្នុងគ្រួសារនិងអ្នកពលកម្ម មនុស្សពេញកម្លាំងមួយកំប៉ុងនិងមនុស្សមិនពេញពលកម្មរបបកន្លះកំប៉ុងក្នុងមួយពេល ។ នៅពេលភ្លៀងធ្លាក់ជោកជាំបន្តិច បងអឿន ត្រូវអង្គការបញ្ជូនទៅធ្វើការនៅកងចល័តយុវជនក្នុងឃុំ ។ បងស្រី សារ៉េត និងប្អូនស្រី ត្រូវបញ្ជូនទៅធ្វើការនៅកងចល័តកុមារីក្នុងឃុំ ។ ស្រីអូន ត្រូវបញ្ជូនទៅធ្វើកងចល័តកុមារីក្នុងឃុំ ឯខ្ញុំទៅតាមពុកឃ្វាលគោនៅស្រែក្រោម ។ ក្រុមកុមារទាំងអស់មិនបានទៅរៀនដូចមុនទៀតហើយ មួយថ្ងៃៗទាំងខ្ញុំទាំងកុមារឯទៀត ទាំងចាស់ទាំងក្មេងប្រុសស្រីម្នាក់ៗចុះប្រឡូកការងារយ៉ាងសកម្មគ្មានសំចៃកម្លាំងឬពេលវេលាឡើយ ។ ពេញមួយរដូវវស្សា មនុស្សក្នុងឃុំទាំងអស់ប្រញឹកដៃធ្វើស្រែ ។ ពេលចប់ការងារពួកខ្ញុំត្រឡប់មកផ្ទះវិញដើរសំដៅរោងបាយរួមតែម្តង ។ ជាការពិត បដិវត្តន៍បានឈានមួយកម្រិតទៀតហើយ គឺធ្វើការរួម ដេករួម ហូបជាសមូហភាព សម្ភារៈប្រើប្រាស់នៅផ្ទះបាយអង្គការមិនអនុញ្ញាតឲ្យមាននៅប្រើជាគ្រួសារទៀតទេ ។ បងប្រុស បងស្រី ប្អូនស្រី ដែលអង្គការប្រមូលទៅធ្វើការរួមកាលពីមុននោះ មិនបានត្រឡប់មកជួបជុំគ្រួសារវិញដែរ ។

ក្រោយពីការប្រមូលផលស្រូវរដូវប្រាំងឆ្នាំនេះ ខ្ញុំត្រូវបានប្រាប់ឲ្យទៅប្រមូលផ្តុំនៅជង្រុកស្រូវដើម្បីត្រៀមខ្លួនទៅនៅកងកុមារ ។ ម្តាយឪពុកខ្ញុំមិនអាចឃាត់ឬរារាំងបានទេ ព្រោះនេះជាផែនការរបស់អង្គការ ។

## កងចល័ត

នៅក្នុងឃុំរំដេង អង្គការបានបែងចែកមនុស្សក្នុងឃុំជាកងចល័តច្រើនប្រភេទ ដោយប្រមូលកម្លាំងមកពីភូមិផ្សេងៗដើម្បីងាយអង្គការដាក់ផែនការនិងភារកិច្ចឲ្យធ្វើ ។ អង្គការបានចែកកងចល័តទៅតាមអាយុនិងភេទ ។ ១) កងចល័តបុរសជាកងពូៗដែលមានគ្រួសារ ឬបុរសវ័យចំណាស់អាចត្រឡប់មកផ្ទះសម្បែងវិញនៅពេលចប់កិច្ចការ ។ ២) កងចល័តមីងដែលមានគ្រួសារក៏អាចវិលត្រឡប់មកផ្ទះដែរក្រោយពេលចប់ភារកិច្ច ។ ៣) កងចល័តយុវជនបុរសវ័យជំទង់ពេញកម្លាំងត្រូវនៅកងចល័តហើយអាចទៅលេងផ្ទះបានតិចតួចឬថ្ងៃបុណ្យរបស់អង្គការ ។ ៤) កងចល័តនារីជំទង់មិនទាន់មានគ្រួសារ កងនេះក៏ធ្វើការដូចកងយុវជនដែរ ។ ៥) កងចល័តកុមារានៅធ្វើការឆ្ងាយពីផ្ទះសម្បែងដូចកងយុវជនឬ

នារីដែរ ។ ៦) កងចល័តកុមារីក៏នៅឆ្ងាយពីគ្រួសារដែរ ។ កងចល័តទាំងអស់មានវិស័យការងារតែមួយមុខប៉ុណ្ណោះគឺ«វិស័យកសិកម្ម» ។ អ្នកដែលមិនបញ្ចូលទៅក្នុងកងចល័តគឺជាមនុស្សចាស់ជរា ស្ត្រីដែលទើបសម្រាលកូននិងកុមារតូចៗដែលមិនទាន់អាចធ្វើការបាន ។ ចាស់ៗទាំងនោះក៏អង្គការមិនឲ្យទំនេរដែរ អង្គការចាត់តាំងឲ្យធ្វើការនៅមណ្ឌលកុមារមើលក្មេងដែលមានអាយុលើសពីបីខែដល់តិចជាងប្រាំឆ្នាំ ម្តាយរបស់ក្មេងទាំងនោះត្រូវចេញទៅធ្វើការ ។

ពេលមួយខ្ញុំនិងកុមារជាច្រើនទៀតបានជួបជុំគ្នានៅជង្រុកស្រូវ ខ្ញុំបានយកថង់ក្រណាត់មួយដែលម៉ែខ្ញុំរៀបចំទុកឲ្យ ។ អ្នកគ្រប់គ្រងនោះប្រាប់ថា រាល់កន្ទុះខាតអង្គការជាអ្នកមើលថែទាំជំនួសឪពុកម្តាយហើយ ។ ឌី ដែលជាប្អូនជីដូនមួយខ្ញុំបានមកជាមួយខ្ញុំដែរ ។ ពេលខ្ញុំមកដល់កន្លែងជួបជុំបងជីដូនមួយខ្ញុំបានប្រាប់ខ្ញុំថាម្តាយខ្ញុំឲ្យត្រឡប់ទៅផ្ទះវិញព្រោះគាត់ជិតសម្រាលកូនបើមិនដូច្នោះគ្មានអ្នកណាមើលថែទាំគាត់ទេ ។ អ្នកដែលមកនាំខ្ញុំទៅនោះមិនអនុញ្ញាតឲ្យត្រឡប់ទៅវិញទេ ថែមទាំងបាននិយាយថា កង់ប្រវត្តិសាស្ត្រវិលទៅមុខហើយមិនវិលត្រឡប់ទៅក្រោយបានទេ ។ បង ឈួន ឮដូច្នេះគាត់បានដើរត្រឡប់ទៅផ្ទះវិញ ។ អ្នកផ្សេងទៀតក្រោយពេលដឹងថានៅផ្ទះខ្ញុំមានម្តាយពោះធំ ក៏បានមកនិយាយលួងលោមឲ្យខ្ញុំត្រឡប់ទៅផ្ទះវិញដែរ ហើយជួយប្រាប់ពីល្បិចកលថា «ទុកអីវ៉ាន់ចោលដើរទៅផ្ទះខ្លួនទទេ នៅពេលល្ងាចចាំត្រឡប់មកយកបង្វេចនោះវិញ» ។ ខ្ញុំខ្លាចអង្គការស្អីគេនោះណាស់ ទោះបីមិនដែលឃើញឬស្គាល់អង្គការនោះយ៉ាងណាក៏ដោយ ។ ការដែលគេប្រាប់វិធីរត់ត្រឡប់ទៅផ្ទះវិញនោះ កាន់តែបន្ថែមចិត្តខ្ញុំឲ្យកាន់តែខ្លាចខ្លាំងឡើងៗសូម្បីតែចេញទៅបត់ជើងតូចក៏មិនហ៊ានចេញទៅឆ្ងាយដែរ ព្រោះអ្នកនាំនោះចេះតែសម្លឹងមើលមកខ្ញុំជាញឹកញាយ ។ បង ឈួន អាចត្រឡប់ទៅផ្ទះវិញបានព្រោះគាត់ជាអ្នកមូលដ្ឋាន ។

## កុមារនិងទារុណកម្ម

រដូវប្រាំង ខ្ញុំឃ្លាតពីម្តាយជាទីស្រឡាញ់ដោយមិនអាចប្រកែកអ្វីមួយម៉ាត់ ។ ខ្ញុំត្រូវបញ្ជូនចេញទៅភូមិត្រពាំងវែងទៅភូមិដីក្រហមដែលមានចម្ងាយប្រហែល៣-៤គីឡូម៉ែត្រ ។ កុមារក្នុងឃុំរំដេងទាំងអស់ត្រូវអង្គការឲ្យមកប្រមូលផ្តុំនៅរោងរួមវែងមួយដោយគ្មានខណ្ឌបន្ទប់អ្វីឡើយ ។ ពីរ-បីថ្ងៃដំបូង ទើបមានការរៀបចំចាត់ចែងជាកងតូចៗដែលមានគ្នាពី២៥ទៅ៣០នាក់ ។ គេឲ្យកងរបស់ខ្ញុំទៅស្នាក់នៅផ្ទះចាស់មួយខ្នងដែលគេបោះបង់ចោលនៅខាងលិចរោងប្រហែល២០០ម៉ែត្រ ។ នៅខាងក្នុងផ្ទះនោះមានគ្រែបីជួរសម្រាប់ឲ្យពួកខ្ញុំដេក ។ ផ្ទះនោះមានទីធ្លាធំល្មមនិងមានរោងមួយនៅចំហៀងសម្រាប់ប្រជុំ ។

ការងាររបស់ពួកខ្ញុំដំបូង គឺកាប់រំលាយដំបូកជញ្ជូនទៅពង្រាយលើដីស្រែ ដោយក្នុងម្នាក់រែកចាក់ឲ្យបានទំហំដី២ម៉ែត្រការ៉េក្នុងមួយថ្ងៃ ។ ពេលយប់មានប្រជុំប្រចាំថ្ងៃរហូតដល់យប់អធ្រាត្រ ។ បន្ទាប់ពីចប់ការប្រជុំមានចាត់វេនយាមយប់ប្រចាំការទល់ភ្លឺ ។ រាល់ការប្រជុំម្តងប្រធានកងតែងលើករឿងដដែលៗមកនិយាយៈ «ដើម្បីក្លាយទៅជាមនុស្សល្អរបស់អង្គការយើងត្រូវខិតខំហាត់ពត់លត់ដំខ្លួនឲ្យក្លាយជាអ្នកបដិវត្តន៍ ។ អ្នកបដិវត្តន៍គឺជាមនុស្សដែលលះបង់ជីវិតដើម្បីអង្គការលះបង់គំនិតស្នូលតួនិយមគោរពផែនការចាត់តាំងរបស់អង្គការ យើងជាកុមារត្រូវហ៊ានលះបង់គំនិតស្នូលតួនិយម ក្បាលអ្នកណាសក់អ្នកហ្នឹង» ។ ឯការហូបចុកថ្ងៃណាក៏ដូចថ្ងៃណា សម្លមានតែត្រួយដំឡូងមីគ្មានសាច់អ្វីបន្តិចឡើយ ។

រយៈពេលកន្លះឆ្នាំបានកន្លងផុតទៅ ហើយក៏ជារយៈពេលដែលខ្ញុំស្ថិតនៅក្នុងកុមារដែរ ខ្ញុំមិនដែលបានទៅលេងផ្ទះម្តងណាទេ ខ្ញុំគ្រាន់តែបានទទួលជាដំណឹងមកថា ម្តាយខ្ញុំបានឆ្លងទន្លេហើយ ។ ប្រធានកងមិនត្រឹមតែមិនអនុញ្ញាតឲ្យខ្ញុំទៅទេ ហើយថែមទាំងនិយាយថាៈ «ឯងគ្មានតួនាទីអ្វីទៅថែទាំម្តាយឯងទេ ។ បើម៉ែឯងឆ្លងទន្លេមានពេទ្យរបស់អង្គការសម្រាប់មើលថែទាំហើយ ។ ត្រឡប់ទៅផ្ទះវិញក៏មានក្រុមមនុស្សរបស់អង្គការតាមមើលថែរក្សាដែរ ឯងមិនចាំបាច់ព្រួយបារម្ភទេ» ។

ឌី បាននិយាយខ្សឹបៗតិចលួងលោមខ្ញុំថាៈ «បើពូមិនឲ្យទៅកុំទៅឲ្យសោះ ខ្លាចគេថាយើងប្រឆាំងនឹងអង្គការ» ។ ខ្ញុំបានរំសាយសេចក្តីនឹកបានមួយរយៈ ហើយគិតតែពីខំធ្វើការនៅកងបន្តទៀត ។

នៅល្ងាចមួយពេលជិតឡើងមកផ្ទះដូចសព្វដង ប្រធានកងបានប្រាប់ពីផែនការថ្មីមួយដែលទើបទទួលបានថា «ឥឡូវអង្គការដាក់ទិសឲ្យពួកយើងធ្វើការបន្ថែមនៅពេលយប់ទៀត គឺក្រោយពេលបាយល្ងាចនេះ ពួកយើងត្រូវនៅជួបជុំគ្នានៅមុខរោងបាយ

បើអ្នកណាគេចវេសពីការងាររបស់អង្គការត្រូវទទួលទោស» ។ ពួកខ្ញុំដែលជាកុមារឥឡូវត្រូវធ្វើការទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ។ ពេលថ្ងៃរែកដីដំបូកចាក់ស្រែ ពេលយប់លើកទំនប់ប្រជុំស្វ័យទិតៀនរហូតយប់ជ្រៅនិងយាមប្រចាំការពេលយប់ទៀត ។

ការងារប្រចាំថ្ងៃបានប្រព្រឹត្តទៅដដែលៗអស់ជាច្រើនថ្ងៃខែ ។ រាល់ពេលចេញទៅធ្វើការពេលថ្ងៃ ពួកខ្ញុំតែងឆ្លៀតពេលរកកូនកង្កែប ក្តាម ខ្យង និងកណ្តូបតាមផ្លូវទៅធ្វើការដោយដុតជាមួយរងើកភ្លើងលាមកគោក្រៀមហើយកាន់ជាប់រហូតដល់កន្លែងធ្វើការ ។ នៅកន្លែងលើកទំនប់ពេលយប់ ខ្ញុំរកមធ្យោបាយគេចវេះពីការងារជាញឹកញាប់ដោយយកលេសបង្គីខូចឬដាច់ខ្សែ ។ ថ្ងៃមួយខ្ញុំបានប្រាប់ទៅប្រធានកងថា បង្គីខ្ញុំដាច់ខ្សែ គាត់បានទាញយកបង្គីពិនិត្យមើល រួចសម្លុតមកខ្ញុំខ្លាំងៗថា ខ្ញុំមានបញ្ហាបង្គីញឹកញាប់ណាស់ ត្រូវធ្វើបង្គីឲ្យបានស្អាតឡើងវិញបើមិនដូច្នេះទេត្រូវទទួលទោសពីបទបំផ្លាញទ្រព្យសម្បត្តិរបស់អង្គការ ។ មិត្តភក្តិឮដូច្នេះភ័យណាស់ ក៏ជួយរកវល្លិ៍ទាំងយប់មកឲ្យពូម្នាក់ខាងកងពូៗដែលមករែកដីនៅទីនោះជួយធ្វើដៃបង្គីវិញ ។

ថ្ងៃបន្ទាប់ ខ្ញុំបានទៅធ្វើការធម្មតា តែខ្ញុំបានដើរគេចមុខពីប្រធានកង ថ្ងៃនោះក៏មិនឃើញគាត់ហៅខ្ញុំដែរ ។ ខ្ញុំត្រេកអរណាស់ដោយគ្មានការហៅមកស្តីបន្ទោស ។ ចាប់តាំងពីថ្ងៃនោះ ខ្ញុំលែងហ៊ានធ្វើអ្វីផ្តេសផ្តាសទៀតហើយ ។

ថ្ងៃមួយ ម្តាយខ្ញុំបានមកលេងខ្ញុំដល់កន្លែង ពេលគាត់បានជួបខ្ញុំដំបូងគាត់មើលខ្ញុំមិនស្គាល់ទេ ព្រោះខ្លួនខ្ញុំត្រូវក្អែលយ៉ាងក្រាស់រុំជិតគាត់ចាំតែសំឡេងខ្ញុំប៉ុណ្ណោះ ។ គាត់បាននាំខ្ញុំទៅកាន់អណ្តូងនៅមុខផ្ទះ ហើយដួសទឹកនិងដុសក្អែលឲ្យខ្ញុំយ៉ាងស្អាត ។ បន្ទាប់មកម៉ែឲ្យដំឡូងខ្ញុំពីរ-បីមើមដែលគាត់ខ្ចប់ក្នុងថង់ក្រមានិងមានស្ករត្នោតមួយដែនមកឲ្យខ្ញុំ ខ្ញុំបានបដិសេធ ព្រោះការទទួលចំណីអាហារដែលអ្នកណាយកមកឲ្យ ពេលគេឃើញឬដឹងនឹងត្រូវចោទប្រកាន់ថាក្បត់សមូហភាព ក្បត់អង្គការមិត្តក្នុងកងរួចគេនឹងវាយធ្វើបាប ។ ម៉ែយល់ចិត្តខ្ញុំ គាត់បានទាញដំឡូងមកកាច់ជាដុំតូចៗផ្សាប់ចំណិតស្ករបញ្ចុកខ្ញុំនិងឪ ។

មិត្តក្នុងកងខ្ញុំទាំងអស់សុទ្ធតែមានក្អែលជាប់ខ្លួនទាំងអស់ លើកលែងតែប្អូនឬក្មួយរបស់ប្រធានកងប៉ុណ្ណោះដែលតែងតែងូតទឹកស្អាតៗ និងមិនចេញទៅធ្វើការដូចពួកខ្ញុំ ។

នៅពេលសម្រាកថ្ងៃត្រង់ពេលខ្ញុំកំពុងរករុក្ខជាតិផ្សេងៗដែលអាចទទួលទានបាននៅក្បែរផ្ទះនោះ បងអឿន បានមកជួបខ្ញុំគាត់ឃើញខ្ញុំស្លៀកខោអាវរហែករបែបនេះ គាត់ស្រាតខោខ្លីគាត់មកឲ្យខ្ញុំ ហើយប្រាប់ឲ្យខ្ញុំទៅលេងផ្ទះផងព្រោះម៉ែនឹក ។ ក្រោយពេលគាត់ឲ្យខោអាវខ្ញុំហើយ គាត់ក៏ដើរទៅកន្លែងគាត់វិញ ។

ថ្ងៃមួយពេលសម្រាកថ្ងៃត្រង់ ពូប្រធានកងបានសួររកអ្នកដែលចេះអានអក្សរ ខ្ញុំ និង ឌី អាចចាត់ថាជាអ្នកចេះអានអក្សរព្រោះកាលពីមុនចាកចេញពីទីក្រុងតាកែវ ខ្ញុំរៀនថ្នាក់ទី១០ ដូចនេះខ្ញុំអាចអានបានច្រើន ។ ពូប្រធានកងផ្អាកខ្ញុំមិនឲ្យធ្វើការដើម្បីហាត់ច្រៀងចម្រៀងបដិវត្តន៍ជាច្រើនបទសម្រាប់ចូលរួមអបអរបុណ្យខួប១៧ មេសា ដែលនឹងមកដល់ពេលខាងមុខ ។ ប្រធានកងឲ្យខ្ញុំងូតទឹកសម្អាតខ្លួនដុសសាប៊ូក្រអូប ហើយឈរតម្រង់ជួរហាត់ច្រៀង និងការហូបចុកមានភាពល្អប្រសើរជាងមុន ។ ម្ហូបអាហារមានច្រើនមុខសម្ល មានត្រីសាច់ជាច្រើន ចានបាយនិងស្លាបព្រាថ្មីៗ ពិសេសស្លាបព្រាម្នាក់មានពីរមួយសម្រាប់ដួសបាយហូបនិងមួយទៀតសម្រាប់ដួសសម្ល ។

កងកុមារឃុំមានរបបហូបបែបនេះដូចៗគ្នាទាំងអស់រយៈពេលជាច្រើនថ្ងៃ ។ លុះក្រោយពីការប្រារព្ធពិធីនោះបីបួនថ្ងៃ របបហូបចុករបស់ខ្ញុំបានវិលទៅសភាពដើមវិញនិងធ្វើការធ្ងន់ៗដូចមុនដដែល ។

នៅរដូវភ្លៀង ពួកខ្ញុំត្រូវផ្អាកការងារលើកទំនប់ព្រោះភ្លៀងជោកជាំ អង្គការបានទុកកិច្ចការនេះសម្រាប់កងយុវជននិងយុវនារីធ្វើបង្ហើយនៅពេលថ្ងៃ ។

ក្រុមខ្ញុំអង្គការឲ្យផ្អាកការងាររែកដំបូកដែរ ។ ពួកខ្ញុំបានទទួលកិច្ចការថ្មីមួយពីពូប្រធានកង គឺទៅឃ្វាលគោតាមភូមិ ។ ពេលព្រឹករកបោចស្មៅតាមចម្ការក្បែរភូមិយកទៅដាក់នៅទ្រុងគោនិងទទួលគោពីម្ចាស់ទៅលាងសម្អាតនៅពេលថ្ងៃត្រង់ បន្ទាប់មកដឹកវាទៅស៊ីស្មៅរហូតដល់ល្ងាច ។

## ការជម្លៀសអ្នកភូមិ

ចុងឆ្នាំ១៩៧៧ អង្គការបានជម្លៀសអ្នកថ្មីទៅកន្លែងផ្សេង

ដោយគ្មាននរណាដឹងជាមុន ។ អ្នកថ្មីក្នុងឃុំទាំងអស់ត្រូវមកជួបជុំគ្នានៅភូមិឬរដើម្បីរង់ចាំរថយន្តមកទទួល ។ នៅទីនោះមានមនុស្សជាច្រើន មានទាំងញាតិសន្តានមកជូនដំណើរផង ។ ក្រុមគ្រួសារខ្ញុំទាំងបីបានមកអង្គុយនៅក្រោមដើមឈើមួយកន្លែងដាច់ឆ្ងាយពីគេបន្តិច ក្រុមចាស់ៗនៅអង្គុយជុំគ្នា ខ្ញុំនិងឪបាននាំគ្នាដើរលេងក្បែរៗនោះតាមចរិតក្មេង ។ អ៊ីកាក់ បានទាញយកក្រមាថ្មីៗចំនួន៤ដុំចេញពីក្នុងបង្វេចមកចែកពុកមួយ ឯមាៗខ្ញុំម្នាក់ពីរដុំ ហើយគាត់ពោលពាក្យទាំងទឹកភ្នែករលីងរលោងថា «មានតែប៉ុណ្ណឹងទេ បើមានវាសនាយើងនឹងបានជួបជុំគ្នាវិញ» ។ ការជជែកគ្នាបានបន្តរហូតដល់រថយន្តរបស់អង្គការមកដល់ ។

ក្រុមគ្រួសារខ្ញុំទាំងបីបានឡើងរថយន្តជាមួយគ្នាដោយមានអ៊ីកាក់ ជួយអន្តរាគមន៍ ។ ក្បួនរថយន្តបានចេញមកទិសខាងលិចតាមអន្លង់ស្ពានឆ្ពោះសំដៅទៅកាន់តាខេត្តកំពត ។ រថយន្តបាននាំគ្រួសារខ្ញុំមកឈប់នៅភូមិសេរីដំណាក់ ឃុំត្រពាំងធំ ស្រុកត្រាំកក់ ខេត្តតាកែវ ។ ឆ្ងាយពីភូមិសេរីដំណាក់ភាគខាងត្បូងបន្តិចមានស្ទឹងមួយ ហួសពីស្ទឹងនោះឆ្ងាយទៅឃើញខ្នងភ្នំជីវិរមៀលលាតសន្ធឹងទៅទិសខាងលិចរំលេចដោយធម្មជាតិបៃតងចាស់ខ្ចី ។

អ្នកជិះក្នុងរថយន្តជាមួយគ្រួសារខ្ញុំទាំងអស់ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅទីធ្លាក្រោមដើមឈើក្នុងភូមិគ្រឹះចាស់មួយរួមគ្នា ។ ស្ថិតនៅក្រោមដំបូលរបស់អង្គការបដិវត្តន៍ មនុស្សនៅក្នុងឃុំត្រពាំងធំទាំងមូលត្រូវបានបែងចែកជាកងដូចកាលនៅព្រៃរំដេងដែរ ។ ថ្ងៃបន្ទាប់ពុកនិង បងអឿន ទៅធ្វើការបាត់ៗ ម៉ែមិនទាន់ចេញទៅធ្វើការទេព្រោះគាត់មានកូនតូចហើយភ្លោះទៀត ។ បងសារ៉េត និង ស្រីអូន នៅកងកុមារីនៅខាងជើងថ្នល់ឆ្ងាយពីផ្ទះគួរសម ។ ខ្ញុំនៅកងចល័តមួយ មានទីតាំងក្បែរសេរីសំណាក់ដែរ ។ ការហូបចុកនៅទីនោះមានរៀបចំជាស្តូក ដែលក្នុងមួយស្តូកសម្រាប់មនុស្សប្រាំមួយនាក់ ។ បន្ទាប់ពីដឹកប្រឡាយ អង្គការបានឲ្យកុមារប្រមូលលាមកគោនៅតាមស្រែមកដាក់ក្នុងរោងមួយសម្រាប់ធ្វើជីនៅឆ្នាំបន្ទាប់ ។

ពេលវេលាបានឈានទៅមុខដោយមិនចេះនឿយណាយ ស្រូវក្នុងស្រែបានប្រែពណ៌ពីបៃតងមកក្រហមទុំ ។ កម្លាំងក្នុងឃុំបានច្រូតកាត់ប្រមូលផលដាក់ជង្រុក ឯកងកុមារខ្ញុំផ្លាស់កន្លែងទៅភូមិមួយនៅខាងជើងផ្លូវធំ ។ នៅកន្លែងថ្មីនោះ ខ្ញុំបានជួបបងប្អូនជីដូនមួយពីរនាក់គឺ សឿន និង សុង ។ ខ្ញុំទើបមកដល់ប៉ុន្មានថ្ងៃ ប្រុស ដែលមានអាយុ៥ឆ្នាំនិងជាប្អូនរបស់ សុង និង សឿន ក៏បញ្ជូនមកទីនេះដែរ ។ ប្រធានកងបានធ្វើការចោទប្រកាន់ ប្រុស នៅក្នុងអង្គប្រជុំដោយត្រង់ៗថា ជាខ្មាំង ជាមនុស្សរារាំងដល់បដិវត្តន៍ ។ ខ្ញុំទាំងបួននាក់ភ័យព្រួយជាខ្លាំង ព្រោះនរណាក៏ដឹងថា ប្រុស ជាប្អូនរបស់យើងដែរ ។ នៅក្នុងអង្គប្រជុំ ប្រុស ត្រូវបង្ខំឲ្យនិយាយសារភាពតាមភាសាក្មេងដែលទើបរៀននិយាយ រហូតកុមារម្នាក់ៗដឹងថា ប្រុស មានកំហុសដោយសារលួចទឹកត្នោត ។ ខ្ញុំធូរចិត្តបន្តិច ដោយឮប្រធានកងនិយាយថា «សក់អ្នកណា ក្បាលអ្នកនោះ» ។ ក្រោយពេលចប់ប្រជុំ សឿន និង សុង បាននាំ ប្រុស ទៅកន្លែងសម្រាកមុន ។ ខ្ញុំ និង ឪ សម្រេចចិត្តផ្លាស់កន្លែងដេកដើម្បីចៀសវាងកុំឲ្យប្រធានកងមកយក ប្រុស ពេលយប់ ។ ប៉ុន្តែគួរឲ្យស្តាយពេលដែលខ្ញុំនិងឪមកដល់ សឿននិងសុង បាននិយាយអួលដើមកមកថា ប្រុស ត្រូវប្រធានកងបាននាំចេញទៅមុននេះបាត់ទៅហើយ ។ អ្នកនៅជុំវិញដេកលង់លក់អស់ទៅហើយ យើងទាំងបួននាក់អង្គុយរង់ចាំផ្លូវ ប្រុស ដល់យប់ជ្រៅនៅតែមិនឃើញត្រឡប់មកវិញ ។ លុះព្រឹកឡើងក៏មិនឃើញ ប្រុស ត្រឡប់មកវិញទៀត ។

ឪពុករបស់សឿន និងសុង ត្រូវអង្គការស្នើយកទៅរៀនសូត្របាត់ ។ ពីរថ្ងៃក្រោយមកមានឃើញរណ្តៅថ្មីមួយនៅគុម្ពោតព្រៃឆ្ងាយពីកន្លែងកងកុមារពីរ-បីរយម៉ែត្រ ។ កងកុមារទាំងអស់ត្រូវចល័តចេញពីភូមិនោះបន្ត ដូចនេះកងខ្ញុំនិងកងសឿន ត្រូវនៅបែកគ្នាទៀត ។

កងកុមារក្នុងឃុំត្រពាំងធំខាងជើងត្រូវចល័តពីកន្លែងមួយទៅកន្លែងមួយតាមភូមិជាច្រើនក្នុងឃុំ ។ លុះការប្រមូលផលនៅក្នុងឃុំរួចរាល់ កងខ្ញុំត្រូវបញ្ជូនទៅភូមិបឹងស្រងែដែលស្ថិតនៅចុងខាងជើងឃុំត្រពាំងធំខាងជើងជាប់ព្រំប្រទល់ខេត្តកំពង់ស្ពឺ ។ ខ្ញុំលែងមានឱកាសជួបឪពុកម្តាយទៀតហើយ ខ្ញុំអាចជួបគាត់បានតែនៅថ្ងៃទី១០ ដែលជាថ្ងៃរបស់អង្គការបានកំណត់ឲ្យប្រជាជនប្រជុំតែប៉ុណ្ណោះ ។

ការងាររបស់ខ្ញុំនៅបឹងស្រងែគឺដើររកលាមកគោឲ្យបាន ១០០គីឡូក្រាមក្នុងមួយថ្ងៃ ថ្ងៃដំបូងខ្ញុំរកបានតែ៦០គីឡូក្រាម

ប៉ុណ្ណោះ នៅខ្វះប៉ុន្មានលើកទុកនៅថ្ងៃស្អែកបន្តទៀត ។ ដោយខ្លាចប្រធានកងដាក់ទោសឬកាត់របបអាហារ ខ្ញុំនិងឪទៅដេកនៅរោងគោចាំកើបលាមកគោ ។ មួយយប់ៗ ខ្ញុំរែកបានបីទៅបួនអម្រែកយកលាក់ទុកក្នុងព្រៃក្បែរនោះ លុះព្រឹកឡើងទើបរែកមកថ្លឹង ខ្ញុំនិង ឪ ប្រឹងទាំងយប់ទាំងថ្ងៃ រហូតដល់ ឪ ចុះខ្សោយកម្លាំងដួលសន្លប់បាត់មាត់បាត់កនៅឯរោងជី ។ ខ្ញុំនិងប្រធានក្រុមបានគក់ប្រដាប់ មួយសន្ទុះក្រោយមក ឪ បើកភ្នែកព្រឹមៗ រួចក្រោកអង្គុយ ។ ពួកខ្ញុំនៅទីនោះបានមួយរយៈ ក៏ផ្លាស់មកនៅមណ្ឌលកុមារនៅព្រៃការវិញ ហើយទទួលការងាររកលាមកគោដដែល ។

រដូវភ្លៀងក៏មកដល់ កងខ្ញុំមានកុមារចំនួន៣៥នាក់ ត្រូវចុះជួយស្ទូង ដោយកំណត់ឲ្យស្ទូងបានមួយហិកតាក្នុងមួយព្រឹក ពេលល្ងាចដកសំណាបម្នាក់មួយដូន ។ បើដកមិនគ្រប់ចំនួននឹងកាត់របបកន្ទះចាន ។ ថ្ងៃណាក៏ដូចថ្ងៃណាខ្ញុំនិងឪត្រូវកាត់របបរាល់ថ្ងៃ ។ មានពេលមួយនោះប្រធានកងវាយខ្ញុំ ដោយសារខ្ញុំចាប់ក្ដាមហូបឆៅ ហើយចោទថាគេចវេះនិងការងារ ។

បន្ទាប់ពីធ្វើការដកស្ទូងរួចរាល់ កងរបស់ខ្ញុំវិលមករកលាមកគោធ្វើជីបន្តទៀត ។ ប៉ុន្តែខ្ញុំត្រូវដកឲ្យឃ្វាលគោម្ដង ខ្ញុំនិងឪត្រូវទម្លាប់រស់នៅបែកគ្នា ហើយ ឪ ក៏ហាក់ដូចរឹងប៉ឹងជាងមុន ចេះរស់នៅដោយខ្លួនទីពឹងខ្លួន ។ ថ្ងៃមួយអង្គការបានស្នើគោពីកងកុមារសម្រាប់យកទៅប្រើនៅក្នុងភូមិនានា ។ ថ្ងៃនោះ ប្រធានកងបានហៅកុមារទាំងអស់មកប្រជុំ ។ ពូប្រធានកងបាននិយាយថា អង្គប្រជុំនេះធ្វើការទិតៀនអ្នកអសកម្ម ។ ប្រធានកងបានហៅឈ្មោះមិត្តខ្ញុំម្នាក់ឲ្យមកអង្គុយមុខអង្គប្រជុំ ។ មិត្តខ្ញុំបានលើកដៃសំពះអង្វរញាប់មាត់ថាមិនដឹងថាខ្លួនមានកំហុសនោះទេ ។ ពូប្រធានកងបានសម្លុតឲ្យមិត្តនោះនៅស្ងៀម រួចគាត់ហៅឈ្មោះខ្ញុំម្ដង ។ គាត់បានបង្គាប់ឲ្យខ្ញុំក្រោកឈរដើរមកខាងមុខ សួរខ្ញុំដោយទឹកមុខញញឹមមកខ្ញុំថា «ឯងមានកំហុសអី?» ខ្ញុំបែរទៅគាត់តបថា «ខ្ញុំគ្មានដឹងថាខ្ញុំមានកំហុសអីទេ សូមមេត្តា...!» ។ ពូប្រធានកងនិយាយ «អើ បើមិនមានកំហុសម្ដេចឯងភ័យម្ល៉េះ?» យើងចង់ដឹងថាឯងហ៊ានសារភាពឬអត់ ។ ឯងកុំភ័យ តាមពិតខ្ញុំចង់សាកល្បងជាមួយឯងទាំងពីរនាក់ទេ ។

ពូប្រធានកងចាត់តាំងឲ្យយើងទាំងពីរទៅយាមចម្ការអំពៅម្នាក់មួយកន្លែងដែលមានទំហំប្រហែលមួយហិកតា ។ ខ្ញុំចាប់ផ្ដើមពូនគល់និងលះស្លឹកតាមការណែនាំរបស់មីងៗដែលនៅបុកស្រូវក្បែរនោះ ។ នៅពេលទំនេរ ខ្ញុំបានមកលេងជាមួយកូនអ្នកមូលដ្ឋានជាញឹកញាប់ ។ ខ្ញុំមកនៅចម្ការអំពៅនេះតាំងពីដើមអំពៅនៅទាបៗ រហូតដើមអំពៅខ្ពស់ជាងក្បាលទើបប្រធានកងដូរឲ្យខ្ញុំទៅដាំបន្លែវិញ ។ ពេលបន្លែខ្ញុំឲ្យផល ខ្ញុំត្រូវផ្លាស់ទៅកាន់កងយុវជនដោយមិនអាចតវ៉ាបាន ។ ក្រុមយុវជនជាក្រុមដែលធ្វើការធ្ងន់ៗ ជាក្រុមកម្លាំងឈានមុខ ជាក្រុមលះបង់កម្លាំងកាយចិត្តនិងជាក្រុមប្រយុទ្ធមិនរាថយ ។ ការដែលប្រធានខ្ញុំដកទៅកងយុវជនមិនមែនមកដែនការឬអាយុខ្ញុំត្រូវទៅនោះទេ ។ នេះប្រហែលជាថ្ងៃមួយប្រធានកងរបស់ សឿន បានដើរកាត់ចម្ការអំពៅប្រទះឃើញខ្ញុំកំពុងស្ងោរខ្យង ហើយបានទាត់ឆ្នាំងខ្ញុំទម្លាក់ចូលស្រះ ហើយថែមទាំងសួរប្រធានកងខ្ញុំទៀតផង ។ ដោយមានការជ្រោមជ្រែងពីអ្នកមូលដ្ឋាន ពូប្រធានកងនោះមិនអាចធ្វើអ្វីខ្ញុំកើត គាត់ខឹងយ៉ាងខ្លាំង ហើយក៏បានបោះសម្ដីថា «មិនអីទេអ្វែងចាំថ្ងៃក្រោយ» ។

នៅរដូវប្រមូលកាត់ឆ្នាំនេះខ្ញុំមិនបានចូលរួមដូចនៅកងកុមារទេ ។ ការប្រមូលកាត់ទើបតែចាប់ផ្ដើម សភាពការណ៍មួយបានប្រែប្រួលខុសពីធម្មតា នៅទិសខាងកើតមានសំឡេងចម្លែកធ្វើឲ្យស្រទាប់ថ្នាក់លើមានការច្របូកច្របល់ តែប៉ុន្មានថ្ងៃប៉ុណ្ណោះកងយុវជនទាំងអស់ត្រូវរំសាយយ៉ាងស្ងប់ស្ងៀម ។ បងអឿន បាននាំខ្ញុំដើរកាត់ព្រៃសំដៅទៅផ្ទះជួបជុំគ្រួសារនៅត្រពាំងក្រឡាញ់ ។ ពួកខ្ញុំបានទៅយកអង្ករនៅរោងបាយបានជាច្រើនយកមកទុកដាំហូប ហើយពុកជាអ្នកចាត់ចែងដាំស្ល ។ សំឡេងគ្រាប់កាំភ្លើងពុកកាន់តែខ្លាំងឡើងៗ ។ ពួកខ្ញុំបានជួបក្បួនទាហានយ៉ាងវែងដើរតម្រង់ទៅទិសខាងលិច ។ នៅពេលយប់ពួកយើងបានមកសម្រាកនៅតាមចិញ្ចើមផ្លូវ ពេលនោះមានទាហានម្នាក់បានចូលមកនិយាយលេងតែគ្មានអ្នកណាម្នាក់អាចស្ដាប់ភាសានោះបានទេ ខ្ញុំពុកចាស់ៗនិយាយថា ទាហាននោះនិយាយភាសាយួន ។

យើងបន្តដំណើរជាមួយមនុស្សដ៏ច្រើនកុះករតម្រង់មកភ្នំពេញ ។ ពួកយើងលែងមានការហូបរួម ដេករួមអ្វីទៀតហើយ ។ ក្រុមគ្រួសារខ្ញុំបានមកបោះទីតាំងនៅកន្លែងនេះរហូតមកដល់សព្វថ្ងៃយ៉ាងសុខសាន្តរហូតមក ។ **ហ៊ុំ សាមិ**

*លិខិតពីមិត្តអ្នកអានៈ*

# គោរពជូន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

*ខ្ញុំបាទឈ្មោះ នូវ ហ៊ិន់ អាយុ៦៨ឆ្នាំ សញ្ជាតិខ្មែរ អតីតបុគ្គលិកក្របខ័ណ្ឌក្រសួងសុខាភិបាល ជាឪពុកបង្កើតរបស់កុមារីរងគ្រោះឈ្មោះ នូវ ច័ន្ទហ៊ូឌីវីន និងជាតំណាងឲ្យក្រុមគ្រួសារឈ្មោះ ពេជន៍ ចុងកាល់ អតីតនិស្សិតសិក្សានៅទីក្រុងតូក្យូប្រទេសជប៉ុនអំឡុងទសវត្សរ៍ឆ្នាំ១៩៦០ និងជាអតីតអគ្គនាយករោងចក្រជីជូស្វាត ស្រុកទូកមាស ខេត្តកំពត ។ ក្រុមគ្រួសារនេះមានសមាជិក៩នាក់ៈ ពេជន៍ ចុងកាល់ ជាមេគ្រួសារ ម៉េង វន្ដា ជាភរិយាដែលជាប្អូនបង្កើតរបស់ភរិយាខ្ញុំបាទ កូនប្រុសតូចៗ ៤នាក់មានឈ្មោះ ពេជន៍ ឋាមៈ, គណិត, វិទ្យា និង នពុន្ធ (នប់ពន់) ម្ដាយបង្កើត បងស្រីរបស់ ចុងកាល់ និងស្ត្រីថែទាំកុមារទាំងបួននាក់ ហើយនិងកូនស្រីរបស់ខ្ញុំម្នាក់ទៀតត្រូវខ្មែរក្រហមប្រមូលយកទៅសម្លាប់ចោលទាំងអស់ ដោយសារតែឈ្លបខ្មែរក្រហមបានស្ដាប់ពាក្យរអ៊ូររបស់ ពេជន៍ ចុងកាល់ ថា៖ «តើកាលណាទៅកូនខ្ញុំបានជាសះស្បើយ បើឲ្យតែថ្នាំអាចម៍ទន្សាយ» ។*

**តុលាការជាទីគោរព!**

*ប៉ុល ពត បានយកជីវិតកូនស្រីខ្ញុំនិងមនុស្ស៩នាក់នៅក្នុងគ្រួសារតែមួយទៅសម្លាប់ចោលយ៉ាងសប្បាយជាមួយនឹងកុមារដែលមិនទាន់ដឹងក្ដីថែមទៀតផង ខ្ញុំបាទសូមអនុញ្ញាតលើកសំណួរថា៖ តើកូនស្រីខ្ញុំមានកំហុសអ្វី? ក្មួយតូចៗរបស់ខ្ញុំបាទតើគេខុសអ្វីដែរ? តើមានកំហុសធ្ងន់ដល់កម្រិតណាទៅ បើគ្រាន់តែនិយាយថា «តើពេលណាកូនខ្ញុំបានជាសះស្បើយ បើឲ្យតែថ្នាំអាចម៍ទន្សាយ?»*

*រហូតមកដល់ថ្ងៃនេះជិត៣០ឆ្នាំកន្លង អ្នកទាំងនេះពុំទាន់ទទួលការកក់ក្ដៅ ពិសេសយុត្តិធម៌សម្រាប់ពួកគេ រួមទាំងជីវិតរាប់លាននាក់ផ្សេងទៀត ។ តើវិញ្ញាណក្ខន្ធរបស់អ្នកទាំងនេះស្ថិតក្នុងភាពរសាប់រសល់ទួញសោកយ៉ាងដូចម្ដេច?*

**តុលាការជាទីគោរពនិងជាទីសង្ឃឹម!**

*ក្នុងនាមខ្ញុំជាឪពុកនិងជាតំណាងឲ្យគ្រួសារ ពេជន៍ ចុងកាល់ សូមតុលាការមេត្តាផ្ដល់យុត្តិធម៌ឲ្យបានស័ក្ដិសមសម្រាប់រូបខ្ញុំបាទផង ។ ខ្ញុំបាទសង្ឃឹមថា តុលាការពិតជានឹងផ្ដល់អ្វីដែលជាយុត្តិធម៌ពិតៗដល់ជនរងគ្រោះ ជាពិសេសដល់សមាជិកគ្រួសារដែលនៅរស់គ្រប់ៗរូប ទោះបីជួបឧបសគ្គខ្លះៗយ៉ាងណាក៏ដោយ យុត្តិធម៌ក្នុងបរិវេណសច្ចធម៌ពិតជាចេញរូបរាងនាពេលខាងមុខជាពុំខាន ។*

*សូមគោរពនិងថ្លែងអំណរគុណយ៉ាងអនេកដល់អង្គតុលាការទាំងមូល ព្រមទាំងសហការីគ្រប់ផ្នែកបម្រើការងារនៅក្នុងអង្គជំនុំជម្រះក្ដីនេះ ។*



*នូវ ច័ន្ទហ៊ូឌីវីន*

# គោរពជូនមជ្ឈមណ្ឌលឯកសារកម្ពុជា!

ជាបឋមសូមមេត្តាអនុញ្ញាតដល់ខ្ញុំបាទបញ្ជាក់អំពីមូលហេតុដែលជំរុញឲ្យខ្ញុំបាទសរសេរសំណេរនេះផ្ញើជូនមជ្ឈមណ្ឌលកម្ពុជា ។ កាលពីថ្ងៃច័ន្ទ ទី១៣ ខែសីហា ឆ្នាំ២០០៧ ដោយចៃដន្យ ខ្ញុំបាទបានទៅលេងផ្ទះបងប្អូនខ្មែរមួយគ្រួសារដែលរស់នៅជិតខាងគ្នា ហើយបានប្រទះឃើញទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជាមានឈ្មោះថា«ស្វែងរកការពិត» លេខ៧៤ ខែកុម្ភៈ ឆ្នាំ២០០៦ ។ ភ្លាមៗនោះហាក់ជាបានកន្ត្រាក់អារម្មណ៍របស់ខ្ញុំបាទឲ្យនឹកដល់មួយរយៈពេលកន្លងផុតដ៏យូរ ។ ខ្ញុំបាទក៏បានខ្ចីទស្សនាវដ្តីស្វែងរកការពិតដែលម្ចាស់ផ្ទះបានព្រមពីកុំព្យូទ័ររបស់គាត់យកទៅអានក្នុងរយៈពេលពីរថ្ងៃ ។

តាមរយៈការអានទស្សនាវដ្តីនេះ រាល់សាច់រឿងដែលបណ្តាគ្រួសារជនរងគ្រោះដែលសុទ្ធតែជារឿងរ៉ាវដ៏មហាវេទនាខ្លោចផ្សា ក្រាំក្រាពុំអាចបំភ្លេចបានក្នុងឆាកជីវិត ។ ខ្ញុំអួលដើមកនឹកសោកស្តាយជីវិតដែលស្លាប់អត់ន័យក្រោមការដឹកនាំរបស់បនខ្មែរក្រហម ចាញ់កលល្បិចគេ បំផ្លាញជាតិសាសន៍ឯងដែលពិភពលោកពុំបានជួបប្រទះរឿងរ៉ាវនេះ ។ មេដឹកនាំខ្មែរក្រហមជឿស្លុងថា សុទ្ធតែជាកល្យាណមិត្ត តែផ្ទុយទៅវិញជាមិត្តទ្រុស្តមិត្តសោះ គេច្បាមយកអត្ថប្រយោជន៍សម្រាប់ប្រជាជននិងប្រទេសជាតិរបស់គេទៅវិញ ។

ខ្ញុំបាទនៅតែឆ្ងល់ថា មេដឹកនាំខ្មែរក្រហមនៅរស់ទាំងឡាយប្រកបដោយសេរីភាពពេញលេញ រហូតដល់សព្វថ្ងៃនៅតែអួតថាខ្លួនស្នេហាជាតិ មិនបានក្បត់ជាតិ ការពារបូរណភាពទឹកដីមិនឲ្យនរណាឈ្លានពានយកបានជាដាច់ខាត ប៉ុន្តែត្រង់ចំណុចសម្លាប់ជាតិឯងយ៉ាងរង្គាល បង្អត់ស្បៀងអាហារ ខ្វះឱសថព្យាបាលជំងឺគ្រប់ប្រភេទ បំផ្លាញខ្ទេចខ្ទីវៀនវប្បធម៌ ក្បួនខ្នាតបណ្តាបញ្ញវន្តគ្រប់មុខជំនាញសឹងសម្លាប់គ្មានសល់ មេដឹកនាំទាំងនោះហាក់ដូចជាមិនខ្វល់ខ្វាយ ឬក្លាហានហ៊ានទទួលកំហុសរបស់ខ្លួនទាល់តែសោះ ។

ខ្ញុំសូមគោរពនិងសរសើរដ៏ស្មោះចំពោះការខិតខំតស៊ូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្ថិតក្រោមការដឹកនាំចាត់ចែងរបស់លោកនិពន្ធនាយកទូទៅដែលបានប្រឹងអស់ពីសមត្ថភាពកម្លាំងកាយចិត្តនិងពុះពារចំពោះមុខឧបសគ្គដ៏សន្ធឹកសន្ធាប់រហូតកើតបានជាលទ្ធផលវិជ្ជមានដ៏គួរឲ្យមានភាពកក់ក្តៅ និងជាក្តីសង្ឃឹមដល់ជនានុជនគ្រប់ស្រទាប់វណ្ណៈនៃជនរងគ្រោះទាំងអ្នកដែលបានស្លាប់និងពិសេសសមាជិកគ្រួសារដែលរស់រានមានជីវិតរហូតដល់ថ្ងៃនេះ ។

សូមឲ្យបញ្ហាខ្មែរត្រូវដោះស្រាយរកយុត្តិធម៌ចំពោះស្ថានៃកម្ពុជាប្រជាធិបតេយ្យនាឱកាសដែលអង្គជំនុំជម្រះត្រូវដំណើរការនិងចៀសវាងកុំឲ្យមានឧបសគ្គអាចរាំងស្ទះដល់ចលនាស្វែងរកយុត្តិធម៌នេះឲ្យសោះ ។



**ឆួរ ហ៊ិន**

# ដំណឹងស្វែរកកូនប្រុសឈ្មោះ អ៊ុច ឡាង

នាងខ្ញុំឈ្មោះ ខែ្វក នីក ភេទស្រី អាយុ៧៩ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្រពាំងឈូក ឃុំមានរិទ្ធ ស្រុកដងទង់ ខេត្តកំពត។ មានកូនទាំងអស់៨នាក់ ប្រុស ២នាក់ និងស្រី ៥នាក់។ កូនទាំងអស់មានឈ្មោះដូចតទៅៈ ១) អ៊ុច អឿន ភេទស្រី ២) អ៊ុច ឡាវ ភេទប្រុស (ធ្វើពេទ្យនៅមន្ទីរពេទ្យ ១៧មេសា ក្រុងភ្នំពេញ ចុងឆ្នាំ១៩៧៩) ៣) អ៊ុច អគ្គ ភេទប្រុស (ស្លាប់ដោយជំងឺគ្រុនចាញ់ នៅចម្ការដូងក្រុងកែប ឆ្នាំ១៩៧៣) ៤) អ៊ុច មុំ ភេទស្រី ៥) អ៊ុច អឿន ភេទប្រុស ៦) អ៊ុច ឱ ភេទស្រី ៧) អ៊ុច អន ភេទស្រី និង ៨) អ៊ុច អែន ភេទស្រី។

សូមប្រកាសស្វែរកកូនប្រុសទី២ ឈ្មោះ អ៊ុច ឡាវ ដែលបានបាត់ខ្លួនរហូតមកទល់សព្វថ្ងៃ ប៉ុន្តែបានជួបចុងក្រោយនៅខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៩ ។

ប្រសិនបងប្អូនញាតិមិត្តណាបានទទួលដឹងដំណឹងអំពី អ៊ុច ឡាវ សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ដំណឹងស្វែរកម្តាយ និងប្អូនប្រុសឈ្មោះ មិន លី

នាងខ្ញុំឈ្មោះ មិន គឹមអាង ភេទស្រី អាយុ៥២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិត្រពាំងឈូក ឃុំមានរិទ្ធ ស្រុកដងទង់ ខេត្តកំពត។ ម្តាយឈ្មោះ ពៅ សួន ឪពុកឈ្មោះ មិន ម៉ាង ស្លាប់ក្នុងឆ្នាំ១៩៧៩ នៅខេត្តពោធិ៍សាត់។ មានបងប្អូនចំនួន ៥នាក់ ប្រុស ៣នាក់ និងស្រី ២នាក់។ ១) មិន គឹមអាង ភេទស្រី ២) មិន លី ភេទប្រុស (បាត់ខ្លួន) ៣) មិន ផាន ភេទប្រុស (ស្លាប់) ៤) មិន ផល ភេទប្រុស (ស្លាប់) និង ៥) មិន អេង ភេទស្រី (ស្លាប់) ។

សូមប្រកាសស្វែរកម្តាយឈ្មោះ ពៅ សួន និងប្អូនប្រុសទី២ឈ្មោះ មិន លី ដែលបានបែកគ្នាក្នុងពេលរត់ទៅខេត្តពោធិ៍សាត់មួយខែ មុនពេលកងទ័ពវៀតណាមរំដោះប្រទេសក្នុងឆ្នាំ១៩៧៩ ។

ប្រសិនបើបងប្អូនញាតិមិត្តណាបានទទួលដំណឹងអ្នកទាំងពីរ សូមមេត្តាជួយផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ដំណឹងស្វែរកប្អូនប្រុសឈ្មោះ អ៊ុយ សៀប

នាងខ្ញុំឈ្មោះ អ៊ុយ សៀប ភេទស្រី អាយុ៥១ឆ្នាំ មានស្រុកកំណើតនៅភូមិក្រាំងលាវ ឃុំអង្គរមាស ស្រុកឈូក ខេត្តកំពត។ បច្ចុប្បន្នរស់នៅភូមិអន្ទង់បែកក ឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត។ ឪពុកឈ្មោះ អ៊ុយ ប៊ុត ត្រូវខ្មែរក្រហមយកទៅសម្លាប់ក្នុងឆ្នាំ១៩៧៨ ដោយសារពីមុនគាត់ធ្វើជាពេទ្យប្រចាំនៅឃុំអង្គរមាស, ម្តាយឈ្មោះ ឡេង សៀន ស្លាប់ក្នុងឆ្នាំ១៩៧៤ ដោយសារជំងឺ ។

សូមប្រកាសស្វែរកប្អូនប្រុសឈ្មោះ អ៊ុយ ជឿង ដែលបានបែកគ្នាតាំងពីអាយុ១៣ឆ្នាំ ។ កាលពីនៅក្នុងជំនាន់ប៉ុល ពត ជឿង ត្រូវបានចាត់តាំងឲ្យទៅរៀនបច្ចេកទេសនៅទីរួមខេត្តកំពត ក្រោយមកខ្មែរក្រហមចាត់តាំងឲ្យបើកឡានដឹកអំបិល ហើយក៏បាត់ដំណឹងរហូតមកទល់សព្វថ្ងៃ ។

ប្រសិនបើបងប្អូនញាតិមិត្តណាបានស្គាល់ ឬដឹងអំពី អ៊ុយ ជឿង នៅកន្លែងណា សូមមេត្តាផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋានខាងលើ ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ។

# ទស្សនាវដ្ដីស្វែងរកការពិត



# ដើម្បីការចងចាំនិងយុត្តិធម៌

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ⬩ Preah Sihanouk Blvd ⬩ Phnom Penh ⬩ Cambodia ⬩ Tel: (855) 23 211 875 ⬩ Fax: (855) 23 210 358 ⬩ dccam@online.com.kh ⬩ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ⬩ Number 94, October 2007 ⬩ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.